ក្រសួងផែនការ
វិទ្យាស្ថានជាតិស្ថិតិ

អង្គការពលកម្មអន្តរជាតិ

# និន្នាការពលកម្មនិងការងារ កម្ពុជា ឆ្នាំ ២០១០



ទសវត្សរ៍ ការងារសមរម្យ អាស៊ាន 2006 2015

# និន្នាការពលកម្មនិងសង្គម នៅកម្ពុជា ឆ្នាំ ២០១០

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ
ភ្នំពេញ កម្ពុជា

ឧបត្ថម្ភដោយ
អង្គការពលកម្មអន្តរជាតិ

កញ្ញា ២០១០

# បុព្វកថា

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ មានសេចក្តីសោមនស្សរីករាយជាអនេក ក្នុងការដាក់ជូន ឲ្យប្រើប្រាស់នូវរបាយការណ៍ស្តីពី និន្នាការពលកម្មនិងសង្គមនេះ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការ ព័ត៌មាន និន្នាការសេដ្ឋកិច្ចសង្គម និងទីផ្សារការងារសម្រាប់អំឡុងពេលទសវត្សរ៍ការងារសមរម្យរបស់ អាស៊ាន ២០០៦-២០១៥ ដែលតំណាងរបស់រដ្ឋាភិបាលនានា ស្ថាប័ននិយោជក និងនិយោជិតពីប្រទេសកម្ពុជា និងប្រទេសជាសមាជិករបស់ ILO នៅអាស៊ី និងបាស៊ីហ្វិកបានប្តេជ្ញាទទួលយក ។

ការបោះពុម្ពផ្សាយនេះ គឺពឹងផ្អែកទៅលើទិន្នន័យដែលមាន និងបានផ្តោតទៅលើការវិភាគនិន្នាការប្រជាសាស្ត្រចុងក្រោយបង្អស់ ទីផ្សារការងារ និងសេដ្ឋកិច្ច ដោយរំលេចចេញនូវសំណើគោលនយោបាយដែលមានលក្ខណៈច្បាស់លាស់អាចអនុវត្តបាន ។ ឧបសម្ព័ន្ធស្ថិតិលំអិត ក៏មានភ្ជាប់នៅផ្នែកខាងក្រោយរបស់របាយការណ៍នេះផងដែរ ក្នុងគោលបំណងរួមចំណែកដល់ការអភិវឌ្ឍន៍សូចនាករ ដែលអាចប្រៀបធៀបគ្នាបានជាអន្តរជាតិ និងឆ្លុះបញ្ចាំងពីយេនឌ័រ ដើម្បីវាស់វែងពីការវិវឌ្ឍន៍ផ្នែកការងារសមរម្យ ។ របាយ ការណ៍នេះមានគោលដៅបំរើជាប្រភពព័ត៌មាន ដែលអាចប្រតិបត្តិបានសម្រាប់អ្នកធ្វើគោលនយោបាយ អ្នកស្រាវជ្រាវ ក៏ដូចជាបណ្តាបុគ្គល និងអង្គការដែលធ្វើការលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ។

ក្នុងរយៈពេលមួយវែង ដែលការអង្កេតជាប់ទាក់ទងនឹងការងារនេះ ពិសេសការអង្កេតកម្លាំងពលកម្មប្រកបដោយលក្ខណៈជាប្រព័ន្ធមិនអាចអនុវត្តទៅបាន របាយការណ៍នេះបានប្រើប្រាស់រាល់ទិន្នន័យ និងព័ត៌មាន ដែលមានទាំងអស់ពីប្រភពផ្សេងទៀតសម្រាប់ការវិភាគ និងចងក្រង ។ ទិន្នន័យដើមពីជំរឿន និងការអង្កេត ត្រូវបានប្រើប្រាស់រួមបញ្ចូលជាមួយទិន្នន័យដែលបានគណនាហើយមកពីបណ្តាក្រសួង ស្ថាប័ន និងសហជីព ។ ទិន្នន័យនៃជំរឿនប្រជារាស្ត្រនៃកម្ពុជាឆ្នាំ ២០០៨ ត្រូវបានប្រើប្រាស់ជាភាគបែង ប្រកបដោយភាពជឿជាក់បំផុតក្នុងការវិភាគ ។ ដោយផ្សំជាមួយទិន្នន័យជំរឿនប្រជារាស្ត្រនៃកម្ពុជាឆ្នាំ ១៩៩៨ ទិន្នន័យនៃជំរឿនទាំងពីរនេះបានផ្តល់នូវនិន្នាការដែលអាចទុកចិត្តបានយ៉ាងប្រសើរសម្រាប់គណនា សូចនាករគន្លឹះមួយចំនួន ។

ក្នុងការបំរើអ្នកប្រើប្រាស់របស់ខ្លួនឲ្យបានប្រសើរបំផុត ក្រុមពិភាក្សាការងារមួយ ដែលរួមមានអ្នក ជំនាញការ និងមន្ត្រីកម្មវិធីនិងគំរោងរបស់ ILO នាយកដ្ឋានព័ត៌មាន

ទីផ្សារការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហព័ន្ធនិយោជកកម្ពុជា (CAMFEBA) សហភាពសហជីព/សហព័ន្ធសហជីព ក្រសួងដែលពាក់ព័ន្ធ (ពោលគឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ ក្រសួងផែនការ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទា ក្រសួងកិច្ចការ នារី ។ល។) ស្ថាប័នអប់រំ និងស្រាវជ្រាវ ស្ថាប័នអភិវឌ្ឍជាតិ និងអន្តរជាតិ (ពោលគឺទីភ្នាក់ងារអង្គការសហប្រជាជាតិដែលជាប់ទាក់ទង ដូចជា UNFPA, IPEC/ILO, JICA, etc.) អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សំខាន់ៗ ដោយរួមមានសមាគមសេដ្ឋកិច្ចមិនផ្លូវការ ត្រូវបានរៀបចំឡើង និងរួមវិភាគទានដល់របាយការណ៍នេះ ហើយការចាប់ផ្តើមរបស់វា គឺសិក្ខាសាលាពិភាក្សាសម្រាប់សមាជិកទាំងអស់នៅថ្ងៃ ទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩ ។

យើងសូមថ្លែងអំណរគុណចំពោះការជួយឧបត្ថម្ភគាំទ្រ ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដោយអង្គការ ILO នៅបាងកក សម្រាប់ការរៀបចំរបាយការណ៍និន្នាការពលកម្មនិងសង្គមនៅកម្ពុជាឆ្នាំ ២០១០ នេះ ។ ក្នុងន័យនេះ ខ្ញុំសូមថ្លែងអំណរគុណជាពិសេសជូនលោកស្រី Sukti Dasgupta ដែលជាអ្នកជំនាញការជាន់ខ្ពស់ផ្នែកការងារ និងគោលនយោបាយទីផ្សារការងារ និងលោក Phu Huynh ដែល ជាមន្ត្រីព័ត៌មានទីផ្សារការងារ សម្រាប់ការខិតខំរបស់ពួកគាត់ ក្នុងការសំរបសំរួល ការជួយឧបត្ថម្ភ និងការ ណែនាំរបស់ពួកគាត់ដល់រាល់ដំណាក់កាលព្រាងរបាយការណ៍នេះ ។

ជាទីបញ្ចប់ ខ្ញុំសូមវាយតំលៃខ្ពស់ចំពោះក្រុមការងារស្នូលរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ចំពោះការខិតខំប្រឹងប្រែងរបស់ពួកគេ ក្នុងការចងក្រងរបាយការណ៍នេះ ។ ដោយឡែកលោក ហាស់ ប៊ុនថួន និងក្រុមរបស់គាត់ដែលមាន លោក ហ៊ាង កាណុល លោក សុក កុសល និង លោក បួយ សុមេធា ដែលបានបំពេញការងារដ៍មានតំលៃក្នុងការចងក្រងទិន្នន័យ និងការវិភាគ ការសរសេររបាយ ការណ៍ និងការកែតំរូវការរៀបចំកែលម្អរបាយការណ៍ ក៍ដូចជាតំរូវការការងាររដ្ឋបាល នៅក្នុងដំណើរការអភិវឌ្ឍ និងផ្សព្វផ្សាយរបាយការណ៍នេះ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងផែនការ

ឆាយ ថន

ក្រសួងផែនការ
ភ្នំពេញ ខែ កក្កដា ឆ្នាំ ២០១០

## អារម្ភកថា

របាយការណ៍ និន្នាការពលកម្មនិងការងារកម្ពុជាឆ្នាំ ២០១០ នេះត្រូវបានផលិតដោយមន្ត្រីនៃវិទ្យា ស្ថានជាតិស្ថិតិ ជាមួយនឹងជំនួយពីអង្គការពលកម្មអន្តរជាតិ (ILO) ។ របាយការណ៍មានរួមបញ្ចូលនូវបណ្តាសូចនាករកម្លាំងពលកម្មនិងសង្គម និងបានធ្វើការវិភាគលើទីផ្សារការងារ និងផលប៉ះពាល់របស់វា លើសេដ្ឋកិច្ចកម្ពុជា ។

របាយការណ៍ប្រើប្រាស់ទិន្នន័យពីប្រភពជាច្រើន ។ ជំរឿនប្រជាសាស្ត្រដែលបានអនុវត្តដោយ វិទ្យាស្ថានជាតិស្ថិតិ គឺជាប្រភពទិន្នន័យចំបងនៃរបាយការណ៍នេះ ។ យ៉ាងណាក្តី របាយការណ៍ក៏មានប្រើទិន្នន័យពីប្រភពផ្សេងទៀត ដូចជាទិន្នន័យពីបណ្តាក្រសួង អង្គការក្រៅរដ្ឋាភិបាល និង ILO ។ ស្ថាប័ន និមួយៗ មានការទទួលខុសត្រូវលើទិន្នន័យរបស់ខ្លួន ។ វិទ្យាស្ថានជាតិស្ថិតិ គ្រាន់តែប្រើប្រាស់ទិន្នន័យទាំងអស់នោះ ដើម្បីចងក្រងជារបាយការណ៍មួយ ក្នុងគោលបំណងបង្ហាញជូនសូចនាករដែលអាចប្រៀបធៀបគ្នាបាន និងមានលក្ខណ:យេនឌ័រសម្រាប់អ្នកដែលមានចំណាប់អារម្មណ៍លើនិន្នាការសេដ្ឋកិច្ច និង សង្គមកម្ពុជា ។ តាមរយៈរបាយការណ៍នេះ អ្នកស្រាវជ្រាវ អ្នកវិភាគ អ្នករៀបចំគោលនយោបាយអាចប្រើប្រាស់ទិន្នន័យដែលមាន មិនថាទិន្នន័យនោះត្រូវបានចងក្រងឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ឬស្ថាប័ន ដទៃទៀតក្តី ដើម្បីទទួលបានការយល់ដឹងប្រសើរជាងមុនពីទីផ្សារការងារនៅកម្ពុជា ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងផែនការ និងឯកឧត្តម អ៊ុក ចាយ រដ្ឋលេខាធិការក្រសួងផែនការ សម្រាប់ការគាំទ្ររបស់ឯកឧត្តមដល់ការរៀបចំរបាយ ការណ៍នេះ ក៏ដូចជាសកម្មភាពដទៃទៀតរបស់វិទ្យាស្ថានជាតិស្ថិតិ ជាពិសេសការរៀបចំរចនាសម្ព័ន្ធសារ ឡើងវិញរបស់វិទ្យាស្ថានជាតិស្ថិតិថ្មីៗនេះ ។

ខ្ញុំសូមវាយតំលៃខ្ពស់ ចំពោះការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់ ILO ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ សម្រាប់ការរៀបចំរបាយការណ៍

នេះ ។ ជាទីបញ្ចប់ខ្ញុំសូម សំដែងនូវការដឹងគុណចំពោះបណ្ដាស្ថាប័នដទៃទៀតទាំងអស់ ដែលបានផលិតទិន្នន័យ និងរួមវិភាគទានសម្រាប់របាយការណ៍នេះ ។

ជាមួយនឹងការខិតខំប្រឹងប្រែង ការរួមវិភាគទាន និងគាំទ្រចំពោះរបាយការណ៍នេះ ខ្ញុំសូមសំដែងនូវ អំណរគុណចំពោះសមាជិកក្រុមពិភាក្សាការងារទាំងអស់ ដែលបានផ្ដល់ទិន្នន័យ ក៏ដូចជាបច្ចេកទេស សម្រាប់របាយការណ៍នេះ ។

ប្រសិនបើគ្មានការខិតខំប្រឹងប្រែងរួមក្នុងការប្រមូល និងចងក្រងទិន្នន័យផ្នែកទីផ្សារការងារនេះទេ របាយការណ៍នេះមិនមានលក្ខណៈពិស្ដារដូចនេះបានឡើយ ។

មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ទទួលខុសត្រូវទាក់ទងនឹងរបាយការណ៍នេះគឺ លោក ហាស់ ប៊ុនថ្លន អគ្គ នាយករង និងលោក ហ៊ាង កាណុល អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ ។

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ



សន ស៊ីថន

ភ្នំពេញ
ខែ កក្កដា ឆ្នាំ ២០១០

# អារម្ភកថា

នៅសម័យប្រជុំថ្នាក់តំបន់នៃអាស៊ានលើកទី ១៤ របស់ ILO ក្នុងខែកញ្ញា ឆ្នាំ ២០០៦ តំណាងរបស់បណ្តារដ្ឋាភិបាល និងតំណាងបណ្តាស្ថាប័នរបស់និយោជក និងរបស់និយោជិតពីកម្ពុជា ក៏ដូចជាពីប្រទេសជាសមាជិក នៅអាស៊ី-ប៉ាស៊ីហ្វិក បានសន្យាដោយខ្លួនផ្ទាល់ ចំពោះទស្សវត្សការងារសមរម្យសម្រាប់អាស៊ាន ក្នុងរយៈកាលរហូតដល់ឆ្នាំ ២០១៥ ។ ការងារសមរម្យមិនគ្រាន់តែសំដៅលើការមានការងារសម្រាប់ ស្ត្រី និងបុរសទេ វាទាមទារផងដែរនូវការងារប្រកបដោយផលិតភាព ដែលអាចផ្តល់ផលចំណូលគ្រប់គ្រាន់ ធ្វើឲ្យពលករ និងគ្រួសាររបស់ពួកគាត់ចាកផុតពីភាពក្រីក្រ ធ្វើឲ្យពួកគាត់មានសុវត្ថិភាព ពេលមានគ្រោះអាសន្ន ផ្តល់ឲ្យពួកគាត់នូវលក្ខខណ្ឌការងារល្អរៀងរាល់ថ្ងៃ និងអនុញ្ញាតឲ្យពួកគាត់ចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្ត ដែលមានផលប៉ះពាល់ដល់ការរស់នៅរបស់ពួកគាត់ ។

ក្នុងការជួយឲ្យសំរេចបាននូវការងារសមរម្យក្នុងតំបន់ ILO បានផ្តើមចេញនូវកម្រងនៃរបាយ ការណ៍ពលកម្ម និងនិន្នាការសង្គម ដែលបង្ហាញនូវការវិភាគនិន្នាការថ្មីៗទាក់ទងនឹងការងារ និងលក្ខខណ្ឌសង្គមក្នុងតំបន់ ក៏ដូចជាការទាក់ទាញការចាប់អារម្មណ៍ចំពោះការខិតខំប្រឹងប្រែងផ្នែកគោលនយោបាយ ។ មកដល់ពេលនេះរបាយការណ៍ចំនួន ៨ ក្បាលមកហើយ ដែលបានបោះពុម្ពផ្សាយ-មួយចំនួនទាក់ទងនឹងពលកម្មនិងនិន្នាការសង្គមរបស់តំបន់ ឯខ្លះទៀតមានលក្ខណៈសម្រាប់ប្រទេសនិមួយៗ ។ កម្ពុជាបង្ហាញអំពីនិន្នាការពលកម្មនិងសង្គមជាមួយនឹងរបាយការណ៍នេះ ។ វាបានឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះសេចក្តីត្រូវការនៃការវិភាគព័ត៌មានទីផ្សារការងារដែលមានស្រាប់ និងប្រើប្រាស់វាដើម្បីបញ្ជាក់ពី ការអនុវត្តគោលនយោបាយ ។

ខ្ញុំសូមសំដែងនូវការវាយតំលៃខ្ពស់ ចំពោះឯកឧត្តម សន ស៊ីថន អគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា និងក្រុមការងាររបស់លោកដែលដឹកនាំដោយ លោក ហាស់ ប៊ុនថ្លន និងលោក ហ៊ាង កាណុលសម្រាប់ការរៀបចំរបាយការណ៍ និងការសំរបសំរួលធាតុចូលពីបណ្តាក្រសួង និងអ្នករួមវិភាគទានផ្សេង ៗ ទៀត ។ របាយការណ៍នេះក៏ទទួលបាននូវការរួមចំនែកពីការសំរបសំរួលបច្ចេកទេស ដោយសហការីខ្ញុំគឺ លោកស្រី Sukti Dasgupta និងលោក Huynh Phu ក៏ដូចជាធាតុចូលពីសហការីមួយចំនួនទៀត តួយ៉ាងដូចជា៖ Pong-sul Anh, Suradee Bhadrasiri, Nelein Haspels, Richard Howard, Bjorn Johannessen, Tsuyoshi Kawakami, Jiun Kim,

Gyorgy Szirachi, DraganRadic, Bijoy Raychoudhury, John Richotte, Valerie Schmitt-Diabate, Simrin Singh, Camela Torres, Sophon Tun, Pracha Vasuprasat និង David Williams ។ Karen Emmons បានកែសំរួលភាសាអង់គ្លេស ។

ខ្ញុំមានសេចក្តីរីករាយ ក្នុងការបង្ហាញជូនរបាយការណ៍ និន្នាការពលកម្មនិងសង្គមកម្ពុជា ឆ្នាំ ២០១០នេះដែលវាឆ្លុះបញ្ចាំងផងដែរ ពីការសហការរវាង ILO និងរាជរដ្ឋាភិបាលកម្ពុជានៅក្នុងការជួយដល់ការ សំរេចបាននូវគោលការណ៍នៃការងារសមរម្យរបស់កម្មករនៅក្នុងប្រទេស ។



Bill Salter
នាយក
ក្រុមការងារសមរម្យរបស់ ILO សម្រាប់ អាស៊ី និងបាស៊ីភិចខាងកើតនិងខាងត្បូង

បាងកក
ខែ កក្កដា ឆ្នាំ ២០១០

# មាតិកា


បុព្វកថា......................................................................................... i
អារម្ភកថា......................................................................................... iii-v
ពាក្យបំប្រួញ......................................................................................... x
សង្ខេបរួម......................................................................................... xiii

ជំពូក ១ សេចក្តីផ្តើម ១
១.១ សារតារ......................................................................................... ១
១.២ កម្មវត្ថុនៃរបាយការណ៍......................................................................................... ២
១.៣ រចនាសម្ព័ន្ធនៃរបាយការណ៍......................................................................................... ២
១.៤ ប្រភពទិន្នន័យ......................................................................................... ៣
១.៥ ភាពមានព្រំដែននៃរបាយការណ៍........................................................................................... ៤

ជំពូក ២ ចរឹតលក្ខណៈប្រជាសាស្ត្រ......................................................................................... ៥
២.១ កំណើនប្រជារាស្ត្រ......................................................................................... ៥
២.២ ទំហំ និងសមាសភាគប្រជារាស្ត្រ......................................................................................... ៦
២.៣ អក្ខរភាព និងការអប់រំ......................................................................................... ៩
២.៤ អត្រាចំណោលប្រជាជន......................................................................................... ១៣
២.៥ កំណត់សំគាល់សង្ខេប......................................................................................... ១៣

ជំពូក ៣ និន្នាការទីផ្សារការងារ និងសេដ្ឋកិច្ចសង្គម......................................................................................... ១៥
៣.១ និន្នាការសេដ្ឋកិច្ចសង្គម......................................................................................... ១៥
៣.១.១ ផលិតផលក្នុងស្រុកសរុប......................................................................................... ១៥
៣.១.២ ពាណិជ្ជកម្ម និង ការវិនិយោគផ្ទាល់ពីបរទេស......................................................................................... ១៨
៣.១.៣ អតិផរណា និងការចំណាយប្រើប្រាស់......................................................................................... ១៩
៣.១.៤ ភាពក្រីក្រ និងវិសមភាព......................................................................................... ២១
៣. និន្នាការទីផ្សារការងារ......................................................................................... ២៣

២
៣.២.១ កម្លាំងពលកម្ម.......................................................................... ២៣
៣.២.២ ការងារ.......................................................................... ២៤
៣.២.៣ បំលាស់ប្តូរលំនៅដ្ឋាន ដើម្បីការងារក្នុងស្រុក និងក្រៅស្រុក...................... ៣០
៣.២.៤ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអភិវឌ្ឍន៍ជំនាញ និងតំរូវការទីផ្សារការងារ.... ៣៣
៣.២.៥ ផលិតភាពការងារ.......................................................................... ៣៦
៣.២.៦ ការគាំពារសង្គម.......................................................................... ៣៨
៣.២.៧ សុខភាព និងសុវត្ថិភាពការងារ.................................................... ៤០
៣.២.៨ កុមារធ្វើការ.......................................................................... ៤៤
៣.២.៩ ទំនាក់ទំនងវិជ្ជាជីវៈ ដំណោះស្រាយវិវាទ និងអនុសញ្ញារួម...................... ៤៥
៣.៣ សេចក្តីសន្និដ្ឋាន.......................................................................... ៤៩

ជំពូក ៤ ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលលោក លើទីផ្សារការងារ ជាពិសេសវិស័យកាត់ដេរ... ៥១
៤.១ ផលប៉ះពាល់លើសេដ្ឋកិច្ច និងទីផ្សារការងារ.................................................... ៥១
៤.២ ការឆ្លើយតបទៅនឹងវិបត្តិ.......................................................................... ៥៦
៤.៣ សេចក្តីសន្និដ្ឋាន.......................................................................... ៥៨

ជំពូក ៥ បញ្ហាទីផ្សារការងារក្នុងទសវត្សរ៍ការងារសមរម្យនៅអាស៊ី ឆ្នាំ ២០០៦-២០១៥............. ៥៩
៥.១ យុទ្ធសាស្ត្រចតុកោណ.......................................................................... ៥៩
៥.២ គោលនយោបាយ និងកម្មវិធីសម្រាប់ពង្រីកឱកាសការងារសមរម្យ.......................... ៦១
៥.៣ បញ្ហាប្រឈម.......................................................................... ៦១
៥.៣.១ បញ្ហាប្រឈមនៃការសម្រេចបាននូវផលិតភាពពេញលេញ និងការងារសមរម្យសម្រាប់ទាំងអស់គ្នា....................................... ៦៥
៥.៣.២ ការគាំពារសង្គម ដើម្បីប្រយុទ្ធនឹងភាពងាយរងគ្រោះ............................ ៦៥
៥.៣.៣ សមភាពខាងយេនឌ័រ.......................................................................... ៦៥
៥.៣. ទំនាក់ទំនងវិជ្ជាជីវៈ.......................................................................... ៦៦

| | | |
|---|---|---|
| ៥.៣.៤ | | |
| ៥.៣.៥ | ស្ថិតិទីផ្សារការងារទាន់ពេលវេលា............................................ | ៦៧ |
| ៥.៤ | គោលនយោបាយ.......................................................................... | ៦៨ |
| ៥.៤.១ | យុទ្ធសាស្រ្ត និងគោលនយោបាយជាតិស្តីពីការងារដែលមានលក្ខណៈយេនឌ័រ | ៦៨ |
| ៥.៤.២ | យុទ្ធសាស្រ្តគាំពារសង្គម....................................................... | ៦៩ |
| ៥.៤.៣ | បរិយាកាសសម្រាប់ទំនាក់ទំនងវិជ្ជាជីវៈ.................................. .............. | ៧០ |
| ៥.៥ | សេចក្តីសន្និដ្ឋាន......................................................................... ...................... | ៧១ |
| | តារាងឧបសម្ព័ន្ធ-ស្ថិតិ........................................................................................ | ៧៣ |
| | ឯកសារយោង.................................................................................... ............... | ១០០ |

## តារាង

| | | |
|---|---|---|
| តារាង ២.១ | អត្រាកំណើនប្រជារាស្ត្រ ឆ្នាំ ១៩៩៨-២០០៨............................................... | ៥ |
| តារាង ២.២ | ប្រជាជនរបស់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ...................................................... | ៦ |
| តារាង ២.៣ | ប្រជារាស្ត្រតាមក្រុមអាយុ និងភេទ ឆ្នាំ ១៩៩៨-២០០៨ ........................................... | ៧ |
| តារាង ២.៤ | អត្រាលទ្ធភាពបង្កើតកូនរបស់ស្ត្រី ឆ្នាំ ១៩៩៨ និង ២០០៨......................................... | ៧ |
| តារាង ២.៥ | ផលធៀបអាយុក្នុងបន្ទុកឆ្នាំ១៩៩៨ និង ២០០៨ (%) ............................................... | ៩ |
| តារាង ២.៦ | អត្រាអក្ខរភាពឆ្នាំ ១៩៩៨ និង ២០០៨............................................................. | ១០ |
| តារាង ២.៧ | កំរិតសិក្សាដែលបានបញ្ចប់ដោយប្រជារាស្ត្រ អាយុ ៧ ឆ្នាំឡើង ឆ្នាំ ១៩៩៨ និង ២០០៨...... | ១២ |
| តារាង ៣.១ | អត្រាកំណើន GDP តាមការចំណាយតាមថ្លៃស្ថេរឆ្នាំ ២០០០ ឆ្នាំ ២០០១-២០០៧ (%)... | ១៦ |
| តារាង ៣.២ | GDP សម្រាប់មនុស្សម្នាក់ៗ តាមថ្លៃស្ថេរឆ្នាំ ២០០០ ឆ្នាំ ២០០២-២០០៨...................... | ១៦ |
| តារាង ៣.៣ | ពាណិជ្ជកម្មតាមថ្លៃថេរ ឆ្នាំ ២០០០ | ១៨ |

| | | |
|---|---|---|
| | (គិតជាពាន់រៀលដុល្លារ)................................ | |
| តារាង ៣.៤ | ការប៉ាន់ស្មានភាពក្រីក្រតាមតំបន់........................................................... | ២២ |
| តារាង ៣.៥ | មេគុណ Gini នៃវិសមភាពការចំណាយរបស់មនុស្សម្នាក់តាមតំបន់.......................... | ២២ |
| តារាង ៣.៦ | អត្រាកំណើនការងារ................................................................................ | ២៤ |
| តារាង ៣.៧ | ការងារតាមវិស័យ អាយុ និងភេទ............................................................. | ២៧ |
| តារាង ៣.៨ | អត្រាគ្មានការងារធ្វើ........................................................................... | ២៨ |
| តារាង ៣.៩ | កម្មករផ្លាស់ប្តូរលំនៅដ្ឋានដើម្បីការងារ(%).................................................. | ៣១ |
| តារាង ៣.១០ | ចំនួនពលករកម្ពុជាទៅធ្វើការនៅឯបរទេសតាមប្រទេស.................................. | ៣២ |
| តារាង ៣.១១ | ចំនួនពលករកម្ពុជាទៅធ្វើការក្រៅប្រទេសតាមវិស័យ.......................................... | ៣៣ |
| តារាង ៣.១២ | សិស្ស-និស្សិតចូលរួមវគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ........................... | ៣៥ |
| តារាង ៣.១៣ | តំរូវការពលកម្មតាមរយៈគំរោងវិនិយោគ តាមវិស័យ ឆ្នាំ ២០០៨.................................. | ៣៦ |
| តារាង ៣.១៤ | ផលិតភាពការងារតាមវិស័យ(តំលៃបន្ថែមសម្រាប់អ្នកធ្វើការម្នាក់តាមថ្លៃថេរ ឆ្នាំ ២០០០).. | ៣៧ |
| តារាង ៣.១៥ | កម្មករដែលបានពិនិត្យកាយសម្បទា............................................................ | ៤១ |
| តារាង ៣.១៦ | របាយការណ៍គ្រោះថ្នាក់ការងារ.................................................................. | ៤១ |
| តារាង ៣.១៧ | សមាមាត្រនៃកុមារធ្វើការអាយុ ៥-១៧ ឆ្នាំ តាមប្រភេទ........................................... | ៤៥ |
| តារាង ៣.១៨ | ការចុះបញ្ជីសហជីព.............................................................................. | ៤៦ |
| តារាង ៣.១៩ | វិវាទការងារ........................................................................................ | ៤៧ |
| តារាង ៣.២០ | ភាពជាតំណាងបំផុត (MRS)........................................................................ | ៤៧ |
| តារាង ៣.២១ | កិច្ចព្រមព្រៀងអនុសញ្ញារួម....................................................................... | ៤៨ |
| តារាង ៤.១ | អត្រាកំណើននៃផលិតផលក្នុងស្រុកសរុបពិត | ៥២ |

| | | |
|---|---|---|
| តារាង ៤.២ | និងវិស័យកាត់ដេរ................................ ការនាំចូលសំលៀកបំពាក់របស់សហរដ្ឋអាមេរិក តាមប្រទេស (គិតជាលានដុល្លារអាមេរិក) | ៥៤ |


## រូប


| | | |
|---|---|---|
| រូប ២.១ | ពីរ៉ាមីតប្រជាពលរដ្ឋកម្ពុជានៅ ឆ្នាំ ២០០៨.............................................................. | ៨ |
| រូប ២.១ | ចំណោលប្រជាពលរដ្ឋឆ្នាំ ២០០៩ - ២០១៥................................................................ | ១៣ |
| រូប ៣.១ | ការរួមចំណែកក្នុង GDP តាមថ្លៃថេរឆ្នាំ ២០០០ ឆ្នាំ ២០០១- ២០០៨(%)........................ | ១៨ |
| រូប ៣.២ | លំហូរការវិនិយោគផ្ទាល់ពីបរទេស (គិតជាលានដុល្លារអាមេរិក)...................................... | ១៩ |
| រូប ៣.៣ | អតិផរណា (សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ភ្នំពេញ ខែ កក្កដា ដល់ខែ ធ្នូ ២០០០=១០០) | ២០ |
| រូប ៣.៤ | ចំណាយសម្រាប់ការប្រើប្រាស់ចុងក្រោយតាមថ្លៃថេរឆ្នាំ ២០០០ (គិតជាពាន់លានរៀល)...... | ២០ |
| រូប ៣.៥ | អត្រាចូលរួមកម្លាំងពលកម្មសម្រាប់ប្រជាពលរដ្ឋអាយុ ១៥ ឆ្នាំឡើង (%).......................... | ២៣ |
| រូប ៣.៦ | អត្រាមានការងារធ្វើធៀបនឹងប្រជាពលរដ្ឋសម្រាប់កម្មករអាយុ ១៥ ឆ្នាំឡើង(%).................. | ២៤ |
| រូប ៣.៧ | សមាមាត្រការងារងាយរងគ្រោះធៀប និងការងារទូទៅ............................................. | ៣០ |
| រូប ៣.៨ | ទិន្នផលសម្រាប់អ្នកធ្វើការម្នាក់សម្រាប់ប្រទេសក្នុងអាស៊ាននៅឆ្នាំ ២០០៨....................... | ៣៨ |
| រូប ៥.១ | យុទ្ធសាស្ត្រចតុកោណ........................................................................................ | ៦០ |


## ប្រអប់


| | | |
|---|---|---|
| ប្រអប់ ១ | ស្ត្រីមានការរីកចំរើនក្នុងការអប់រំ ប៉ុន្តែនៅតែមានគំលាតយេនឌ័រ.......................... | ២៦ |
| ប្រអប់ ២ | វិធានការដើម្បីកែលម្អការងាររបស់យុវជន............................................................ | ២៩ |
| ប្រអប់ ៣ | យុទ្ធសាស្ត្រដើម្បីបង្កើនការងារនៅក្រៅប្រទេសសម្រាប់ប្រជាពលរដ្ឋកម្ពុជា........................ | ៣២ |

| | | |
|---|---|---|
| ប្រអប់ ៤ | គណៈកម្មការជាតិបណ្តុះបណ្តាលដើម្បីធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពបណ្តុះបណ្តាល........................................................................... | ៣៥ |
| ប្រអប់ ៥ | ប្រព័ន្ធអភិវឌ្ឍន៍ដើម្បីកែលម្អបាយការណ៍គ្រោះថ្នាក់នៅកន្លែងធ្វើការ....................... | ៤២ |
| ប្រអប់ ៦ | ការសិក្សារបស់អង្គការ ILO អំពីវិស័យកាត់ដេរឲ្យដឹងពីការលំបាកថ្មី និងយន្តការដោះស្រាយ............................................................................................ | ៥៥ |

# ពាក្យបំប្រួញ

| | |
|---|---|
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CBA | អនុសញ្ញារួម |
| CBHI | ការធានារ៉ាប់រងផ្នែកសុខភាពក្នុងសហគមន៍ |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDHS | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| DLD | នាយកដ្ឋានវិវាទការងារ |
| DWCP | កម្មវិធីការងារសមរម្យសម្រាប់ប្រទេស |
| FCE | ការចំណាយប្រើប្រាស់ចុងក្រោយ |
| FDI | ការវិនិយោគផ្ទាល់ពីបរទេស |
| GMAC | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| GTZ | សហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| HIV and AIDS | មេរោគហ៊ីវ និងជម្ងឺអេដស៍ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IOM | អង្គការអន្តរជាតិទទួលបន្ទុកទេសន្តប្រវេសន៍ |
| MOLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MOP | ក្រសួងផែនការ |
| MRS | ភាពជាតំណាងបំផុត |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NPRS | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NSPS | យុទ្ធសាស្ត្រជាតិគាំពារសង្គម |
| NSSF | បេឡាជាតិរបបសន្តិសុខសង្គម |
| NTB | គណៈកម្មាធិការជាតិបណ្តុះបណ្តាល |
| OSH | សុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ |
| SESC | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |
| SIDA | ភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត |
| TVET | វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UN | អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍន៍ |

# សង្ខេបរួម

របាយការណ៍នេះ ផ្តល់នូវការវិភាគប្រៀបធៀប ដែលទិន្នន័យភាគច្រើនបានពីជំរឿនប្រជាជនឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៨ ក៏ដូចជាប្រភពដទៃទៀត ដើម្បីបង្ហាញពីនិន្នាការសេដ្ឋកិច្ច សង្គមកិច្ច និងទីផ្សារការងារនៅកម្ពុជាក្នុងទសវត្សរ៍កន្លងមក ។ ម៉្យាងទៀតរបាយការណ៍គ្របដណ្តប់គោលនយោបាយ ដែល ទាក់ទងនឹងនិន្នាការ ដើម្បីសម្រេចបាននូវគោលការណ៍ ការងារសមរម្យសម្រាប់ប្រទេស ជាពិសេសជាមួយក្រុមងាយរងគ្រោះ ។

ជារួម ការងារមួយចំនួនបានទទួលលទ្ធផលល្អជាវិជ្ជមាន ។ ប្រទេសកម្ពុជាមានការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងកំណើនសេដ្ឋកិច្ចក្នុងទសវត្សរ៍កន្លងមក និងកម្រិតភាពក្រីក្រត្រូវបានកាត់បន្ថយ ។ ប៉ុន្តែ នៅមានបញ្ហាប្រឈមគួរយកចិត្តទុកដាក់ រួមទាំងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើកម្មករ ។ ម៉្យាងទៀត មានប្រមាណ ៣០ ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ។

## និន្នាការសេដ្ឋកិច្ច សង្គមកិច្ច និងទីផ្សារការងារ

ក្នុងការផ្លាស់ប្តូរ ពីផែនការប្រមូលផ្តុំមកសេដ្ឋកិច្ចទីផ្សារ សេដ្ឋកិច្ចកម្ពុជាមានការប្រែប្រួលក្នុងពីរ ទសវត្សរ៍កន្លងមកនេះ ។ បញ្ហាប្រឈមនៃការអភិវឌ្ឍន៍បច្ចុប្បន្នមានដូចជា និរន្តរភាពនៃកំណើន ការកាត់បន្ថយភាពក្រីក្រ ការរក្សាតុល្យភាពនៃសមភាព និងការបង្កើនល្បឿនកែទម្រង់ ។

មុនវិបត្តិសេដ្ឋកិច្ចសកលលោក សេដ្ឋកិច្ចកម្ពុជា បានកើនឡើងគួរឲ្យកត់សម្គាល់ ដែលផលិតផល ក្នុងស្រុកសរុបពិត (GDP) កើនឡើងដល់ ១៣,៣ ភាគរយនៅឆ្នាំ ២០០៥ ។ ទោះបីសេដ្ឋកិច្ចសកលលោក ធ្លាក់ចុះក៏ដោយ ក៏សេដ្ឋកិច្ចបន្តកើនឡើងប្រមាណ ៦,៧ ភាគរយនៅឆ្នាំ ២០០៨ ។ ប៉ុន្តែកំណើននៅឆ្នាំ ២០០៩ ធ្លាក់ចុះដោយសារឥទ្ធិពលបន្តនៃវិបត្តិសេដ្ឋកិច្ចសកលលោក ។ ការវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជាថយចុះបន្តិច ពី ៨៦៧ លានដុល្លារអាមេរិកនៅឆ្នាំ ២០០៧ មក ៨១៥ លានដុល្លារអាមេរិកនៅឆ្នាំ ២០០៨ ។ ភាគច្រើននៃការវិនិយោគផ្ទាល់ពីបរទេស គឺមកពីសាធារណរដ្ឋកូរ៉េ និងម៉ាឡេស៊ី ដែលផ្តោតទៅ លើសហគ្រាសទូរគមនាគមន៍ និងកាត់ដេរ និងបន្ទាប់មកធនាគារពាណិជ្ជ ។

អតិផរណា (១៩,៧ ភាគរយ) បានកើនឡើងនៅឆ្នាំ ២០០៨ ជាចម្បងដោយសារការកើនឡើងនៃ តម្លៃម្ហូបអាហារ ។ ការចំណាយប្រើប្រាស់ចុងក្រោយតាមថ្លៃថេរឆ្នាំ ២០០០ បានកើនឡើង ៩,៣ ភាគរយ និងចំណែកសមាមាត្រនៃ GDP មាន ៨៣,៧ ភាគរយនៅឆ្នាំ ២០០៧ ។

ប្រទេសកម្ពុជាមានអត្រាកំណើនប្រជាជនប្រចាំឆ្នាំជាមធ្យម ១,៥ ភាគរយក្នុងរយៈពេលទសវត្សរ៍ កន្លងមកដែលបង្កើនបាននូវប្រជាជន "យុវវ័យ" បន្ថែមទៀត ។ ប្រមាណមួយភាគបីនៃ ប្រជាជនសរុប ១៣,៤ លាននាក់តាមជំរឿនឆ្នាំ

២០០៨ មានអាយុ ១៥ ឆ្នាំ ឬក្មេងជាង ។ អត្រាលទ្ធភាពបង្កើតកូនថយចុះប្រហែលមកពីការកើនឡើងនៃការសិក្សាអប់រំក្នុងចំណោមប្រជាជនទាំងមូល ជាពិសេសស្ត្រី ។ អត្រាអ្នក នៅក្នុងបន្ទុកតាមអាយុបានថយចុះ ។

ការកើនឡើងខ្លាំងនៃអក្ខរភាពរវាងឆ្នាំ ១៩៩៨ និង ២០០៨ មានកំណើននៃអត្រារបស់ស្ត្រី ច្រើនជាង អត្រារបស់បុរស ។ ទោះបីជាយ៉ាងណាក៏ដោយចំនួនច្រើននៃប្រជាជននោះ (៥៨,៩ ភាគរយ) មិនបានបញ្ចប់កម្រិតបឋមសិក្សានៅឆ្នាំ ២០០៨ ។ បច្ចុប្បន្នប្រជាជនដល់អាយុធ្វើការដ៏ច្រើនជាអក្ខរជនបើធៀប នឹងដប់ឆ្នាំមុន ។ ប៉ុន្តែវិសមភាពខាងយេនឌ័រនៅតែមានចោទដោយសារអក្ខរជនមានការងារធ្វើជាបុរស (៨២,៧ ភាគរយ) ច្រើនជាង ស្ត្រី (៦៩,១ ភាគរយ) នៅឆ្នាំ ២០០៨ ។

ចំណោលប្រជាជននឹងកើនឡើងរហូតដល់ឆ្នាំ ២០១៥ ដែលមានអត្រាមធ្យម ១,៣ ភាគរយក្នុង មួយឆ្នាំ ខណៈដែលប្រជាជនដល់អាយុធ្វើការ (អាយុ ២៥-៥៤ ឆ្នាំ) នឹងកើនឡើងខ្ពស់តាមអត្រាប្រចាំឆ្នាំ ជាមធ្យម ៣ ភាគរយ ។ ទាំងនេះអាចនាំមកនូវផលប្រយោជន៍ដល់ប្រទេស បើមានជម្រើសគោល នយោបាយត្រឹមត្រូវ ។ នៅពេលដូចគ្នានេះ វាបង្កើតបញ្ហាប្រឈមមួយចំនួនដល់ការបង្កើតការងារដោយសារការកើនឡើងនៃកម្លាំងពលកម្ម ។

កម្លាំងពលកម្មរបស់ប្រទេស (អាយុ ១៥ ឆ្នាំឡើង) ក៏មានការប្រែប្រួលក្នុងទសវត្សរ៍កន្លងមក ហើយបានកើនឡើងជាមធ្យមក្នុងមួយឆ្នាំ ៣,៣ ភាគរយ មានប្រមាណ ៧ លាននាក់នៅឆ្នាំ ២០០៨ ។ អត្រាចូលរួមកម្លាំងពលកម្មវ័យក្មេងបានថយចុះបន្តិច ដែលឆ្លុះបញ្ចាំងនិន្នាការ ជាវិជ្ជមានរបស់យុវជនស្ថិតនៅបានយូរក្នុងប្រព័ន្ធអប់រំ ។ ជាទូទៅ ស្ត្រីវ័យក្មេងហាក់ដូចជាចូល និងចេញពីកម្លាំងពលកម្មមុន អាយុជាងបុរសវ័យក្មេង ។ អត្រាសកម្មភាពសេដ្ឋកិច្ចរបស់ស្ត្រី នៅតែខ្ពស់បន្តិចជាងបុរសក្នុងទសវត្សរ៍ កន្លងមក ទោះបីមានគម្លាតតិចខាង យេនឌ័រក្នុងអត្រាចូលរួមកម្លាំងពលកម្មពីឆ្នាំ ១៩៩៨ ទៅឆ្នាំ ២០០៨ ក៏ដោយ ។

នៅឆ្នាំ ២០០៨ ប្រជាជន ៦,៨ លាននាក់មានអាយុ ១៥ ឆ្នាំឡើង មានការងារធ្វើដែលឆ្លុះបញ្ចាំងពី កំណើនអ្នកមានការងារធ្វើក្នុងទសវត្សរ៍ ៤៣,៣ ភាគរយ ឬកំណើនជាមធ្យមប្រចាំឆ្នាំ ៣,៦ ភាគរយតាំង ពីឆ្នាំ ១៩៩៨ ។ ផលធៀបអ្នកមានការងារធ្វើទៅនឹងប្រជាជនមាន ៧៧ ភាគរយជាមួយនឹងផលធៀបសម្រាប់យុវជនកើនឡើងដល់ ៥៨ ភាគរយនៅឆ្នាំ ២០០៨ ។

ទោះបី អត្រាអ្នកគ្មានការងារធ្វើនៅទាប និងថយចុះក្នុងទសវត្សរ៍ក៏ដោយ ក៏ផ្នែកដ៏ធំនៃកម្មករ (៨២,៥ ភាគរយ) បន្តការងារមានភាពងាយរងគ្រោះ ដែលកំណត់ដោយអ្នកធ្វើការឲ្យគ្រួសារដោយមិន យកប្រាក់ឈ្នួល និងអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន ។

ពីឆ្នាំ ២០០៤ ទៅឆ្នាំ ២០០៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានពង្រីកសកម្មភាព ដើម្បីអភិវឌ្ឍន៍ឆ្ពោះទៅជម្រើសការងារទាំងក្នុងស្រុក និងបរទេស ។ ចំពោះបញ្ហានេះ ប្រជាជនកម្ពុជា ដែលធ្វើការនៅក្រៅប្រទេសបានកើនឡើងតាមរយៈបណ្តាញផ្លូវការក្នុងប្រទេសម៉ាឡេស៊ី សាធារណរដ្ឋកូរ៉េ ថៃ និងជប៉ុន ។ ភាគច្រើននៃពួកគេ ត្រូវបានផ្តល់ការងារក្នុងវិស័យឧស្សាហកម្ម បន្ទាប់មកការងារក្នុងផ្ទះ និងវិស័យកសិកម្ម ។ នៅដើមឆ្នាំ ២០០៤ ស្ត្រីមានចំនួនច្រើនជាងបុរសទៅធ្វើការនៅក្រៅប្រទេស ។

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតស្ថាប័ន ដើម្បីអភិវឌ្ឍន៍ជំនាញរបស់កម្មករ ប៉ុន្តែបញ្ហាប្រឈមនៅ តែមានគួរឲ្យកត់សម្គាល់ ។ យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា ចំនួនអ្នកបញ្ចប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកើនឡើងពី ៨៨.៣៦៧ នាក់នៅឆ្នាំ ២០០៧ ទៅ ១១៣.៦៤៨ នាក់នៅឆ្នាំ ២០០៨ ។

ជាសរុប ផលិតភាពការងារមានតម្លៃប្រមាណ ៤,១៩ លានរៀល (១.០៣០ ដុល្លារអាមេរិក) នៅឆ្នាំ ២០០៨ ។ ការប្រែប្រួលប្រចាំឆ្នាំជាមធ្យមខ្ពស់ជាងគេនៃផលិតភាពការងាររវាងឆ្នាំ ១៩៩៨ និង ២០០៨ គឺ ផ្នែករុករករ៉ែ និងថ្ម (១៩,៤ ភាគរយ) បន្ទាប់មកផ្នែកហិរញ្ញវត្ថុ និងសេវាកម្មដទៃទៀត (៨,៦ ភាគរយ) ។ កំណើនប្រចាំឆ្នាំជាមធ្យមនៃផលិតភាពការងារក្នុងវិស័យកសិកម្ម ក្នុងរយៈពេលដូចគ្នាបានកើនឡើងយឺត មាន ១,៧ ភាគរយ ក៏ដូចជាផ្នែកពាណិជ្ជកម្មមាន ១ ភាគរយ ។ កម្រិតផលិតភាពការងារនៅកម្ពុជានៅទាបជាងបណ្តាប្រទេសជិតខាងក្នុងអាស៊ាន ។

វិបត្តិសេដ្ឋកិច្ច និងការឡើងថ្លៃនៃម្ហូបអាហារ បាននាំមកនូវបញ្ហាមួយចំនួនដល់ភាពក្រីក្រ និងផល ប៉ះពាល់ដល់ការជួយសង្គម និងការគាំពារសង្គមដែលជាកត្តាសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ។

ការគាំពារសង្គមបច្ចុប្បន្ននៅកម្ពុជា រួមមាន i) បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់និយោជិក ផ្នែកឯកជន ដែលផ្តល់ការធានារ៉ាប់រងខាងគ្រោះថ្នាក់ការងារ ii) បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ មន្ត្រីរាជការស៊ីវិល ដែលផ្តល់អត្ថប្រយោជន៍ខាងសោធននិវត្តន៍ iii) កម្មវិធីគាំពារ សុខភាពសង្គមផ្សេងៗ ដែលសំដៅទៅលើកម្មករក្រីក្រ និងធ្វើក្នុងសេដ្ឋកិច្ចមិនរៀបរយ ដូចជាមូលនិធិសមធម៌ផ្នែកសុខភាព និង គម្រោងការធានារ៉ាប់រងផ្នែកសុខភាពក្នុងសហគមន៍ iv) កម្មវិធីសំណាញ់សុវត្ថិភាពសង្គមផ្សេង ៗ (ឬ ជំនួយសង្គម) សំដៅលើអ្នកក្រីក្រ និងមានភាពងាយរងគ្រោះ ។ ពួកគាត់ ត្រូវបានផ្តល់ហិរញ្ញប្បទានមួយចំនួនធំដោយម្ចាស់ជំនួយ ។

បច្ចុប្បន្ន ស្ថិតិអំពីគ្រោះថ្នាក់នៅកន្លែងធ្វើការបានបង្ហាញថា ប្រជាជនមួយចំនួនធំដែលជួបគ្រោះ ថ្នាក់ គឺជាកម្មការិនីក្នុងឧស្សាហកម្មកាត់ដេរ ។ រាជរដ្ឋាភិបាលបានកំណត់គោលនយោបាយដើម្បីកែលម្អ សុខភាពនិងសុវត្ថិភាពនៅកន្លែងធ្វើការរបស់កម្មករ រួមទាំងគោលនយោបាយនិងកម្មវិធីនៅកន្លែងធ្វើការ ខាងមេរោគហ៊ីវ និងរាយការណ៍អំពីគ្រោះថ្នាក់ និងរបួស ។ ផែនការមេអំពីសុខភាព និងសុវត្ថិភាពនៅ កន្លែងធ្វើការនៅកម្ពុជាលើកទីមួយត្រូវបានប្រកាសនៅឆ្នាំ ២០០៩ ។

ទាក់ទងនឹងកុមារធ្វើការងារ យោងតាមជំរឿនប្រជាជនឆ្នាំ ២០០៨ ចំនួន ៩,៧ ភាគរយនៃកុមារ ទាំងអស់ធ្វើការយ៉ាងហោចណាស់ប្រាំមួយខែឬច្រើនជាងក្នុងរយៈពេលមុនធ្វើជំរឿន ។ ក្នុងនោះចំនួន កុមារាមានច្រើនជាងបន្តិចពីកុមារី ។ សមាមាត្រពលកម្មកុមារក្នុងវិស័យកសិកម្មបានថយចុះក្នុងទសវត្សរ៍ កន្លងមកខណៈដែលសមាមាត្រធ្វើការក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មបានកើនឡើង ។ ភាគច្រើននៃ កុមារមានការងារធ្វើ បានបញ្ចប់កម្រិតបឋមសិក្សា ។ ប្រមាណតែ ៤,៦ ភាគរយនៃអ្នកទាំងនោះ បាន បញ្ចប់កម្រិតអនុវិទ្យាល័យ ។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានចាប់ផ្តើមរៀបចំគោលនយោ បាយសំដៅលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ បន្ថយពលកម្មកុមារ និងឧប្បត្តិហេតុនៃការ ជួញដូរកុមារ និងស្ត្រី ។

ប្រព័ន្ធទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជានៅក្មេងខ្ចីនៅឡើយ ជាមួយនឹងសហជីពដែលចាប់មាននៅពាក់ កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ មុនការអនុមតិច្បាប់ការងារឆ្នាំ ១៩៩៧ សំដៅដល់ការធានារ៉ាប់រងដល់សិទ្ធិនិយោជិតផ្នែកឯកជនចូលរួមក្នុងសហជីព និងកូដកម្ម ។ បច្ចុប្បន្នមាន ៨២ សហព័ន្ធសហជីព (និង ៥ សហភាពសហព័ន្ធសហជីព) នៅតាមវិស័យផ្សេង ៗ នៃសេដ្ឋកិច្ច និង ២៨ សហព័ន្ធសហជីពនៅក្នុង វិស័យកាត់ដេរ ។

ទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជា ត្រូវបានសម្គាល់ដោយកូដកម្ម និងវិវាទជាពិសេសក្នុងវិស័យ កាត់ដេរ ។ ទោះជាយ៉ាងណាក៏ដោយ និយោជិតនិងនិយោជកមិនមានបទពិសោធន៍ ឬឧបករណ៍ចាំបាច់ក្នុង ការស្រាយវិវាទឡើយមុននឹងជ្រើសយកកូដកម្ម ។ ក៏ប៉ុន្តែ បន្តិចម្តងៗត្រូវបានផ្លាស់ប្តូរដោយសារការយល់ដឹងច្បាប់ច្រើន និងមានការអភិវឌ្ឍន៍យន្តការសម្រុះសម្រួល អាជ្ញាកណ្តាលនិងអនុសញ្ញារួម ។ ទោះបីចំនួន អនុសញ្ញារួមទាំងអស់ពុំមានក៏ដោយក៏បច្ចុប្បន្នចំនួនអនុសញ្ញារួម ដែលចុះហត្ថលេខាហើយ មានប្រមាណ ២៤៦ ។ ច្បាប់ការងារនិងបទប្បញ្ញត្តិនៅកម្ពុជាជួយដល់ទស្សនៈនៃភាពជាតំណាងបំផុតសម្រាប់សហ ជីព ។ បទប្បញ្ញត្តិថ្មីមួយចេញនៅឆ្នាំ ២០០៨ បានជួយសម្រួលដល់ការបញ្ជាក់ភាពជាតំណាងបំផុតរបស់ សហជីពដោយក្រសួងការងារ

និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាលទ្ធផលមាន ៩០០ ភាគរយ បញ្ជាក់ថ្មី កើនពីជាងមុន និងមាន ២០២ ភាពជាតំណាងបំផុត ដែលបានបញ្ជាក់ដោយលិខិត ។

ជាទូទៅ និន្នាការគួរកត់សម្គាល់ក្នុងទសវត្សរ៍កន្លងមកក្នុងទីផ្សារការងារនៅកម្ពុជា ដែលកើនឡើង បានកាត់បន្ថយអត្រាភាពក្រីក្រ ប៉ុន្តែនៅតែខ្ពស់ ទោះបីអត្រាអ្នកគ្មានការងារធ្វើធ្លាក់ចុះទាបក៏ដោយ ។ ទាំងនេះមានទំនាក់ទំនងទៅនឹងគុណភាពការងារ ជាពិសេសសមាមាត្រដ៏ធំនៃកម្មករក្នុងការងារមានភាព ងាយរងគ្រោះ ។ និន្នាការចំណោលប្រជាជន បង្ហាញបានពីកំណើនប្រជាជនដល់អាយុធ្វើការ អាចបន្ថែមបញ្ហាប្រឈមដល់ឱកាសការងារសមរម្យ នៅពេលដែលមានការកើនឡើងនៃកម្លាំងពលកម្ម ។ ទោះបីការ ចូលរួមក្នុងកម្លាំងពលកម្មមានគម្លាតខាងយេនឌ័រថយចុះក៏ដោយ ក៏អត្រាអ្នកគ្មានការងារធ្វើជាស្ត្រីខ្ពស់ ជាងបុរស ហើយមានសមាមាត្រធំចំពោះកម្មការិនីដែលមិនចេះអក្សរ ។

## ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលលោកលើទីផ្សារការងារ

ការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃសកម្មភាពសេដ្ឋកិច្ចសកលលោក ដែលចាប់ផ្តើមនៅឆ្នាំ ២០០៨ រហូតដល់ឆ្នាំ ២០០៩ បានជះឥទ្ធិពលដល់ប្រទេសកម្ពុជាតាមរយៈពាណិជ្ជកម្ម និងវិនិយោគ ជាពិសេសក្នុងវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ។ កំណើនក្នុងវិស័យកាត់ដេរបានថយចុះគួរឲ្យកត់សម្គាល់ពី ១០ ភាគរយនៅឆ្នាំ ២០០៧ មកតែ ២,២ ភាគរយនៅឆ្នាំ ២០០៨ ។ ការបាត់បង់ការងារក្នុងវិស័យនេះ ក៏មានកំរិតគួរយកចិត្តទុកដាក់ផងដែរ ។

ដើម្បីឆ្លើយតបទៅនឹងវិបត្តិនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាប់ផ្តើមបង្កើត មជ្ឈមណ្ឌលការងារតាមតំបន់ ដើម្បីភ្ជាប់ជាមួយកម្មករដែលឈប់ធ្វើការ និងគ្មានការងារធ្វើរយៈពេលវែង ទៅនឹងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការងារថ្មី ។ មជ្ឈមណ្ឌលការងារមុនគេបង្អស់ ត្រូវ បានបង្កើតនៅក្នុងរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលចំនួនពីរទៀតនឹងបង្កើតនៅចុងឆ្នាំ ២០១០ ។

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលលោក លើប្រជាជនងាយរង គ្រោះ និងក្រីក្រ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាច្រើន រួមមានកញ្ចប់សារពើពន្ធ ជំរុញកំណើន និងពង្រឹងការយកចិត្តទុកដាក់លើការគាំទ្រដល់កម្មវិធីសំណាញ់សុវត្ថិភាពសង្គម ។ បច្ចុប្បន្នគោលបំណង របស់រាជរដ្ឋាភិបាល គឺបង្កើតនូវមធ្យាបាយអចិន្ត្រៃយ៍មួយដែលជាកម្មវិធីគាំពារសង្គម ដូចជាគម្រោងការងារសាធារណៈដែលប្រើកម្លាំងពលកម្មច្រើន និងការផ្ទេរសាច់ប្រាក់មានលក្ខខណ្ឌសម្រាប់ប្រជាជន ដែលក្រីក្រ និងងាយរងគ្រោះ ។

ចំពោះគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជា បានឆ្លើយតបដែលរួមមានការ សម្រួលដល់ការអនុវត្តន៍គោលនយោបាយរូបិយវត្ថុ និងវិធានការជាច្រើនទៀត ដើម្បីគាំទ្រ និងពង្រឹងប្រព័ន្ធ ហិរញ្ញវត្ថុ និងធនាគារ ។

ដូច្នេះរាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ក្នុងការដោះស្រាយបញ្ហាប្រឈមតាមវិស័យដូចខាងក្រោម៖

- ធ្វើឲ្យមានទីផ្សារច្រើន សម្រាប់វិស័យកាត់ដេរ និងទំនិញកម្មន្តសាលផ្សេងៗទៀត ដោយស្វះ ស្វែងរកពីអាស៊ីបូព៌ា មជ្ឈឹមបូព៌ា និងអាហ្វ្រិក។
- កែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យទេសចរណ៍ និងអភិវឌ្ឍន៍តំបន់ទេសចរណ៍បន្ថែមទៀត ព្រមទាំងរៀបចំកញ្ចប់ទេសចរណ៍ប្រកបដោយភាពទាក់ទាញ ។
- ផ្តល់អាទិភាពក្នុងការប្រើប្រាស់ធនធាន និងជំនាញរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បី ពង្រីកវិស័យកសិកម្មឲ្យបានច្រើនថែមទៀត ។
- ធ្វើការវិនិយោគបន្ថែមទៀតលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសលើវិស័យថាមពល ដើម្បីកាត់បន្ថយថ្លៃដើមថាមពលសម្រាប់ផ្នែកឯកជន និងសហគមន៍ ។
- បន្តលើកកម្ពស់ និងគាំទ្រដល់ការបង្កើតទ្រព្យធន និងកែលម្អកម្រិតជីវភាពដោយអនុលោមតាម គោលការណ៍ និងនីតិវិធីដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។

## បញ្ហាទីផ្សារការងារក្នុងទសវត្សរ៍ការងារសមរម្យនៅអាស៊ី ឆ្នាំ ២០០៦-២០១៥

កម្មវិធីការងារសមរម្យ (២០០៨-២០១០) ផ្តល់នូវយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាទាក់ទងនឹង បរិមាណ និងគុណភាពការងារនៅកម្ពុជា ។ ការរៀបចំក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋា ភិបាល និងផែនការជាតិអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចដែលផ្តល់នូវមូលដ្ឋានដល់រាជរដ្ឋាភិបាល ដើម្បីកំណត់ គោលនយោបាយឆ្លើយតបរួមមាន៖

- បង្កើនឱកាសការងារ និងផលិតភាពការងារសម្រាប់ស្ត្រី និងបុរស យុវជន និងជនពិការ ជាពិសេសនៅតំបន់ជនបទ
- កែលម្អវិធាននៃច្បាប់ និងពង្រឹងប្រសិទ្ធភាពច្បាប់ការងារ ស្ថាប័នទីផ្សារការងារ និងការអនុវត្តន៍ តាមស្តង់ដារការងារអន្តរជាតិ
- យល់ព្រម និងអនុវត្តគោលនយោបាយ ដើម្បីកែលម្អ និងការពារសិទ្ធិកុមារ ស្ត្រី កម្មករ ទេសន្ត ប្រវេសន៍ និងប្រជាជនម្ចាស់ស្រុក
- បង្កើនវិសាលភាពគាំពារសង្គមសម្រាប់កម្មករ និងកម្មការិនី ក្នុងសេដ្ឋកិច្ចរៀបរយ និងមិន រៀបរយ ។

វិបត្តិសេដ្ឋកិច្ចសកលលោក បានធ្វើឲ្យឃើញច្បាស់អំពីឱកាសការងារ និងសង្គម និងបញ្ហាប្រឈម មួយចំនួនដូចបានបញ្ជាក់ក្នុងរបាយការណ៍នេះ ។ ឆ្លងតាមផលប៉ះពាល់នៃវិបត្តិ បញ្ហាសំខាន់ៗមួយចំនួនក៏ នឹងមានឥទ្ធិពលលើសមិទ្ធិផល និរន្តរភាព និងកំណើនការងារនៅកម្ពុជា៖

- បញ្ហាប្រឈមនៃការសម្រេចបាននូវផលិតភាពការងារពេញលេញ និងការងារសមរម្យសម្រាប់ ទាំងអស់គ្នា
- ការកាត់បន្ថយភាពក្រីក្រតាមរយៈបង្កើនផលិតភាព
- ការអភិវឌ្ឍន៍ជំនាញ និងការអភិវឌ្ឍន៍ធនធានមនុស្ស
- ការគាំពារដើម្បីប្រយុទ្ធនឹងភាពងាយរងគ្រោះ
- សមភាពខាងយេនឌ័រ
- ទំនាក់ទំនងវិជ្ជាជីវៈសុខាភិបាល
- ស្ថិតិទីផ្សារការងារគួរទុកចិត្តបាន និងទាន់ពេលវេលា។

ក្នុងបរិបទនៃបញ្ហាប្រឈមទីផ្សារការងារ គោលនយោបាយសំខាន់តាមផ្នែកគឺ៖

- យុទ្ធសាស្ត្រជាតិស្តីពីការងារដោយយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ
- យុទ្ធសាស្ត្រគាំពារសង្គម
- បរិយាកាសសម្រាប់ទំនាក់ទំនងវិជ្ជាជីវៈ។

## សេចក្តីសន្និដ្ឋាន

នៅពេលដែលប្រទេសកម្ពុជាបន្តរីកចម្រើន និងធ្វើសមាហរណកម្មបន្ថែមទៀតទៅក្នុងសេដ្ឋកិច្ច សកលលោកនោះ ការទទួលបាននូវការងារសមរម្យ និងផលិតភាពការងារ នៅតែជាមធ្យោបាយមួយដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ ទោះបីសម្រេចបានសមិទ្ធផលសំខាន់ៗក៏ដោយ ក៏នៅតែមានបញ្ហា ប្រឈមសម្រាប់ការបង្កើតគោលនយោបាយ សម្រាប់ប្រទេសដើម្បីសម្រេចបាននូវគោលដៅការងារសម រម្យ ។ សមាមាត្រដ៏ធំនៃការងារប្រកបដោយភាពងាយរងគ្រោះ គួរត្រូវបានយកចិត្តទុកដាក់ ។ ប្រជាជន ដល់អាយុធ្វើការនឹងកើនឡើងនៅឆ្នាំខាងមុខ បង្ខំឲ្យទីផ្សារការងារផ្តល់ការងារប្រកបដោយគុណភាព ក៏នឹង ត្រូវកើនឡើងផងដែរ ។ ដើម្បីដោះស្រាយឱនភាពនៃបរិមាណ និងគុណភាពការងារ គោលនយោបាយ សំខាន់ ៗ សម្រាប់បញ្ហាប្រឈមនៅត្រូវបានបង្កើតឡើងនៅកម្ពុជា ។

ទាក់ទងទៅនឹងយេនឌ័រ និងព័ត៌មានទីផ្សារការងារតាមអាយុ ជាបញ្ហាសំខាន់សម្រាប់ធ្វើសេចក្តី សម្រេចចិត្ត និងបង្កើតប្រព័ន្ធព័ត៌មានទីផ្សារការងារប្រកបដោយប្រសិទ្ធភាព ដូចដែលបានរៀបរាប់ក្នុងផែន ការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ ។ ប្រទេសកម្ពុជា បានកសាងប្រព័ន្ធស្ថិតិ ជាតិដ៏រឹងមាំមួយ ។

ជំរឿនតាមពេលកំណត់ និងការអង្កេតសេដ្ឋកិច្ច និងសង្គមកិច្ច បានផ្តល់នូវទិន្នន័យសម្រាប់សូចនាករទីផ្សារការងារ ។ ទិន្នន័យនេះត្រូវបានប្រើប្រាស់សម្រាប់ការវិភាគនិន្នាការការងារ និងសង្គមដែលមាននៅក្នុងរបាយការណ៍នេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ទិន្នន័យអំពីផ្នែកសំខាន់ៗ មួយ ចំនួនដូចជាចំណូល ការងារសេដ្ឋកិច្ចមិនរៀបរយ ភាពគ្មានការងារធ្វើគ្រប់គ្រាន់ ការងារបានចំណូលតិច ម៉ោងធ្វើការ យន្តការផ្លាស់ប្តូរយោបល់ខាងសង្គម ដែលបច្ចុប្បន្នមិនមានឡើយ ។ ជាងនេះទៀត ការខិតខំ ប្រឹងប្រែង តម្រូវឲ្យពឹងផ្អែកលើមូលដ្ឋានព័ត៌មានសម្រាប់ការវិភាគ និងតាមដាននិន្នាការការងារ និងសង្គម ពេញលេញ និងលម្អិត ដែលផ្តល់ការជឿទុកចិត្តជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយទីផ្សារការ ងារ ។ ក្រៅពីនេះត្រូវមានប្រព័ន្ធប្រមូល និងផ្សព្វផ្សាយទិន្នន័យដែលត្រឹមត្រូវមួយ ហើយប្រើទិន្នន័យទាំង នេះសម្រាប់វិភាគ និងជាព័ត៌មានទីផ្សារការងារដ៏មានសារៈប្រយោជន៍ ។

# ជំពូក ១

# សេចក្តីផ្តើម

## ១.១ សារតារ

កម្ពុជា បានទទួលនូវការរីកចំរើនគួរឲ្យកត់សំគាល់នៅក្នុងការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និង នៅក្នុងការកសាងស្ថាប័នជាតិនានារបស់ខ្លួនឡើងវិញ ក្នុងរយៈកាល ២ ទសវត្សកន្លងទៅនេះ ។ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ជាមួយនឹងស្ថេរភាពនយោបាយ និងបរិយាកាសវិនិយោគសេរីមួយ បានផ្តល់វិភាគទានដល់លំហូរចូលនូវការវិនិយោគដែលបានជំរុញការរីកចំរើនផ្នែកសេដ្ឋកិច្ច ។ ប្រការនេះបានលើកស្ទួយជីវភាព ប្រជាជនកម្ពុជាជាច្រើនចាកផុតអំពីភាពក្រីក្រ ។ មានការរីកចំរើនគួរឲ្យកត់សំគាល់ដែលបានទទួល ក្នុងដំណើរឆ្ពោះទៅរកសមិទ្ធផលនៃគោលដៅអភិវឌ្ឍន៍សហវត្ស ។ យ៉ាងណាក្តីក៏នៅមានការលំបាកសាក ល្បងជាច្រើនទៀត ដែលត្រូវប្រឈមនៅឡើយ ។ សមាមាត្រក្នុងកម្រិតគួរឲ្យកត់សំគាល់នៃប្រជាជន នៅតែបន្តរស់នៅក្នុងភាពក្រីក្រ និង វិសមភាពដែលបានវាស់វែងតាមរយៈការបែងចែកផលចំណូល និង ចំណាយ នៅតែបន្តកើនឡើង ។

គន្លឹះនៅក្នុងការកាត់បន្ថយភាពក្រីក្រ គឺការទទួលបាននូវឱកាសការងារសមរម្យ។ ការងារសមរម្យរួមបញ្ចូលមិនគ្រាន់តែការមានការងារធ្វើរបស់ស្ត្រី និងបុរសប៉ុណ្ណោះទេ ប៉ុន្តែវាទាមទារនូវការងារប្រកបដោយផលិតភាពដែលផ្តល់នូវចំណូលគ្រប់គ្រាន់ ដើម្បីធ្វើឲ្យកម្មករ និងគ្រួសាររបស់គាត់ចាកផុតអំពី ភាពក្រីក្រ ផ្តល់លក្ខខណ្ឌសម្រាប់ការទទួលបានការងារបែបនេះ មានសុវត្ថិភាពពេលជួបគ្រោះអាសន្ន លក្ខខណ្ឌការងារល្អរៀងរាល់ថ្ងៃ និងការចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្ត ដែលមានផលប៉ះពាល់ដល់ជីវិត និងជីវភាពរបស់ពួកគាត់ ។ ដោយហេតុនេះ វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងធម្មជាតិ និងចលករ នៃទីផ្សារការងារ ។

នៅឯការប្រជុំថ្នាក់តំបន់នៃអាស៊ានលើកទី ១៤ របស់អង្គការពលកម្មអន្តរជាតិ (ILO) ក្នុង ខែ កញ្ញា ឆ្នាំ ២០០៦ តំណាងរដ្ឋាភិបាល និយោជក និងនិយោជិត ពីប្រទេសកម្ពុជា និងប្រទេសជាសមាជិកនៃ អាស៊ី-ប៉ាស៊ីភិចដទៃទៀត បានសន្យាដោយខ្លួនឯងសម្រាប់

ទសវត្សរ៍ការងារសមរម្យរបស់អាស៊ានមួយ សម្រាប់រយៈកាលរហូតដល់ឆ្នាំ២០១៥។[1] បណ្តាគោលនយោបាយ និងកម្មវិធីដែលបានផ្តល់ព័ត៌មានដោយការវិភាគដែលអាចប្រើប្រាស់បាន នៃស្ថិតិទីផ្សារការងារ និងសង្គមរបស់កម្ពុជាមានភាពចាំបាច់ដើម្បីឈាន ឆ្ពោះទៅសំរេចបានបណ្តាគោលដៅនៃការងារសមរម្យ ។ ដោយប្រើប្រាស់ទិន្នន័យថ្មីៗបំផុត របាយការណ៍ និន្នាការពលកម្មនិងសង្គមកម្ពុជាឆ្នាំ ២០១០ នេះ បំភ្លឺអំពីព័ត៌មាននៃទីផ្សារការងាររបស់កម្ពុជា និងរំលេច ចេញនូវគោលនយោបាយដែលជាប់ទាក់ទង ។

## ១.២ កម្មវត្ថុនៃរបាយការណ៍

ចំណុចចាប់ផ្តើមនៃគោលនយោបាយប្រកបដោយលក្ខណៈជាក់ស្តែង និងសំដៅលើលទ្ធផល គឺត្រូវ អាស្រ័យលើព័ត៌មានដែលមានលក្ខណៈច្បាស់លាស់ និងជាប់ទាក់ទង ។ ដោយហេតុនេះ កម្មវត្ថុចំបងនៅ ក្នុងការរៀបចំរបាយការណ៍នេះ គឺសំដៅចងក្រងទិន្នន័យដែលមាន និងពិនិត្យមើលលើគោលនយោបាយនានាដើម្បីផ្តល់ចេញនូវការវិភាគ និងការពិនិត្យស៊ីជំរៅលើកម្លាំងពលកម្ម និងនិន្នាការសង្គមរបស់ប្រទេស ដែលនេះនឹងក្លាយទៅជាមធ្យោបាយអប់រំផ្សព្វផ្សាយ ដ៏មានប្រយោជន៍មួយសម្រាប់ការជំរុញការងារសម រម្យ ។ របាយការណ៍នេះ មានគោលបំណងជាពិសេសសម្រាប់ជាប្រភពព័ត៌មាន ដែលអាចអនុវត្តបានសម្រាប់អ្នករៀបគោលនយោបាយ អ្នកស្រាវជ្រាវនានា និងបណ្តាឯកជនដទៃទៀតដែលធ្វើការលើវិស័យ សេដ្ឋកិច្ច និងសង្គមសម្រាប់ការអភិវឌ្ឍន៍កម្ពុជា និងតំបន់ ។

## ១.៣ រចនាសម្ព័ន្ធនៃរបាយការណ៍

របាយការណ៍បានរៀបចំជា ៥ ជំពូកៈ ជំពូក ១ ផ្តល់នូវសារតារ និងវិធីសាស្រ្តដែលបានប្រើប្រាស់ក៏ដូចជាភាពមានដែនកំណត់របស់របាយការណ៍ ។ ជំពូក ២ ពិភាក្សាអំពីចរិតលក្ខណៈប្រជាសាស្រ្តទូទៅ ចំនួន និងសមាសភាពប្រជាជនអត្រាអក្ខរភាព និងកំរិតវប្បធម៌ ។ ជំពូក ៣ ផ្តល់នូវការពិនិត្យស៊ីជំរៅលើទិដ្ឋភាពសង្គមសេដ្ឋកិច្ចថ្មីៗ និងនិន្នាការទីផ្សារការងារដែលមានជាប់ទាក់ទងនឹងការងារ ការបំលាស់ ទីកម្លាំងពលកម្ម ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអភិវឌ្ឍន៍ទេពកោសល្យ តំរូវការទីផ្សារការងារ ផលិត ភាពនៃកម្លាំងពលកម្ម ការគាំពារសង្គម សុវត្ថិភាពនិងសុខភាពមុខរបរ ពលកម្មកុមារ សមាជិកភាព នៃសហជីព កិច្ចការសហជីពកម្មករ និងទំនាស់ឧស្សាហកម្មនៅក្នុងប្រទេស ។ ជំពូក ៤ លើកឡើងអំពី ការវិភាគផលប៉ះពាល់ទាក់ទងទៅនឹងវិបត្តិសេដ្ឋកិច្ចសកលលោកចំពោះទីផ្សារការងារ និងការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ជំពូក ៥ បង្ហាញអំពីការពិភាក្សាលើបញ្ហានៃទីផ្សារ

[1] ILO, Realizing decent work in Asia: Conclusions, Fourteenth Asian Regional Meeting, Busan, Korea,29 August - 1 September 2006, available at: www.ilo.org/public/english/standards/relm/rgmeet/14asrm/conclusions.pdf

ការងារដែលមានកើតឡើងក្នុងរយៈកាល នៃទសវត្សការងារសមរម្យរបស់អាស៊ាន និងពិនិត្យមើលអំពីថា តើវាជាប់ទាក់ទងទៅនឹងការលំបាកសាកល្បង និងកាលានុវត្តភាពរយៈពេលវែងសម្រាប់កម្ពុជាដូចម្តេច ។

ការបោះពុម្ពផ្សាយនេះ ផ្អែកទៅលើទិន្នន័យដែលមាន ដោយផ្តោតទៅលើការវិភាគនិន្នាការប្រជាសាស្ត្រថ្មីបំផុត ទីផ្សារការងារ និងនិន្នាការសេដ្ឋកិច្ច ដោយរំលេចនូវគោលនយោបាយដែលពាក់ពន្ធ័ និងអាចអនុវត្តបានក្នុងលក្ខណៈច្បាស់លាស់ និងចំចំណុច ។ ការវិភាគ ក៏បានផ្តោតជាពិសេសទៅលើ លក្ខណៈយេនឌ័រ និងព្យាយាមបំបែកទិន្នន័យ និងការវិភាគតាមលក្ខណៈយេនឌ័រនៅគ្រប់កន្លែងដែលអាច ធ្វើទៅបាន ។ ឧបសម្ព័ន្ធស្ថិតិលំអិត ក៏មានផ្តល់ជូននូវផ្នែកខាងក្រោយដែលអាចប្រើប្រាស់សម្រាប់ការប្រៀបធៀបជាអន្តរជាតិ នៃសូចនាករដែលមានលក្ខណៈយេនឌ័រ ដែលត្រូវបានប្រើប្រាស់សម្រាប់ការវាស់ វែង ការវិវត្តន៍ឆ្ពោះទៅរកគោលដៅនានារបស់ការងារសមរម្យ ។

## ១.៤ ប្រភពទិន្នន័យ

ទិន្នន័យដែលគួរឲ្យទុកចិត្តបាន មិនមានជានិច្ចកាលទេនៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន ។ ប្រទេសកម្ពុជាក៏ដូច្នោះដែរ ពិសេសព័ត៌មាននៃកម្លាំងពលកម្មដែលលំអិត និងប្រកបដោយបច្ចុប្បន្នភាព ។ យ៉ាងណាក្តី អ្នកស្រាវជ្រាវបានខិតខំព្យាយាមរាវរកអស់ពីលទ្ធភាពនូវប្រភពទិន្នន័យជាច្រើន ដោយរួមទាំងពី ស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីផ្តល់ចេញនូវការវិភាគប្រកបដោយលក្ខណៈប្រកួតប្រជែងនេះ ។ ទិន្នន័យ ភាគច្រើនបានមកពីការអង្កេតសង្គមសេដ្ឋកិច្ចនានា ក៏ដូចជាជំរឿនប្រជាសាស្ត្រទូទៅនៃកម្ពុជាឆ្នាំ ១៩៩៨ និង ២០០៨ ដែលបានអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិ ។ ទិន្នន័យនៃភាពក្រីក្របានស្រង់ចេញអំពីរបាយ ការណ៍ភាពក្រីក្រដែលធនាគារពិភពលោក និងទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិរបស់ស៊ុយអែត (SIDA) បានផលិតក្នុងកិច្ចសហការជាមួយ រ.ជ.ស ។ ព័ត៌មានអំពីការវិនិយោគទុនផ្ទាល់ពីបរទេសបានមកអំពីធនា គារជាតិនៃកម្ពុជា។

ទិន្នន័យខ្លះដែលជាប់ទាក់ទងនឹងពលករនៅក្រៅប្រទេស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងតំរូវការពលករពីការវិនិយោគ ការធានារ៉ាប់រងសង្គមសុវត្ថិភាពការងារ និងវិវាទការងារបានមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ អ្នកស្រាវជ្រាវនៃរបាយការណ៍ ក៏បានធ្វើសំភាសន៍ផងដែរជាមួយនឹងបុគ្គលសំខាន់ៗ ដើម្បីទទួលបាននូវទិន្នន័យ និងការវិភាគបន្ថែមដោយរួមទាំងតំណាងរបស់សហជីព តំណាងរបស់ ស្ថាប័ននិយោជក និងនាយករបស់នាយកដ្ឋានព័ត៌មានទីផ្សាររបស់ក្រសួងការងារ និងបណ្តុះបណ្តាល

វិជ្ជាជីវៈ ។ ប្រភពព័ត៌មានដទៃទៀតដែលបានប្រើប្រាស់ មានបញ្ជាក់ឈ្មោះនៅក្នុងរបាយការណ៍នេះ (សូម ពិនិត្យមើលផងដែរនូវផ្នែកឯកសារយោង) ។

## ១.៥ ភាពមានព្រំដែននៃរបាយការណ៍

ទោះបីជាមានការខិតខំប្រឹងប្រែងប្រមូលទិន្នន័យ និងព័ត៌មានដែលជាប់ទាក់ទង និងគួរឲ្យទុក ចិត្តបានយ៉ាងណាក្តី ភាពមានព្រំដែនមិនអាចចៀសផុតបាន មានដូចខាងក្រោម៖

- ទិន្នន័យភាគច្រើនដែលមានសម្រាប់ការធ្វើការវិភាគតាមស៊េរីនៃពេលបាន គឺមានតែមកពី ទិន្នន័យជំរឿនប្រជាសាស្ត្រទូទៅនៃប្រជារាស្ត្រកម្ពុជាតែប៉ុណ្ណោះ ។ មកដល់បច្ចុប្បន្ននេះមានតែទិន្នន័យជំរឿនប្រជាសាស្ត្រ ២ ប៉ុណ្ណោះ នោះគឺជំរឿនឆ្នាំ១៩៩៨ និង ឆ្នាំ២០០៨។
- ទិន្នន័យអង្កេតពីរនៃឆ្នាំផ្សេងគ្នា ជាទូទៅមិនអាចយកមកប្រៀបធៀបគ្នាបាន អាស្រ័យដោយភាពខុសគ្នានៃគំរូ វិធីសាស្ត្រ និងតារាងសំណួរដែលបានប្រើប្រាស់។
- ទិន្នន័យលើទិដ្ឋភាពផ្សេងៗនៃទីផ្សារការងារ ដូចជាការងារមិនផ្លូវការ ការងារបន្ថែម ទំនាក់ទំនងការងារ រយៈពេលធ្វើការងារ ជនក្រីក្រដែលធ្វើការងារ ប្រាក់បៀវត្សនិងប្រាក់ចំណូល និងលក្ខខណ្ឌការងារដទៃទៀតមិនមានក្នុងលក្ខណៈស៊ីគ្នាទេ ។ ទិន្នន័យដែលមានសម្រាប់ព័ត៌ មានទាំងនេះមិនត្រូវបានកំណត់ឲ្យបានច្បាស់លាស់ ឬរៀបចំឲ្យបានស៊ីគ្នាទេ ហើយដោយ ហេតុនេះក៏មិនត្រូវបានប្រើប្រាស់នៅក្នុងការវិភាគនេះដែរ ។

# ជំពូក ២

## ចរឹតលក្ខណៈប្រជាសាស្ត្រ

ជំពូកនេះ បង្ហាញព័ត៌មានជាមូលដ្ឋានអំពីប្រជាសាស្ត្រនៅកម្ពុជា ដូចជាទំហំ និងសមាសភាគប្រជា ពាស្ត្រ អត្រាអក្ខរភាព និងកំរិតសិក្សាដែលទទួលបាន។

### ២.១ កំណើនប្រជាពាស្ត្រ

ចរឹតលក្ខណៈប្រជាពាស្ត្រ មានទំនាក់ទំនងទៅនឹងការផ្លាស់ប្តូរកម្លាំងពលកម្មរបស់ប្រទេស ។ សូច នាករប្រជាសាស្ត្រប្រើប្រាស់សម្រាប់រៀបចំគំពោង និងការត្រួតពិនិត្យតាមដាន វាយតំលៃដំណើរប្រព្រឹត្ត ទៅរបស់គំពោង ។ លទ្ធផលជំរឿនទូទៅនូវប្រជាពាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ បង្ហាញថាប្រទេស កម្ពុជាមានប្រជាពាស្ត្រ ១៣,៤ លាននាក់ដែលក្នុងនោះ ៦,៥២ លាននាក់ ឬ ៤៨,៦ ភាគរយប្រុស និង ៦,៨៨ លាននាក់ ឬ ៥១,៤ ភាគរយស្រី (តារាង ២.១) ។ អត្រាកំណើនមួយទស្សវត្សរ៍ ១៩៩៨ ដល់ ២០០៨ ស្មើនឹង ១៦,៧ ភាគរយ ឬ អត្រាកំណើនមធ្យមប្រចាំឆ្នាំស្មើនឹង ១,៥ ភាគរយ ។

**តារាង ២.១. អត្រាកំណើនប្រជាពាស្ត្រ ឆ្នាំ ១៩៩៨ - ២០០៨**

| ភេទ | ជំរឿនប្រជាពាស្ត្រ ១៩៩៨ | | ជំរឿនប្រជាពាស្ត្រ ២០០៨ | | អត្រាកំណើនមួយទស្សវត្សរ៍ | អត្រាកំណើនមធ្យមប្រចាឆ្នាំ |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ភាគរយ | ភាគរយ |
| សរុប | 11 437 656 | 100.0 | 13 395 682 | 100.0 | 16.7[2] | 1.5 |
| ប្រុស | 5 511 408 | 48.2 | 6 516 054 | 48.6 | 17.8 | 1.6 |
| ស្រី | 5 926 248 | 51.8 | 6 879 628 | 51.4 | 15.6 | 1.5 |

[2] អត្រាកំណើនមួយទសវត្ស និងអត្រាកំណើនប្រចាំឆ្នាំត្រូវបានគណនាបន្ទាប់ពីការបូកសរុបចំនួនប្រជាពាស្ត្រ ៩៥ ០០០ នាក់នៅក្នុងតំបន់ដែលមិនបានធ្វើ ជំរឿនឆ្នាំ ១៩៩៨ ដោយសារអសន្តិសុខ ចំនួនបុរស និងស្ត្រីសំរាប់ឆ្នាំ ១៩៩៨ ធ្វើការប៉ាន់ស្មានទៅតាមសមាមាត្រភេទនៅក្នុងចំណាមប្រជាពាស្ត្រទូទៅ។

ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជាពស្រ្តរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- NIS/MOP ជំរឿនទូទៅនូវប្រជាពស្រ្តរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨

យោងតាមសៀវភៅស្ថិតិប្រចាំឆ្នាំរបស់អង្គការសហប្រជាជាតិឆ្នាំ ២០០៨ មានប្រជាជនប្រមាណ ៧៧៧ លាននាក់ ឬ ៨,៦ ភាគរយនៃប្រជាជនពិភពលោករស់ក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ប្រជាជនកម្ពុជា មាន ២,៣ ភាគរយ នៃប្រជាជនក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

ដូចបង្ហាញក្នុងតារាង ២.២ អត្រាកំណើនប្រជាជនកម្ពុជាប្រចាំឆ្នាំមាន ១,៥ ភាគរយ ខ្ពស់ជាង អត្រាកំណើនប្រជាជនប្រចាំតំបន់អាស៊ីអាគ្នេយ៍ ១,២ ភាគរយ ។ អត្រាកំណើនប្រជាពស្រ្តកម្ពុជាខ្ពស់ជាង អត្រាកំណើនប្រទេសថៃ ខ្ពស់ជាងអត្រាកំណើនប្រទេសវៀតណាមបន្តិចបន្តួច ទាបជាងខ្លាំងជាមួយអត្រាកំណើនប្រទេសទីម័រលេស ប្រ៊ុយណេ និងប្រទេសហ្វីលីពីន ប៉ុន្តែអត្រាកំណើននេះទាបជាងតិចតួចធៀប ទៅនឹងប្រទេសឡាវ និងម៉ាឡេស៊ី ។

### តារាង ២.២. ប្រជាជនរបស់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍[3]

| ប្រទេស | ចំនួនប្រជាពស្រ្តពាក់កណ្ដាលឆ្នាំ ២០០៨ (ពាន់នាក់) | អត្រាកំណើនប្រចាំឆ្នាំ(%) |
|---|---|---|
| អាស៊ីអាគ្នេយ៍ | 576 637 | 1.2 |
| ប្រ៊ុយណេដារូសាឡាម | 398 | 2.0 |
| កម្ពុជា | 13 396 | 1.5 |
| ឥណ្ឌូណេស៊ី | 234 342 | 1.1 |
| ឡាវ | 5 983 | 1.7 |
| ម៉ាឡេស៊ី | 27 663 | 1.8 |
| ភូមា | 49 221 | 0.8 |
| ហ្វីលីពីន | 90 457 | 2.0 |
| សឹង្ហបូរី | 4 490 | 1.2 |
| ថៃឡង់ដ៍ | 63 121 | 0.4 |
| ទិម័រ លេស | 1 193 | 3.5 |
| វៀតណាម | 86 373 | 1.3 |

## ២.២ ទំហំ និងសមាសភាគប្រជាពស្រ្ត

ជំរឿនប្រជាពស្រ្តឆ្នាំ ២០០៨ បង្ហាញថាចំនួនប្រជាពស្រ្តកម្ពុជានៅមានទំហំធំសម្រាប់ "កុមារ" ក្នុងចំនួន ៤,៥១ លាននាក់ ឬ ៣៣, ៧ ភាគរយដែលស្ថិតក្នុងក្រុមអាយុ ០ ដល់ ១៤ ឆ្នាំ ក្នុងនោះប្រុស មាន

[3] គ្រប់ប្រទេសទាំងអស់លើកលែងតែកម្ពុជា និង សរុបសម្រាប់តំបន់អាស៊ីអាគ្នេយ៍។ ប្រភពទិន្នន័យស្រង់ចេញពីសន្លឹកព័ត៌មានប្រជាជន *ESCAP* បាងកក ២០០៨ ។ ប្រជាជនកម្ពុជាដកស្រង់ចេញពីជំរឿនទូទៅនូវប្រជាពស្រ្តរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ ។

២,៣១ លាននាក់ (៣៥,៥ ភាគរយ) និងស្រី ២,២០ លាននាក់ (៣២ ភាគរយ) (តារាង ២.៣) ។ ទោះជាយ៉ាងណាក៏ដោយតួលេខនេះ បង្ហាញពីនិន្នាការធ្លាក់ចុះពីឆ្នាំ ១៩៩៨ ដែលនៅក្នុងក្រុមអាយុដូចគ្នា នេះមាន ៤,៩ លាននាក់ ឬ ៤២,៨ ភាគរយ (ប្រុស ២,៥ លាននាក់ ឬ ៤៥,៤ ភាគរយ និងស្រី ២,៤ លាន នាក់ ឬ ៤០,៤ ភាគរយ) ។

### តារាង ២.៣. ប្រជារាស្ត្រតាមក្រុមអាយុ និងភេទ ឆ្នាំ ១៩៩៨-២០០៨

| ក្រុមអាយុ | ១៩៩៨ | | | ២០០៨ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ចំនួន | | | | | | |
| 0–14 | 4 897 808 | 2 502 407 | 2 395 401 | 4 513 792 | 2 314 806 | 2 198 986 |
| 15–24 | 2 089 945 | 1 018 284 | 1 071 661 | 2 988 492 | 1 503 759 | 1 484 733 |
| 25–54 | 3 592 551 | 1 629 576 | 1 962 975 | 4 653 371 | 2 188 238 | 2 465 133 |
| 55–64 | 461 924 | 196 791 | 265 133 | 668 727 | 279 059 | 389 668 |
| 65+ | 395 428 | 164 350 | 231 078 | 571 300 | 230 192 | 341 108 |
| សរុប | **11 437 656** | **5 511 408** | **5 926 248** | **13 395 682** | **6 516 054** | **6 879 628** |
| ភាគរយ | | | | | | |
| 0–14 | 42.8 | 45.4 | 40.4 | 33.7 | 35.5 | 32.0 |
| 15–24 | 18.3 | 18.5 | 18.1 | 22.3 | 23.1 | 21.6 |
| 25–54 | 31.4 | 29.6 | 33.1 | 34.7 | 33.6 | 35.8 |
| 55–64 | 4.0 | 3.6 | 4.5 | 5.0 | 4.3 | 5.7 |
| 65+ | 3.5 | 3.0 | 3.9 | 4.3 | 3.5 | 5.0 |
| សរុប | **100.0** | **100.0** | **100.0** | **100.0** | **100.0** | **100.0** |

ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨
- NIS/MOP ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨

ការធ្លាក់ចុះចំនួនកុមារក្នុងទសវត្សរ៍កន្លងមក ដោយសារការបន្តធ្លាក់ចុះនៃអត្រាលទ្ធភាពបង្កើត កូនរបស់ស្ត្រី ។ តារាង ២.៤ បង្ហាញពីចំនួនកូនមធ្យមដែលផ្តល់កំណើតដោយស្ត្រីអាយុ ១៥-៤៩ ឆ្នាំ យោង តាមជំរឿន និងប្រភពអង្កេតគ្រួសារ ។ តួលេខនេះបង្ហាញអត្រាលទ្ធភាពបង្កើតកូនរបស់ស្ត្រី បានធ្លាក់ចុះ ពីជាងប្រាំនាក់នៅ ឆ្នាំ ១៩៩៨ មកនៅត្រឹមបីនាក់ក្នុងស្ត្រីម្នាក់នៅឆ្នាំ ២០០៨ ។

### តារាង ២.៤. អត្រាលទ្ធភាពបង្កើតកូនរបស់ស្ត្រី ឆ្នាំ ១៩៩៨ និង ២០០៨

| ជំរឿន/អង្កេត | អត្រាលទ្ធភាពបង្កើតកូន |
|---|---|
| ជំរឿនឆ្នាំ ១៩៩៨ | 5.3 |
| អង្កេតប្រជារាស្ត្រ និងសុខភាពឆ្នាំ ២០០០ | 4.0 |
| អង្កេតប្រជារាស្ត្រនិងសុខភាពឆ្នាំ ២០០៥ | 3.4 |
| ជំរឿនឆ្នាំ ២០០៨ | 3.1 |

ប្រភព - ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨ របាយការណ៍ទី ១ លទ្ធភាពបង្កើតកូន និងមរណភាព NIS/MOP
- ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨ របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ NIS/MOP

យោងតាមនិយមន័យរបស់អង្គការសហប្រជាជាតិ "យុវជន" សំដៅលើមនុស្សដែលមានវ័យក្នុង ចន្លោះ ១៥-២៤ ឆ្នាំ និង"មនុស្សពេញវ័យ" សំដៅលើមនុស្សដែលមានវ័យ ២៥ ឆ្នាំឡើង។ ចំនួនប្រជារាស្ត្រ ជាយុវជនកើនឡើងពី ២,១ លាននាក់ (១៨,៣ ភាគរយ) ក្នុងឆ្នាំ ១៩៩៨ ទៅ ២,៩៩ លាននាក់ (២២,៣ ភាគរយ) នៅ ឆ្នាំ ២០០៨ ដែលក្នុងចំណោមនោះប្រុសបានកើនពី ១,០២ លាននាក់ (១៨,៥ ភាគរយ) ទៅ ១,៥ លាននាក់ (២៣,១ ភាគរយ) ខណៈដែលស្រីបានកើនពី ១,០៧ លាននាក់ (១៨,១ ភាគរយ) ទៅ ១,៤៨ លាននាក់ (២១,៦ ភាគរយ) ។

ចំនួនប្រជារាស្ត្រពេញវ័យបានកើនឡើងផងដែរ ក្នុងចំនួនដាច់ខាតពី ៤,៤៥ លាននាក់ (៣៨,៩ ភាគរយ) ក្នុងឆ្នាំ ១៩៩៨ ទៅ ៥,៩ លាននាក់ (៤៤ ភាគរយ) ក្នុងឆ្នាំ ២០០៨ ដែលក្នុងចំណោមនោះ ប្រុស បានកើនពី ១,៩៩ លាននាក់ (៣៦,២ ភាគរយ) ទៅ ២,៧ លាននាក់ (៤១,៤ ភាគរយ) និងស្រីបានកើនពី ២,៤៦ លាននាក់ (៤១,៥ ភាគរយ) ទៅ ៣,២ លាននាក់ (៤៦,៥ ភាគរយ) ។ ការកើនឡើងនៃចំនួនប្រជា រាស្ត្រជាយុវជន និងប្រជារាស្ត្រពេញវ័យ បានសេចក្តីថានឹងមានការកើនឡើងនៃការផ្គត់ផ្គង់កំម្លាំងពលកម្ម ដល់ប្រទេស ឬប្រើប្រាស់សម្រាប់សកម្មភាពសេដ្ឋកិច្ច ។

ការបន្តធ្លាក់ចុះនៃកំណើនប្រជារាស្ត្រក្នុងឆ្នាំថ្មីៗនេះ បញ្ជាក់ពីប្រជារាស្ត្រកម្ពុជាកំពុងធ្វើដំណើរការ ទៅកាន់ទីបញ្ចប់នៃអន្តរកាលប្រជាជន ។ ការប្រៀបធៀបរចនាសម្ព័ន្ធអាយុប្រជារាស្ត្រតាមភេទឃើញថា សមាមាត្រនៃប្រជាជនជាកុមារក្នុង (០-១៤ឆ្នាំ) រួញខ្លីក្នុងទស្សវត្សរ៍ចុងក្រោយនេះពី ៤២,៨ ភាគរយក្នុង ឆ្នាំ ១៩៩៨ មកត ៣៣,៧ ភាគរយនៅក្នុងឆ្នាំ ២០០៨ ដោយសារការធ្លាក់ចុះនៃអត្រាលទ្ធភាព បង្កើតកូន ។ ប្រជាជនក្នុងអាយុធ្វើការ (១៥-៦៤) មានតែ ៥៣,៧ ភាគរយនៅឆ្នាំ១៩៩៨ ទល់នឹង ៦២ ភាគរយនៅឆ្នាំ ២០០៨ ។ ទោះបីប្រជារាស្ត្រវ័យចំណាស់មានតែ ៣,៥ ភាគរយនៃប្រជារាស្ត្រសរុប ប៉ុន្តែចំនួននេះបាន កើនឡើងទៅ ៤,៣ ភាគរយក្នុងអំឡុងមួយទស្សវត្សរ៍ ។

រូប២.១ ពណ៌នាសមាសភាពភេទ និងអាយុរបស់ប្រជារាស្ត្រក្នុងឆ្នាំ ២០០៨ ជាពីរ៉ាមីត ។ សមាមាត្រ កុមារក្រុមអាយុ ០-៤ ឆ្នាំ តិចជាងអាយុ ៥-៩ ឆ្នាំ ។ នេះគឺ ដោយសារការធ្លាក់ចុះនៃអត្រាលទ្ធភាពបង្កើត កូន និងដោយសាររាយការណ៍មិនអស់ចំនួនទារក និងកុមារក្នុងក្រុមអាយុនេះ ។ ក្រុមអាយុ ១០-១៤ ឆ្នាំ មានចំនួនច្រើន (១២,៥ ភាគរយ) ដែលបានកត់ត្រាក្នុងជំរឿនឆ្នាំ ២០០៨ បន្ទាប់មកក្រុមអាយុ ១៥-១៩ ឆ្នាំ ដែលបញ្ជាក់ការប្រៀបធៀបនៃអត្រាលទ្ធភាពបង្កើតកូនខ្ពស់ ក្នុងដើមទស្សវត្សរ៍ឆ្នាំ ១៩៩០ បន្ទាប់ពីកើន ឡើងនៃទារកនៅដើមទស្សវត្សរ៍ឆ្នាំ ១៩៨០ ។

## រូប ២.១ ពីរ៉ាមីតប្រជារាស្ត្រកម្ពុជានៅ ឆ្នាំ ២០០៨




ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨

ការផ្លាស់ប្តូរលើក្រុមមនុស្សដែលមានអាយុលើស ១០ ឆ្នាំ ក្នុងពីរ៉ាមីតអាយុបង្ហាញពីទំរង់ធម្មតា នៃលំដាប់ថយចុះជាមួយនឹងការកើនឡើងនៃអាយុ ។ ប៉ុន្តែមានភាពលើកលែងដោយឡែកតែក្នុងក្រុមអាយុ ៣០-៣៤ ឆ្នាំដែលបង្ហាញពីការថយចុះយ៉ាងគំហុក ។ ការណ៍នេះអាចរងនូវឥទ្ធិពលរួមគ្នានៃអត្រាលទ្ធភាព បង្កើតកូនទាប និងអត្រាមរណភាពខ្ពស់ក្នុងចំណោមប្រជារាស្ត្រ ដែលបានកើតក្នុងរបបខ្មែរក្រហម (១៩៧៥-១០៧៩) ។ នៅដើមទស្សវត្សរ៍ឆ្នាំ ១៩៧០ កម្ពុជាមានសង្គ្រាមស៊ីវិល និងចុងទស្សវត្សរ៍ឆ្នាំ ១៩៧០ មានចំនួនអ្នកស្លាប់ច្រើនដោយសារការសម្លាប់ ទុរភិក្ស និងជម្ងឺ ។ រចនាសម្ព័ន្ធភេទ និងអាយុលើស ៣៥ ឆ្នាំ ទទួលរងនូវកំរិតមរណភាពខ្ពស់ ជាពិសេសបុរសក្នុងកំឡុងឆ្នាំចលាចល និងជម្លោះផ្ទៃក្នុងដែលប្រសើរឡើងវិញក្នុងអំឡុងឆ្នាំ ១៩៨០ ទោះបីមានកំរិតផ្សេងគ្នាក៏ដោយ ។

ផលធៀបអាយុក្នុងបន្ទុក[4] បង្ហាញពីនិន្នាការធ្លាក់ចុះពី ៨៦,១ ភាគរយមក ៦១,២ ភាគរយ (១៩៩៨-២០០៨) ។ ការធ្លាក់ចុះនេះមានល្បឿនលឿនសម្រាប់ទាំងបុរស និងស្ត្រីមាន ៩៣,៧ ភាគរយនៅ ឆ្នាំ ១៩៩៨ ដែលផ្ទុយនឹង ៦៤,១ ភាគរយក្នុងឆ្នាំ ២០០៨ សម្រាប់បុរស និង ៧៩,៦ ភាគរយធៀបជាមួយ ៥៨,៥ ភាគរយសម្រាប់ស្ត្រី (តារាង២.៥) ។ ភាពខុសគ្នាដ៏ធំបានកំណត់ឲ្យមានការប្រែប្រួលក្នុងរចនា
សម្ព័ន្ធអាយុព្រមជាមួយនឹងការធ្លាក់ចុះនៃសមាមាត្ររបស់ប្រជាជនជាកុមារ។

## តារាង ២.៥ ផលធៀបអាយុក្នុងបន្ទុកឆ្នាំ១៩៩៨ និង ២០០៨

| ផលធៀបអាយុក្នុងបន្ទុក | ១៩៩៨ | ២០០៨ |
|---|---|---|
| ទាំងពីរភេទ | **86.1** | **61.2** |
| ប្រុស | 93.7 | 64.1 |

[4] ផលធៀបអាយុក្នុងបន្ទុកកំណត់ដោយសមមាត្រនៃប្រជារាស្ត្រក្រុមអាយុវ័យក្មេង (០-១៤) និង ក្រុមអាយុមនុស្សចាស់ (៦៥ ឆ្នាំឡើង) ធៀបនឹងប្រជារាស្ត្រមាន អាយុ១៥-៦៤ ឆ្នាំ ។

| | | |
|---|---|---|
| ស្រី | 79.6 | 58.5 |

ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជាពស្រ្តរបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨
- NIS/MOP ជំរឿនទូទៅនូវប្រជាពស្រ្តរបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨

ការប្រែប្រួលរចនាសម្ព័ន្ធនៃប្រជាពស្រ្តមានទំនាក់ទំនងទៅនឹងទីផ្សារការងារ ។ ម៉្យាងទៀតការធ្លាក់ ចុះនៃផលធៀបអាយុក្នុងបន្ទុកមានន័យថា ប្រជាពស្រ្តក្នុងក្រុមអាយុធ្វើការមានចំនួនច្រើនដែលអាចគាំទ្រ ដល់វិស័យផ្សេងៗ ។ ក្រៅពីនេះ វាបញ្ជាក់ពីលំហូរចូលក្នុងកម្លាំងពលកម្ម និងចោទជាបញ្ហាប្រឈមនៃការផ្តល់ឱកាសការងារសម្រាប់ចំនួនអ្នកស្វែងរកការងារដ៏ច្រើននេះ ។

## ២.៣. អក្ខរភាព និងការអប់រំ

កំរិតអក្ខរភាព និងការអប់រំត្រូវបានចាត់ទុកជាសូចនាករមួយដ៏សំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ។ ការអប់រំមានឥទ្ធិពលលើឥរិយាបទប្រជាសាស្រ្តទាក់ទងនឹងអាពាហ៍ពិពាហ៍ លទ្ធភាពបង្កើតកូន មរណភាព និងការផ្លាស់ទីលំនៅ ក៏ដូចជាការចូលរួមក្នុងកម្លាំងពលកម្ម ។ ការសិក្សាស្រាវជ្រាវជាច្រើន បានបង្ហាញទំនាក់ទំនងផ្ទុយគ្នារវាងកំរិតសិក្សារបស់ស្ត្រី និងលទ្ធភាពបង្កើតកូន[5]។ អាយុរៀបការរបស់ស្ត្រីត្រូវបានរងឥទ្ធិពលដោយកំរិតសិក្សាដែលទទួលបាន ។ មរណភាពទារកក៏ជាអថេរមួយដែលទទួលរង ឥទ្ធិពលដោយកំរិតសិក្សារបស់ម្តាយផងដែរ ។ ម៉្យាងវិញទៀតកំរិតសិក្សាអប់រំរបស់ប្រជាពស្រ្ត មានទំនាក់ទំនងជាវិជ្ជមានខ្លាំងទៅនឹងផលិតភាពការងារ ។

ជាទូទៅ ការអប់រំបញ្ជាក់ពីគុណភាពអក្ខរភាពរបស់ប្រជាពស្រ្ត និងមានសារៈសំខាន់ណាស់ក្នុង ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍ និងគោលនយោបាយប្រជាពស្រ្ត ។ គោលនយោបាយអាទិភាពក្នុងផែនការយុទ្ធសាស្រ្តអប់រំឆ្នាំ ២០០៦-២០១០ សំដៅ i) ធានាទទួលបានសមធម៌សម្រាប់ការអប់រំ ii) បង្កើនគុណ ភាព និងប្រសិទ្ធភាពសេវាអប់រំក្នុង និង iii) អភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពសម្រាប់អនុវត្តវិមជ្ឈ ការ ។ គោលនយោបាយជាតិស្តីពីអក្ខរកម្ម និងវិស័យអប់រំក្រៅប្រព័ន្ធ មានគោលបំណងដើម្បី i) បង្កើន អត្រាអក្ខរភាព ២០ ភាគរយក្នុងរយៈពេល ១៥ ឆ្នាំគិតពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០១៥ ii) លើកកម្ពស់ការចូលរួមដើម្បីសម្រេចបានគោលដៅអប់រំមូលដ្ឋានសម្រាប់ទាំងអស់គ្នា និង iii) ផ្តល់គ្រប់ពលរដ្ឋ ជាពិសេស ស្ត្រី កុមារក្រៅសាលា កុមារធ្វើការ ជនជាតិភាគតិចនៅតំបន់ភ្នំ និងខ្ពង់រាប និងក្រុមងាយរងគ្រោះនូវឱកាសអប់រំពេញមួយជីវិតរបស់ពួកគេ ។

ការអនុវត្តប្រកបដោយជោគជ័យនៃកម្មវិធីអភិវឌ្ឍន៍អក្ខរភាព និងការចាប់ផ្តើមដោយប្រជាជន វ័យក្មេងភាគច្រើនដើម្បីរៀនអាន

[5] មើលឧទាហរណ៍ S.O.,Cinnirella,F.) និង Woessmann,L. ២០០៩ ការដូរដោះរវាងលទ្ធភាពបង្កើតកូន និងការអប់រំបញ្ជាក់ ភស្តុតាងពីមុនការធ្វើអន្តរកម្មប្រជាសាស្រ្ត អត្ថបទពិភាក្សាសេដ្ឋកិច្ច Stirling ២០០៩-១៧ សីហា ២០០៩ និង Breierova, L. and Duflo, E. ២០០២។ ផលប៉ះពាល់ការអប់រំលើលទ្ធភាពបង្កើតកូន និងមរណភាពកុមារៈ ថាតើបិតាពិតជាមានឥទ្ធិពលតិចជាងមាតាមែនឬ?MIT ។

និងសរសេរបានផ្តល់នូវកំណើននៃកំរិតអក្ខរភាពក្នុងចំណោមប្រជាជន ក្នុងទស្សវត្សរ៍កន្លងមក ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការអភិវឌ្ឍប្រទេស អត្រាអក្ខរភាព និងកំរិត សិក្សាអាចប្រែប្រួលក្នុងប្រទេស ពីតំបន់មួយទៅតំបន់មួយអាស្រ័យលើទំហំនៃការអភិវឌ្ឍរបស់តំបន់ ឬ សហគមន៍នីមួយៗ ។ ករណីនេះក៏ជាការពិតសម្រាប់ប្រទេសកម្ពុជាផងដែរ ។

ដូចបានបង្ហាញក្នុងតារាង ២.៦ អត្រាអក្ខរភាព (ផលធៀបនៃប្រជាពរាស្ត្រអក្ខរភាពធៀបនឹងប្រជា ពរាស្ត្រទូទៅអាយុ ៧ ឆ្នាំឡើង) បានស្ទុះឡើងគួរឲ្យភ្ញាក់ផ្អើលក្នុងមួយទស្សវត្សរ៍នេះ ។ ចំនួននេះកើនឡើង ពីប្រមាណ ៥,៧៨ លាននាក់ ទៅ ៨,៩៦ លាននាក់ជាមួយអត្រាកំណើនមួយទស្សវត្សរ៍ជិត ៥៥ ភាគរយ (ក្នុងពេលដែលអត្រាកំណើនប្រជាពរាស្ត្រមួយទស្សវត្សរ៍មានប្រមាណ ១៧ ភាគរយ) ។ អត្រាអក្ខរភាពក្នុង ចំណោមប្រជាពរាស្ត្រអាយុ ១៥-៦៤ ឆ្នាំមានទំនាក់ទំនងខ្លាំងក្នុងទស្សវត្សរ៍ ជាមួយនឹងការកើនឡើងខ្លាំងក្នុង ចំណោមស្ត្រីជាងបុរស ។

តារាង២.៦ អត្រាអក្ខរភាពឆ្នាំ ១៩៩៨ និង ២០០៨

| ភេទ | អត្រាអក្ខរភាពប្រជាពរាស្ត្រអាយុ ៧ ឆ្នាំឡើង១៩៩៨ | អត្រាអក្ខរភាពប្រជាពរាស្ត្រអាយុ ១៥-៦៤ ឆ្នាំ១៩៩៨ | អត្រាអក្ខរភាពប្រជាពរាស្ត្រអាយុ ៧ ឆ្នាំឡើង២០០៨ | អត្រាអក្ខរភាពប្រជាពរាស្ត្រ អាយុ ១៥-៦៤ ឆ្នាំ២០០៨ |
|---|---|---|---|---|
| ទាំងពីរភេទ | 62.8 | 69.7 | 78.4 | 79.6 |
| បុរស | 71.0 | 80.7 | 84.0 | 85.7 |
| ស្ត្រី | 55.4 | 60.2 | 73.1 | 74.0 |

ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជាពរាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨
- NIS/MOP ជំរឿនទូទៅនូវប្រជាពរាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨

តារាង ២.៧ បង្ហាញថា ៤៨,៩ ភាគរយនៃចំនួនសរុបប្រជាពរាស្ត្រចេះអាន និងសរសេរអាយុ៧ ឆ្នាំ ឡើង ជាទូទៅមិនបានបញ្ចប់កំរិតបឋមសិក្សា ។ ប្រជាពរាស្ត្រដែលបានបញ្ចប់កំរិតបឋមសិក្សា និងមធ្យម សិក្សាបឋមភូមិមានអត្រា ២៨,៦ភាគរយ និង ១៧ ភាគរយតាមលំដាប់រៀងនៅឆ្នាំ ២០០៨ ។ ប្រជាពរាស្ត្រ ដែលបានបញ្ចប់កំរិតវិទ្យាល័យ និងសញ្ញាប័ត្រដែលរួមមានសញ្ញាប័ត្របច្ចេកទេសមុនមធ្យមសិក្សាកម្រិត មធ្យម និង ទុតិយភូមិ និងសញ្ញាប័ត្របច្ចេកទេស សញ្ញាប័ត្រក្រោយមធ្យមសិក្សាមាន ១,៦ ភាគរយនៃប្រជា ពរាស្ត្រចេះអក្សរ ។ អ្នកមិនទាន់បានបញ្ចប់មហាវិទ្យាល័យ និងទទួលបានសញ្ញាប័ត្រឧត្តមសិក្សា ឬខ្ពស់ ជាងមានតែ ១,៥ ភាគរយប៉ុណ្ណោះ ។

យុវជន ៣៧,៦ ភាគរយ (អាយុ ១៥-២៤)បានបញ្ចប់កំរិតបឋមសិក្សា ខណៈដែល ២៩,៨ ភាគរយមិនបានបញ្ចប់ ហើយប្រមាណ ២៧ ភាគរយ បានបញ្ចប់កំរិតមធ្យមសិក្សាបឋមភូមិ ។ អ្នកដែល មានកំរិតសិក្សាខ្ពស់ជាងមធ្យមសិក្សាបឋមភូមិមាន ៤ ភាគរយនៃយុវជនចេះអក្សរទាំងអស់ ។ លទ្ធផល ជំរឿន បង្ហាញផងដែរពីអត្រាភាគរយខ្ពស់របស់ស្ត្រីក្នុងចំណោមប្រជាជនចេះអក្សរទាំងអស់ដែល មិនបាន បញ្ចប់កំរិតបឋមសិក្សា និងបានបញ្ចប់មាន ៣១,៩ ភាគរយ និង ៣៨,៤

ភាគរយតាមលំដាប់រៀងធៀបជា មួយ ២៧,៩ ភាគរយ និង ៣៦,៩ ភាគរយតាមលំដាប់រៀងសម្រាប់បុរស ។ បុរសមានភាគរយលើសលប់ ក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ និងកម្រិតខ្ពស់ជាង ។ សមាមាត្រយុវជនមិនបានបញ្ចប់កម្រិតបឋម សិក្សា បានថយចុះពី ៥២,៧ ភាគរយ សម្រាប់ទាំងពីរភេទ (ប្រុស៤៨,៨ ភាគរយ និង ស្ត្រី ៥៩ ភាគរយ) ក្នុងឆ្នាំ ១៩៩៨ ទៅ ២៩,៨ ភាគរយ (ប្រុស២៧,៩ ភាគរយ នឹង ស្ត្រី៣១,៩ ភាគរយ) នៅឆ្នាំ ២០០៨ ។

ជាមួយនិន្នាការដូចគ្នានេះដែរ សមាមាត្រអ្នកដែលបានបញ្ចប់កំរិតបឋមសិក្សា បានកើនឡើងក្នុង អំឡុងមួយទស្សវត្សរ៍កន្លងមក ។ ចំណែកដ៏ធំនៃប្រជារាស្ត្រអាយុ ១៥-២៤ ឆ្នាំជាអនក្ខរភាព និងគ្មានកំរិត សិក្សាជាក់លាក់ ឬមិនបានបញ្ចប់កំរិតបឋមសិក្សា ។ ទាំងនេះទាក់ទងសំខាន់ដល់គុណភាពកម្លាំងពលកម្ម ផ្អែកលើកំរិតសិក្សាជាមូលដ្ឋាន និងវិជ្ជាជីវៈការប្រកួតប្រជែងជាតិ និងការសម្រេចបានការងារសមរម្យ ។

សមាមាត្រប្រជារាស្ត្រពេញវ័យអាយុ ២៥ ឆ្នាំឡើងទៅដែលមិនបានបញ្ចប់កំរិតបឋមសិក្សាមាន តិចនៅឆ្នាំ ២០០៨ (៤៧,២ ភាគរយ) ជាងឆ្នាំ ១៩៩៨ (៥៦,៥ ភាគរយ) ។ លទ្ធផលជំរឿនបានបង្ហាញ គម្លាតគ្នាខ្លាំងខាងយេនឌ័ររវាងបុរស (៣៩,៩ ភាគរយ) និងស្ត្រី (៥៥,១ ភាគរយ) ជាពិសេសក្នុងចំណោម ប្រជារាស្ត្រពេញវ័យ ដែលមិនបានបញ្ចប់កំរិតបឋមសិក្សានៅឆ្នាំ ២០០៨ ។ កង្វះការសិក្សាអប់រំមានផល ប៉ះពាល់ជាចំបងដល់ឱកាសសម្រាប់ស្ត្រី ដើម្បីទទួលបានផលិតភាពការងារ និងការងារមានផលកម្រៃ ល្អ ។ សមាមាត្រអ្នកចេះអក្សរដែលមានកំរិតសិក្សាខ្ពស់ជាងបឋមសិក្សាមាន ២២,៨ ភាគរយនៃប្រជា រាស្ត្រពេញវ័យទាំងអស់ (បុរស ២៨,២ ភាគរយ និងស្ត្រី ១៧ ភាគរយ) ។

### តារាង ២.៧ កំរិតសិក្សាដែលបានបញ្ចប់ដោយប្រជារាស្ត្រ អាយុ ៧ ឆ្នាំឡើង ឆ្នាំ ១៩៩៨ និង ២០០៨

| ភេទនិងក្រុមអាយុ | ចំនួន | អក្ខរភាព | ការបែងចែកភាគរយកម្រិតសិក្សាពេញលេញ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | មិនបានបញ្ចប់ថ្នាក់ណាមួយ | មិនបានបញ្ចប់បឋមសិក្សា | បឋមសិក្សា | មធ្យមសិក្សាបឋមភូមិ | មធ្យមសិក្សា/សញ្ញាប័ត្របច្ចេកទេស | ក្រោយមធ្យម | ផ្សេងទៀត | មិនបានរាយការណ៍ |
| **១៩៩៨** | | | | | | | | | | |
| ទាំងពីរភេទ | | | | | | | | | | |
| ចំនួន | 9 225 621 | 37.4 | 1.8 | 63.3 | 22.4 | 9.2 | 2.7 | 0.5 | 0.1 | 0.1 |
| 7–14 | 2 685 773 | 48.3 | 2.2 | 88.3 | 8.8 | 0.7 | - | - | 0.0 | 0.0 |
| 15–24 | 2 089 945 | 24.0 | 0.8 | 53.7 | 30.2 | 12.2 | 2.7 | 0.4 | 0.0 | 0.0 |
| 25+ | 4 449 903 | 37.0 | 2.1 | 56.5 | 24.6 | 11.7 | 4.0 | 0.8 | 0.1 | 0.1 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ប្រុស | | | | | | | | | | |
| ចំនួន | 4 384 569 | 29.2 | 1.7 | 58.0 | 24.9 | 10.9 | 3.5 | 0.7 | 0.1 | 0.1 |
| 7–14 | 1 375 568 | 47.6 | 2.3 | 88.3 | 8.7 | 0.7 | - | - | 0.0 | 0.0 |
| 15–24 | 1 018 284 | 18.5 | 0.7 | 48.8 | 32.2 | 14.3 | 3.3 | 0.6 | 0.1 | 0.1 |
| 25+ | 1 990 717 | 22.0 | 2.0 | 48.8 | 28.6 | 13.8 | 5.3 | 1.1 | 0.2 | 0.1 |
| ស្រី | | | | | | | | | | |
| ចំនួន | 4 841 052 | 44.8 | 1.8 | 69.5 | 19.4 | 7.3 | 1.7 | 0.2 | 0.0 | 0.1 |
| 7–14 | 1 310 205 | 49.2 | 2.2 | 88.2 | 8.9 | 0.7 | - | - | 0.0 | 0.0 |
| 15–24 | 1 071 661 | 29.1 | 0.8 | 59.0 | 28.0 | 9.9 | 2.0 | 0.2 | 0.0 | 0.0 |
| 25+ | 2 459 186 | 49.3 | 2.2 | 66.0 | 19.7 | 9.2 | 2.4 | 0.4 | 0.1 | 0.1 |
| ២០០៨ | | | | | | | | | | |
| ទាំងពីរភេទ | | | | | | | | | | |
| ចំនួន | 11 435 11 | 21.7 | 2.4 | 48.9 | 28.6 | 17.0 | 1.6 | 1.5 | 0.1 | 0.0 |
| 7–14 | 2 553 226 | 19.0 | 1.7 | 76.5 | 21.0 | 0.9 | - | - | 0.0 | 0.0 |
| 15–24 | 2 988 492 | 12.5 | 1.6 | 29.8 | 37.6 | 27.0 | 1.9 | 2.0 | 0.0 | 0.0 |
| 25+ | 5 893 398 | 27.4 | 3.2 | 47.2 | 26.7 | 18.7 | 2.2 | 1.8 | 0.1 | 0.0 |
| ប្រុស | | | | | | | | | | |
| ចំនួន | 5 512 476 | 16.0 | 2.0 | 45.0 | 29.3 | 19.6 | 2.0 | 1.9 | 0.1 | 0.0 |
| 7–14 | 1 311 228 | 19.5 | 1.8 | 77.6 | 19.8 | 0.8 | - | - | 0.0 | 0.0 |
| 15–24 | 1 503 759 | 10.6 | 1.5 | 27.9 | 36.9 | 29.3 | 2.1 | 2.3 | 0.0 | 0.0 |
| 25+ | 2 697 489 | 17.3 | 2.4 | 39.9 | 29.4 | 22.6 | 2.9 | 2.6 | 0.1 | 0.0 |
| ស្រី | | | | | | | | | | |
| ចំនួន | 5 922 640 | 26.9 | 2.7 | 53.0 | 27.8 | 14.2 | 1.2 | 1.0 | 0.0 | 0.0 |
| 7–14 | 1 241 998 | 18.4 | 1.5 | 75.3 | 22.2 | 1.0 | - | - | 0.0 | 0.0 |
| 15–24 | 1 484 733 | 14.5 | 1.6 | 31.9 | 38.4 | 24.5 | 1.8 | 1.8 | 0.0 | 0.0 |
| 25+ | 3 195 909 | 36.0 | 4.1 | 55.1 | 23.9 | 14.5 | 1.4 | 1.0 | 0.1 | 0.0 |

ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨
- NIS/MOP ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨

## ២.៤ អត្រាចំណោលប្រជាជន

រូប ២.២ បង្ហាញអំពីការធ្វើចំណោលប្រជាពស្ត្ររហូតដល់ឆ្នាំ ២០១៥ ។ ដូចបានបញ្ជាក់សមា មាត្រប្រជាពស្ត្រពេញវ័យក្នុងអាយុធ្វើការ និងយុវជនរំពឹងថានឹងកើនឡើងខណៈដែលចំនួនកុមារ នឹងថយ ចុះ ។ ចំណោលប្រជាពស្ត្រសម្រាប់ឆ្នាំ ២០១៥ បង្ហាញអត្រាកំណើនមធ្យមប្រចាំឆ្នាំមាន ១,៣ ភាគរយ ទន្ទឹមនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំសម្រាប់អាយុ ២៥-៥៤ ឆ្នាំដែលក្រុមអាយុធ្វើការមាន ៣ ភាគរយ។ នេះបានបង្ហាញពីចំនួនប្រជាជនកម្ពុជាចូលរួមក្នុងកម្លាំងពលកម្ម និងការបង្កើតការងារសម្រាប់កម្លាំង ពលកម្មថ្មី ។

រូបភាព ២.២ ចំណោលប្រជាពស្ត្រឆ្នាំ ២០០៩ -២០១៥




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

## ២.៥ កំណត់សំគាល់សង្ខេប

លទ្ធផលជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ ២០០៨ បានឲ្យដឹងថាអត្រាកំណើនប្រជាជនប្រចាំឆ្នាំ ១,៥ ភាគរយចន្លោះឆ្នាំ ១៩៩៨ និង ២០០៨ ដែលនៅលើសអត្រាកំណើនមធ្យមប្រចាំឆ្នាំនៅក្នុងតំបន់ ១,២ ភាគរយ ហើយលទ្ធផលជំរឿនឆ្នាំ ២០០៨ មានប្រជារាស្ត្រទាំងអស់ ១៣,៤ លាននាក់ ។ កម្ពុជានៅតែជា ប្រទេសដែលមានចំនួនប្រជារាស្ត្រវ័យក្មេងច្រើនគឺប្រមាណ ៣ ភាគនៃប្រជាជនអាយុ ១៤ ឆ្នាំ ឬតិចជាង ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ចំនួននេះបានថយចុះធៀបនឹងឆ្នាំ ១៩៩៨ ។ អត្រាលទ្ធភាពបង្កើតកូនបាន ថយចុះផងដែរ ប្រហែលដោយសារការកើនឡើងនៃវិស័យសិក្សាអប់រំក្នុងចំណោមប្រជារាស្ត្រ ជាពិសេសស្ត្រី ។ សមាមាត្រស្ត្រីក្នុងចំណោមប្រជារាស្ត្រទាំងអស់មាន ៥១,៤ ភាគរយ ។ ការកើនឡើងសំបើមនៃ អក្ខរភាពនៅចន្លោះ ឆ្នាំ ១៩៩៨ និង ២០០៨ ដែលស្ត្រីមានអត្រាកំណើនខ្ពស់ជាងបុរស ។ ប៉ុន្តែមួយចំនួន នៃពួកគេ គឺមិនបានបញ្ចប់កំរិតបឋមសិក្សាមាន ៤៨,៩ ភាគរយ ។

ផលធៀបអាយុក្នុងបន្ទុកក៏ថយចុះផងដែរ ដោយសារប្រជាជនក្នុងអាយុធ្វើការកើនឡើងច្រើនជាង ប្រជារាស្ត្រជាកុមារ និងមនុស្សចាស់ ។ ប្រជារាស្ត្រក្នុងអាយុធ្វើការចេះអក្សរបច្ចុប្បន្នក៏មានច្រើនជាង បើធៀបនឹងដប់ឆ្នាំមុន ។ ប្រជារាស្ត្រក្នុងអាយុធ្វើការបានកើនឡើងពី ៥៣,៧ ភាគរយក្នុងឆ្នាំ ១៩៩៨ ទៅ ៦២ ភាគរយនៅ ឆ្នាំ ២០០៨ មានន័យថាកម្លាំងពលកម្មបានរីកធំឡើង ។ អត្រាកំណើនប្រជារាស្ត្រតាមការ

ធ្វើចំណោលបង្ហាញថា
អត្រាកំណើនប្រជារាស្រ្តក្នុងអាយុធ្វើការនឹងបន្តកើនឡើងរហូតដល់ឆ្នាំ ២០១៥ ។ នេះអាចផ្តល់ប្រយោជន៍ជាវិជ្ជមានសម្រាប់ប្រទេស
ក្នុងការបង្កើតគោលនយោបាយដ៏ត្រឹមត្រូវមួយ ។ ស្របពេលជាមួយគ្នានេះដែរ វាក៏ជាបញ្ហាប្រឈមផងដែរសម្រាប់ការបង្កើតការងារដល់កម្លាំងពលកម្ម ដ៏ច្រើននេះ ។

# ជំពូក ៣

## និន្នាការទីផ្សារការងារ និងសេដ្ឋកិច្ចសង្គម

ជំពូកនេះផ្តល់ការបកស្រាយសង្ខេបអំពីនិន្នាការទីផ្សារការងារ និងសេដ្ឋកិច្ចសង្គមសំខាន់ៗក្នុងមួយ ទស្សវត្សរ៍កន្លងមក ។ ក្នុងរយៈពេលនេះប្រទេសកម្ពុជាបានទទួលបទពិសោធន៍លើការប្រែប្រួលសេដ្ឋកិច្ច និងសង្គមកិច្ចយ៉ាងលឿន ដោយការផ្លាស់ប្តូរពីជំលោះក្នុងសង្គមទៅកាន់ស្ថេរភាព និងកំណើនសេដ្ឋកិច្ច ។ ការខិតខំប្រឹងប្រែងអភិវឌ្ឍន៍ គឺជាកំណើនប្រកបដោយចិរភាព ការកាត់បន្ថយភាពក្រីក្រ និងពន្លឿនដើម្បី បញ្ចប់របៀបវារៈនៃកំណែទំរង់របស់រដ្ឋាភិបាល ។ ជំពូកនេះលើកយកសមិទ្ធផល និងបញ្ហាប្រឈមដែល ប្រទេសជួបប្រទះក្នុងសង្គម និងសេដ្ឋកិច្ច។

### ៣.១ និន្នាការសេដ្ឋកិច្ចសង្គម

#### ៣.១.១ ផលិតផលក្នុងស្រុកសរុប

អត្រាកំណើនមធ្យមប្រចាំឆ្នាំនៃ GDP គិតឆ្នាំ ២០០១ និង ឆ្នាំ ២០០៧ មាន ៩,៦ ភាគរយ ។ កំណើន GDP ខ្ពស់បំផុត គឺក្នុងរវាងឆ្នាំ ២០០៤ និង ២០០៧ ដែលគួរឲ្យកត់សំគាល់ក្នុងអត្រាខ្ពស់ ១៣,៣ ភាគរយនៅឆ្នាំ ២០០៥ ។ ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់តិចតួចដោយសារវិបត្តិទីផ្សារ ហិរញ្ញវត្ថុសកលលោកនៅឆ្នាំ ២០០៨ ដែលផលប៉ះពាល់នេះអូសបន្លាយនៅរហូតដល់ឆ្នាំ ២០០៩ ។ ទោះជាយ៉ាងណាក៏ដោយក្នុងឆ្នាំ ២០០៨ សេដ្ឋកិច្ចកម្ពុជានៅរក្សាបាននូវស្ថានភាពល្អតាមអត្រាកំណើន ៦,៧ ភាគរយយោងតាមការ ប៉ាន់ស្មានបឋមតាមវិធីសាស្ត្រផលិតកម្ម [6]។

អត្រាកំណើនGDP តាមថ្លៃថេរឆ្នាំ ២០០០ មាន ១០,២ ភាគរយធៀប ១០,៨ ភាគរយក្នុងឆ្នាំ ២០០៦ និង ១៣,៣ ភាគរយនៅឆ្នាំ ២០០៥ ។

---

[6] តាមវិធីសាស្ត្រផលិតកម្ម GDP ស្មើនឹងសរុបតំលៃបន្ថែម (GVA) នៃគ្រប់វិស័យ ឬសកម្មភាពសេដ្ឋកិច្ចទាំងអស់ ។ GVA អាចគណនាដោយ យកតំលៃទំនិញ និងសេវាកម្មផលិតដោយវិស័យ (ផលិតផលសរុប) ហើយដកចំណាយទំនិញ ឬសេវាកម្មប្រើប្រាស់ដោយសហគ្រាសក្នុង ដំណើរការផលិតកម្ម (ចំណាយអន្តរការី) ។ ឧបសម្ព័ន្ធមានបង្ហាញពីការប៉ាន់ស្មានបឋមដោយវិទ្យាស្ថានជាតិស្ថិតិ លើ GDP តាមផលិតកម្ម សំរាប់ឆ្នាំ ២០០៨ តាមថ្លៃថេរឆ្នាំ ២០០០ ដែលកំណត់ដោយវិធីសាស្ត្រផលិតកម្ម ។

ការចំណាយនៃវិស័យឯកជនតាមថ្លៃថេរឆ្នាំ ២០០០ បាន កើនឡើង ៦,២ ភាគរយក្នុងឆ្នាំ ២០០៧ ធៀបជាមួយនឹងការកើនឡើង ៦,៨ ភាគរយនៅឆ្នាំ ២០០៦ ។

ចំណាយពិតរបស់រដ្ឋាភិបាលបានកើនឡើង ៨២,១ ភាគរយក្នុងឆ្នាំ ២០០៧ បន្ទាប់មកថយចុះ ៤,៩ ភាគរយក្នុងឆ្នាំ ២០០៦ និង ២,៩ ភាគរយនៅឆ្នាំ ២០០៥ ។ ការវិនិយោគបានកើនឡើងយឺតក្នុងឆ្នាំ ២០០៧ ១០,១ ភាគរយពីឆ្នាំ ២០០៦ ដែលកើនឡើង ១៦,៧ ភាគរយ ។ តាមថ្លៃថេរឆ្នាំ២០០០ ទំនិញ និងសេវាកម្មនាំចេញមានកំរិតខ្ពស់ ប៉ុន្តែកំណើនថយចុះក្នុងចន្លោះឆ្នាំ ២០០៦ និង២០០៧ គឺថយចុះពី ១៩,២ ភាគរយទៅ ១០,១ ភាគរយ ។ ការនាំចូលទំនិញ និងសេវាកម្មក៏បានកើនឡើង ១២,១ ភាគរយតាមថ្លៃថេរឆ្នាំ ២០០៧ បន្ទាប់ពីកើនឡើង ១៦ ភាគរយនៅឆ្នាំ២០០៦ ។

### តារាង ៣.១ អត្រាកំណើន GDP តាមការចំណាយតាមថ្លៃស្ថេរឆ្នាំ ២០០០ ឆ្នាំ ២០០១-២០០៧ (%)

| ពិពណ៌នា | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ |
|---|---|---|---|---|---|---|---|
| ចំណាយវិស័យឯកជន | 2.3 | 5.9 | 8.1 | 12.5 | 12.3 | 6.8 | 6.2 |
| ចំណាយរដ្ឋាភិបាល | 8.9 | 9.9 | 4.8 | -6.7 | 2.9 | -4.9 | 82.1 |
| ការវិនិយោគទុន | -4.2 | 27.5 | 7.3 | 11.0 | 19.5 | 16.7 | 10.1 |
| ការនាំចេញ | 16.7 | 13.0 | 11.1 | 28.1 | 16.4 | 19.2 | 10.1 |
| ការនាំចូល | 10.2 | 14.5 | 12.9 | 19.8 | 17.3 | 16.0 | 12.1 |
| **GDP** | **7.4** | **6.6** | **8.5** | **10.3** | **13.3** | **10.8** | **10.2** |

ប្រភព  វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

យោងតាមទិន្នន័យជាច្រើន កំណើនសេដ្ឋកិច្ចកម្ពុជាបានកើនខ្ពស់អាស្រ័យដោយការវិនិយោគផ្ទាល់ ពីបរទេស និងពាណិជ្ជកម្ម ។ ដូច្នេះវិធានការកម្មវិធី និងគោលនយោបាយរបស់រាជរដ្ឋាភិបាលបច្ចុប្បន្ន ត្រូវបានរៀបចំ និងអនុវត្តដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន ឬហានិភ័យសេដ្ឋកិច្ច និងបន្តការគាំទ្រស្ថេរភាពសេដ្ឋកិច្ច ក្នុងនោះដូចជាស្ថេរភាពថ្លៃអតិផរណាទាប ពង្រីកផលិតផល និងការនាំចេញ និងអត្រា ប្តូរប្រាក់ប្រែប្រួលបន្តិចបន្តួច ។

ផលិតផលក្នុងស្រុកសរុបពិត (Real GDP) សម្រាប់មនុស្សម្នាក់ស្មើនឹង ២,០៤៨ លានរៀល (៥០៣ ដុល្លារ) នៅឆ្នាំ ២០០៨ កើនឡើង ៥,២ ភាគរយពីឆ្នាំ ២០០៧ ។ GDP ពិតសម្រាប់ម្នាក់កើនជា មធ្យមប្រមាណ ៨,៨ ភាគរយ ក្នុងរយៈកាល៥ ឆ្នាំកន្លងមក ។

### តារាង ៣.២ GDP សម្រាប់មនុស្សម្នាក់ៗ តាមថ្លៃស្ថេរឆ្នាំ ២០០០ ឆ្នាំ ២០០២-២០០៨

| ពិពណ៌នា | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨p/ |
|---|---|---|---|---|---|---|---|
| GDP សម្រាប់មនុស្សម្នាក់(គិតជា ១០០០ រៀល) | 1,258 | 1,344 | 1,461 | 1,630 | 1,793 | 1,947 | 2,048 |
| អត្រាកំណើនគិតជាភាគរយ | 5.8 | 6.8 | 8.7 | 11.6 | 10.0 | 8.6 | 5.2 |
| GDP សម្រាប់មនុស្ស | 321 | 338 | 364 | 398 | 434 | 480 | 503 |

| (គិតជាដុល្លារអាមេរិក) | | | | | | | |
|---|---|---|---|---|---|---|---|
| អត្រាកំណើនគិតជាភាគរយ | 5.8 | 5.4 | 7.6 | 9.5 | 9.0 | 10.5 | 5.0 |

ប្រភព - វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

- កំណត់សំគាល់ p/ = ប៉ាន់ស្មានបឋម

រូប ៣.១ បង្ហាញពីការរួមចំណែករបស់វិស័យកសិកម្មទៅនឹងGDP តាមថ្លៃថេរ (២៦,៥ ភាគរយ) ទាបជាងឆ្នាំ ២០០១ (៣៩,៤ ភាគរយ) ។ នេះគឺដោយសារការថយចុះផលិតផលដំណាំ ជាពិសេសស្រូវ ។ ផលិតផលកសិកម្មនៅពឹងផ្អែកលើធម្មជាតិ ហើយបានធ្លាក់ចុះដោយសារភាពរាំងស្ងួត ទឹកជំនន់ និងជំងឺ ។ ផែនការអភិវឌ្ឍន៍កសិកម្មឆ្នាំ ២០០១-២០០៥ មានគោលដៅដើម្បីធ្វើឲ្យមាននិរន្តរភាពកសិកម្ម និង សម្រេចបាន និងធានាសន្តិសុខស្បៀង ហើយនឹងអភិរក្សធនធានធម្មជាតិ[7] ។ ការរួមចំណែកក្នុង GDP ដោយវិស័យពាណិជ្ជកម្ម សណ្ឋាគារ និងភោជនីយដ្ឋាន និងដឹកជញ្ជូន និងទូរគមនាគមន៍ក៏ធ្លាក់ចុះផងដែរ ក្នុងឆ្នាំ ២០០៨ ។ ការភ្ជាប់ផលិតកម្មទៅនឹងការចំណាយ ឬអ្នកផលិតទៅនឹងអ្នកប្រើប្រាស់ពាណិជ្ជកម្ម ជាកត្តាលីករដ៏មានឥទ្ធិពល និងសំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ។ ការលើកស្ទួយពាណិជ្ជកម្ម ក្នុងផលិតផលកម្ពុជា គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពចម្បងផ្សេងទៀតរបស់រាជរដ្ឋាភិបាល ។

ចាប់តាំពីឆ្នាំ ២០០១ ក្របខ័ណ្ឌគោលនយោបាយពាណិជ្ជកម្មសម្រាប់លើកកំពស់ពាណិជ្ជកម្មក្នុង និងក្រៅប្រទេសត្រូវបានអនុវត្តន៍ដើម្បីលើកកំពស់កំណើន និងរួមចំណែកកាត់បន្ថយភាពក្រីក្រ ។ ការចាប់ ផ្តើមគំរោង និងវិភាគការកំណែទំរង់ជាច្រើនត្រូវបានអនុវត្តន៍សម្រាប់ការនាំចេញ និងការធ្វើសមាហរកម្ម ប្រទេសចូលក្នុងតំបន់ហើយក៏ដូចជាការចូលក្នុងអង្គការពាណិជ្ជកកម្មពិភពលោកនៅឆ្នាំ ២០០៤ ។ រាជរដ្ឋា ភិបាល បានធ្វើការចរចារប្រកបដោយជោគជ័យនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងជាមួយបណ្តា ប្រទេសជាច្រើន ។

ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានភាពយឺតយ៉ាវ ដូចការវិនិយោគវិស័យឧស្សាហកម្មឯកជន ដែលរាំងខ្ទប់ការរីកចំរើនក្នុងវិស័យនេះ ។ កម្មវិធីវេទិការសម្រាប់វិស័យពាណិជ្ជកម្មទូទៅ បច្ចុប្បន្នត្រូវបាន រៀបចំ ។ បញ្ហាប្រឈមចំពោះមុខបន្ទាន់ គឺដើម្បីធានាដល់កិច្ចព្រមព្រៀងពាណិជ្ជកម្ម ដែលបានអនុវត្តន៍ ដោយពាណិជ្ជកម្មឯកជន

[7] គោលនយោបាយដាក់ឡើងដើម្បីសំរេចគោលដៅដោយរាប់បញ្ចូល i/ បង្កើនផ្ទៃដីដាំដុះ ii/ ពង្រីកប្រព័ន្ធស្រោចស្រប់កសិកម្ម iii/ ធានា សុវត្ថភាពការធ្វើអាជីវកម្មលើផ្ទៃដី និងការពារការធ្វើអាជីវកម្មលើផ្ទៃដីខុសច្បាប់ iv/ បន្តការអនុវត្តគោលនយោបាយទឹកសំរាប់ការងារកសិកម្ម និង v/ លើកកំពស់បណ្តាញហិរញ្ញទានជនបទដើម្បីផ្តល់ប្រាក់កំចីដល់កសិករ និងផ្សេងទៀត ។

ក្នុងការបញ្ជូនផលិតផលកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ដើម្បីពង្រីកផលិតផល នាំចេញ និងសំរាលបន្ទុកដល់វិស័យឧស្សាហកម្មកាត់ដេរ [8]។

វិស័យកម្មន្តសាល និងសេវាកម្មផ្សេងៗបានរួមចំណែកជិត ២០ ភាគរយនៃផលិតផលក្នុងស្រុក សរុបតាមថ្លៃថេរឆ្នាំ ២០០០ នៅឆ្នាំ ២០០៨ ដែលមានអត្រាខ្ពស់ជាងនៅឆ្នាំ ២០០១ (១៧,១ ភាគរយ សម្រាប់វិស័យកម្មន្តសាល និង ១៦,៦ ភាគរយសម្រាប់វិស័យហិរញ្ញវត្ថុ និងសេវាកម្មផ្សេងៗ ។ វិស័យសំណង់ បានរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបដោយកើនពី ៤,៧ ភាគរយ ទៅ ៦,៦ ភាគរយ (រូប ៣.១) ។ ការពង្រីកក្នុងវិស័យកម្មន្តសាល បានរួមចំណែកបង្កើនផលិតផលតម្បាញ សំលៀកបំពាក់ និងស្បែកជើង ហើយនិងម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ ។

រូប ៣.១ ការរួមចំណែកក្នុង GDP តាមថ្លៃថេរឆ្នាំ ២០០០ ឆ្នាំ ២០០១- ២០០៨ (%)




ប្រភព - វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

- កំណត់សំគាល់ p/ = ប៉ាន់ស្មានបឋម

## ៣.១.២ ពាណិជ្ជកម្ម និង ការវិនិយោគផ្ទាល់ពីបរទេស

តាមថ្លៃថេរឆ្នាំ ២០០០ ការនាំចេញទំនិញ និងសេវាកម្មបានកើនឡើង ១០,១ ភាគរយក្នុងឆ្នាំ ២០០៧ បន្ទាប់ពីកើនឡើង ១៦,៤ ភាគរយ និង ១៩,២ ភាគរយក្នុងឆ្នាំ ២០០៥ និង ២០០៦ តាមលំដាប់ រៀង ។ ការនាំចូលទំនិញ និងសេវាកម្មបានកើនឡើង១២,១ ភាគរយក្នុងឆ្នាំ ២០០៧ បន្ទាប់ពីកើនឡើង ១៧,៣ ភាគរយ និង ១៦ ភាគរយ ក្នុងឆ្នាំ ២០០៥ និង ២០០៦ តាមលំដាប់រៀងគ្នា ។

តារាង ៣.៣ ពាណិជ្ជកម្មតាមថ្លៃថេរ ឆ្នាំ ២០០០ (គិតជាពាន់រៀលដុល្លារ)

| ការនាំចេញ និងនាំចូល | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ |
|---|---|---|---|---|---|---|
| ការនាំចេញទំនិញ និងសេវាកម្ម | **9 259** | **10 284** | **13 174** | **15 333** | **18 275** | **20 129** |
| % ផលិតផលក្នុងស្រុកសរុប | 57.0 | 58.4 | 67.8 | 69.7 | 75.0 | 74.9 |
| អត្រាកំណើន ជាភាគរយ % | 13.0 | 11.1 | 28.1 | 16.4 | 19.2 | 10.1 |
| ការនាំចូលទំនិញ និងសេវាកម្ម | **10 983** | **12 405** | **14 864** | **17 438** | **20 220** | **22 659** |
| % ផលិតផលក្នុងស្រុកសរុប | 67.7 | 70.4 | 76.5 | 79.2 | 82.9 | 84.3 |

[8] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦- ២០១០ ក្រសួងផែនការ

| | | | | | | |
|---|---|---|---|---|---|---|
| អត្រាកំណើនជាភាគរយ% | 14.5 | 12.9 | 19.8 | 17.3 | 16.0 | 12.1 |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

ការវិនិយោគផ្ទាល់ពីបរទេស (FDI) មាននិន្នាការថយចុះនៅកម្ពុជាពីឆ្នាំ ២០០២ ទៅ ២០០៣ បន្ទាប់មកបានកើនឡើងខ្លាំងរហូតដល់ឆ្នាំ ២០០៧ មុនពេលធ្លាក់ចុះបន្តិចម្តងទៀតនៅឆ្នាំ ២០០៨ ។ ក្នុងឆ្នាំ ២០០៧ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) បានកើនដល់ចំណុចប្រវត្តិសាស្ត្រគឺ ៨៦៧,៣ លាន ដុល្លារអាមេរិក ។ ភាគច្រើននៃលំហូរការវិនិយោគពីបរទេសមកពីសាធារណរដ្ឋកូរ៉េ និងម៉ាឡេស៊ីនៅឆ្នាំ ២០០៨ និងភាគច្រើនវិនិយោលើវិស័យទូរគមនាគមន៍ កាត់ដេរ ធនាគារពាណិជ្ជកម្ម (មើលឧបសម្ព័ន្ធ តារាង ៦ និង តារាង ៨) ។

រូប ៣.២ លំហូរការវិនិយោគផ្ទាល់ពីបរទេស (គិតជាលានដុល្លារអាមេរិក)




ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងធនាគារជាតិនៃកម្ពុជា

សំគាល់: ទិន្នន័យបណ្តោះអាសន្នសម្រាប់ឆ្នាំ ១៩៩៩ ដល់ ២០០៩ នឹងអាចមានការផ្លាស់ប្តូរ

## ៣.១.៣ អតិផរណា និងការចំណាយប្រើប្រាស់

អតិផរណាបានកើនឡើងយ៉ាងខ្លាំងពី ៥,៨ ភាគរយក្នុងឆ្នាំ ២០០៧ ទៅ ១៩,៧ ភាគរយក្នុងឆ្នាំ ២០០៨ មូលហេតុចំបង គឺដោយសារការឡើងថ្លៃម្ហូបអាហារ ។ ថ្លៃម្ហូបអាហារសកលលោកបានកើនឡើង ដោយកត្តាជាច្រើន រួមមានការឡើងយ៉ាងរហ័សនៃតំរូវការ សន្និធិសកលលោកទាប និងថ្លៃប្រេងខ្ពស់ ។ បន្ថែមទៅលើកម្រិតទាបនៃសន្និធិម្ហូបអាហារនៅសកលលោកមានកំរិតទាប និងចំណាយផលិតកម្ម និងដឹក ជញ្ជូនមានតម្លៃខ្ពស់ អង្ករលើពិភពលោកដែលកំណត់ដោយបណ្តាប្រទេសនាំចេញ និងការទិញអង្ករពី ប្រទេសនាំចូលតាមថ្លៃខ្ពស់ជាង[9]។ អតិផរណា និងវិបត្តិម្ហូបអាហារក្នុងឆ្នាំ ២០០៨ ជាលទ្ធផលការកើន ឡើងខ្ពស់នៃថ្លៃម្ហូបអាហារ

[9] United Nations. June 2008. *Cambodia: Rising food prices*, Discussion paper

ជាសញ្ញាបង្ហាញភាពងាយរងគ្រោះខាងម្ហូបអាហារចំពោះគ្រួសារក្រីក្រ រាប់បញ្ចូលទាំងអ្នកក្រនៅទីប្រជុំជន ។ ក្នុងអវត្តមាននៃសំណាញ់សុវត្ថិភាពសង្គមផ្លូវការគ្រួសារកម្ពុជាបាន ប្រឈមនឹងហានិភ័យជាច្រើន រួមមានជំងឺ កំណើននៃការផ្លាស់ប្តូរលំនៅដ្ឋាន បន្ថយការចូលរៀន និងបង្កើន ពលកម្មកុមារ[10]។

រូប ៣.៣ អតិផរណា (សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ភ្នំពេញ ខែ កក្កដា ដល់ខែ ធ្នូ ២០០០=១០០)




ប្រភព វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

ចំណាយចុងក្រោយសម្រាប់ការប្រើប្រាស់ (FCE) តាមថ្លៃថេរឆ្នាំ ២០០០ បានកើនឡើង ៩,៣ ភាគរយ ក្នុងឆ្នាំ ២០០៧ ធៀបជាមួយនឹងការកើនឡើង ១១,៩ ភាគរយនៅឆ្នាំ ២០០៥ និង ៦,២ ភាគរយនៅឆ្នាំ ២០០៦ ។ FCE ជាភាគរយនៃ GDP ធ្លាក់ចុះយ៉ាងខ្លាំងរវាងឆ្នាំ ២០០៦ និងឆ្នាំ ២០០៧ គឺពី ៨៩,៥ ភាគរយទៅ ៨៣,៧ ភាគរយនៅឆ្នាំ ២០០៧ (មើលឧបសម្ព័ន្ធតារាង ១១ )

រូប ៣.៤ ចំណាយសម្រាប់ការប្រើប្រាស់ចុងក្រោយតាមថ្លៃថេរឆ្នាំ ២០០០ (គិតជាពាន់លានរៀល)

[10] See for example ADB. *Protecting Cambodia's most vulnerable from food crisis.* Social Protection Policy Briefs. http://www.adb.org/Documents/Brochures/Social-Protection-Project-Briefs/CAM-Proj-Brief-Food-Assistance.pdf




ប្រភព គណនេយ្យជាតិកម្ពុជា ក្រសួងផែនការ p/=ការគណនាបឋម

## ៣.១.៤ ភាពក្រីក្រ និងវិសមភាព

ការគណនាភាពក្រីក្រ[11] ក្នុងតារាង ៣.៤ បង្ហាញថាប្រមាណ ៣៩ ភាគរយនៃប្រជារាស្ត្រកម្ពុជា រស់ក្នុងភាពក្រីក្រនៅឆ្នាំ ១៩៩៣/៩៤ និងថយមក ៣០,១ ភាគរយនៅឆ្នាំ ២០០៧ (គណនាជាសន្ទស្សន៍ចំនួនមនុស្សធៀបនឹងបន្ទាត់ភាពក្រីក្រទូទៅនៅកម្ពុជា)។ សន្ទស្សន៍នៃចំនួនមនុស្សធៀបនឹងបន្ទាត់ភាពក្រីក្រ សម្រាប់ម្ហូបអាហារនៅកម្ពុជាបានថយចុះពី ២០ ភាគរយៈ កាលឆ្នាំ ១៩៩៣/៩៤ មក ១៨ ភាគរយនៅ ឆ្នាំ ២០០៧ ។ ទោះជាយ៉ាងណាក៏ដោយអត្រាភាពក្រីក្រមានភាពខុសគ្នាទៅតាមតំបន់នីមួយៗ ។

ខណៈដែលមានតែ ០,៨ ភាគរយនៃអ្នករស់នៅក្នុងរាជធានីភ្នំពេញចាត់ទុកថាក្រនៅឆ្នាំ ២០០៧ ហើយជិត ២២ ភាគរយនៃអ្នករស់នៅតំបន់ទីប្រជុំជនផ្សេងទៀត ។ នៅតំបន់ជនបទមានអត្រាភាពក្រីក្រមានជាង ៣៤ ភាគរយ ។ ក្នុងចំណោមប្រជារាស្ត្រក្រីក្រទាំងអស់មានជាង ៩២ ភាគរយរស់នៅតំបន់ជន បទធៀបជាមួយនឹង ៧,៥ ភាគរយនៅតំបន់ទីប្រជុំជន និង ០,៣ ភាគរយនៅរាជធានីភ្នំពេញ ។ ទាំងកំរិត និងចំនួននៃភាពក្រីក្រ គឺប្រមូលផ្តុំខ្ពស់នៅតំបន់ជនបទ ។

យុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល បានឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តដើម្បីកាត់ បន្ថយភាពក្រីក្រ និងវិសមភាពព្រមទាំងធ្វើឲ្យប្រសើរឡើងនូវគុណភាពរស់នៅ សម្រាប់ការកើនឡើង

[11] Poverty measures are calculated by comparing the estimates of per capita daily consumption in local currency for each individual in the sample to the updated poverty lines for the region in which each person resides

ដ៏លឿននៃប្រជារាស្ត្រកម្ពុជា ដូច្នេះគ្រប់ប្រជារាស្ត្រកម្ពុជាអាចទទួលបានផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច និងការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ ។ កម្មវិធីអាទិភាពរបស់រាជរដ្ឋាភិបាលដែលបានយល់ព្រមកាលពី ខែធ្នូ ឆ្នាំ ២០០២ បានផ្តោតលើ i/ ការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ii/ ធ្វើឲ្យប្រសើរឡើងកំរិតជីវភាព ជនបទ iii/ ពង្រីកឱកាសការងារ iv/ កែលម្អសមត្ថភាព v/ ពង្រឹងស្ថាប័ន និងអភិបាលកិច្ចល្អ vi/ កាត់បន្ថយភាពងាយរងគ្រោះ និងពង្រឹងសុវត្ថិភាពក្នុងសង្គម vii/ លើកកំពស់សមភាពយេនឌ័រ និងviii/ យកចិត្តទុកដាក់លើកំណើនប្រជារាស្ត្រ ពិសេសផ្តោតលើសុខភាពបន្តពូជ និងសេវាកម្មផែនការគ្រួសារ សម្រាប់ជនក្រីក្រ ។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) បានអនុវត្តន៍យ៉ាងទូលំទូលាយ ហើយគំរោងកំណត់អត្តសញ្ញាណភាពក្រីក្រ បានអនុវត្តដើម្បីលើកស្ទួយជីវភាពជនបទមានភាពប្រសើរឡើង លើកកំពស់ឱកាសការងារ ធានាភាពប្រសើរនៃសុខភាពអាហារូបត្ថម្ភ និងលទ្ធផលវិស័យអប់រំ និងកាត់ បន្ថយភាពងាយរងគ្រោះ ។

### តារាង ៣.៤ ការប៉ាន់ស្មានភាពក្រីក្រតាមតំបន់

| តំបន់ | ១៩៩៣/៩៤ | | ២០០៤ | | ២០០៧ | |
|---|---|---|---|---|---|---|
| | សន្ទស្សន៍ (%) | (%) ភាពក្រីក្រ | សន្ទស្សន៍ (%) | (%) ភាពក្រីក្រ | សន្ទស្សន៍ (%) | (%) ភាពក្រីក្រ |
| បន្ទាត់ភាពក្រីក្រ[12] | | | | | | |
| ភ្នំពេញ | 11.4 | 3.1 | 4.6 | 1.1 | 0.8 | 0.3 |
| ទីប្រជុំជន | 36.6 | 10.4 | 24.7 | 7.8 | 21.9 | 7.5 |
| ជនបទ | 43.1 | 86.5 | 39.2 | 91.1 | 34.7 | 92.3 |
| ប្រទេសកម្ពុជា | 39.0 | 100.0 | 34.7 | 100.0 | 30.1 | 100.0 |
| បន្ទាត់ក្រីក្រលើម្ហូបអាហារ * | | | | | | |
| ភ្នំពេញ | 6.2 | 3.3 | 2.6 | 1.1 | 0.1 | 0.1 |
| ទីប្រជុំជន | 19.6 | 10.8 | 14.2 | 7.8 | 12.7 | 7.3 |
| ជនបទ | 21.9 | 85.9 | 22.2 | 91.1 | 20.8 | 92.7 |
| ប្រទេសកម្ពុជា | 20.0 | 100.0 | 19.7 | 100.0 | 18.0 | 100.0 |

ប្រភព: - ធនាគារពិភពលោក WB 1993/94 ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជា
- ភ្នាក់ងារអភិវឌ្ឍអន្តរជាតិប្រទេស ស៊ុយអែត SIDA ២០០០ ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជា
- ធនាគារពិភពលោកWB 2007 និន្នាការស្ថានភាពនៃភាពក្រីក្រនៅកម្ពុជា

សំគាល់:SESC ១៩៩៣/៩៤ ទំហំសំណាកគំរូ ៥៩៨ ភូមិ ៥.៥៧៨ គ្រួសារ វិធីសាស្ត្រលើកឡើងវិញម្ហូបអាហារ ១៧៧ មុខ និងមិនមែនម្ហូប អាហារ ២៦៦ មុខ ។ SESC ២០០៤ ទំហំសំណាកគំរូ ៧២០ ភូមិ ១២.០០០ គ្រួសារ

[12] World Bank. June 2009. *Poverty profile and trends in Cambodia, Findings from the 2007 Cambodia socio-economic survey.*

វិធីសាស្ត្រប៉ាន់ស្មានរំលឹកឡើងវិញលើម្ហូបអាហារ ១៩ មុខ និងមិនមែនម្ហូបអាហារ ១៤ មុខ ។ SESC ២០០៧ ទំហំសំណាកគំរូ ៣៦០ ភូមិ ៣៦.០០០ គ្រួសារវិធីសាស្ត្រប៉ាន់ស្មានរំលឹកឡើងវិញ លើម្ហូបអាហារ ២០ មុខនិងមិនមែនម្ហូបអាហារ ១៦ មុខ ។ អង្កេតទាំងអស់ ទស្សនៈទាននិយមន័យនិងវិធីសាស្ត្រដូចគ្នា ប៉ុន្តែចំនួនសំណាកគំរូផ្សេងគ្នា ។ អង្កេតឆ្នាំ ១៩៩៣/១៩៩៤ មិនរាប់បញ្ចូលគ្រប់ខេត្តឡើយ។

*ការគណនាបន្ទាត់ភាពក្រីក្រលើចំណីអាហារ យោងការចំណាយក្រោមម្ហូបអាហារតាមពេលវេលាជាក់លាក់ដែលបានចំណាយសម្រាប់ ២១០០ កាឡូរី ក្នុងមនុស្សម្នាក់ (មធ្យមសម្រាប់មនុស្សគ្រប់អាយុ និងភេទ) ។

ដូចបានបង្ហាញក្នុងតារាង ៣.៥ មេគុណ Gini សម្រាប់កម្ពុជាបានកើនពី ០,៤០ ក្នុងឆ្នាំ ២០០០ ទៅ ០,៤៣ ក្នុងឆ្នាំ ២០០៧។ ទោះបីវិសមភាពចំណូលនៅរាជធានីភ្នំពេញបានថយចុះក្នុងអំឡុងពេលនោះ ក៏ការប៉ាន់ស្មានការថយចុះមិនជះឥទ្ធិពលខាងស្ថិតិឡើយ ។

### តារាង ៣.៥ មេគុណ Gini នៃវិសមភាពការចំណាយរបស់មនុស្សម្នាក់តាមតំបន់

| តំបន់ | ១៩៩៣/៩៤ | ២០០៤ | ២០០៧ |
|---|---|---|---|
| ភ្នំពេញ | 0.39 | 0.37 | 0.34 |
| ទីប្រជុំជនផ្សេងទៀត | 0.44 | 0.44 | 0.47 |
| ជនបទ | 0.27 | 0.34 | 0.36 |
| ប្រទេសកម្ពុជា | 0.38 | 0.40 | 0.43 |

ប្រភព: - ធនាគារពិភពលោកWB 1993/94 ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជា
- SIDA ក្រសួងផែនការ ២០០៤ ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជា
- ធនាគារពិភពលោក ២០០៧ ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជា

## ៣.២ និន្នាការទីផ្សារការងារ

### ៣.២.១ កម្លាំងពលកម្ម

កម្លាំងពលកម្មកម្ពុជា មានការផ្លាស់ប្តូរគួរឲ្យកត់សំគាល់ក្នុងមួយទសវត្សរ៍កន្លងមកដូច ទិន្នន័យបង្ហាញក្នុងរូប ៣.៥ (ឧបសម្ព័ន្ធតារាង ១៣) បានឆ្លុះបញ្ចាំងស្រាប់ ។ ឆ្នាំ ២០០៨ កម្លាំងពលកម្ម អាយុ ១៥ ឆ្នាំឡើងមានប្រមាណ ៧ លាននាក់ ដែលកើនឡើង ១,៩ លាននាក់ ពី ១៩៩៨ ឬកំណើន ជាមធ្យមប្រចាំឆ្នាំ ៣,៣ ភាគរយ ។ ក្នុងរយៈពេលនេះ អត្រាចូលរួមកម្លាំងពលកម្មបានកើនឡើងបន្តិចពី ៧៧ ភាគរយ ទៅ ៧៨,៣ ភាគរយ ឬ ១,៣ ភាគរយ ។ ការបែងចែកតាមភេទ បានឲ្យដឹងថា អាត្រា ចូលរួមកម្លាំងពលកម្ម បុរសមាន ៨០,៨ ភាគរយ (ថយចុះ ០,៤ ភាគរយ) និងស្ត្រីមាន ៧៦ ភាគរយ (កើនឡើង ២,៥ ភាគរយ) ។

ក្នុងចំណោមកម្លាំងពលកម្មទាំងអស់ យុវជនមានជាងមួយភាគបួនគឺ ២៥,៨ ភាគរយ ។ អត្រា ចូលរួមកម្លាំងពលកម្មយុវជនបានថយចុះបន្តិចពី ៦០,៧ ភាគរយ នៅឆ្នាំ ១៩៩៨ មក ៦០,១ ភាគរយនៅ ក្នុងឆ្នាំ ២០០៨ ។ នេះអាចបញ្ជាក់ពីនិន្នាការជាវិជ្ជមាននៃយុវជន បានចំណាយពេលវេលាច្រើនសម្រាប់ការសិក្សា ។ ជាទូទៅស្ត្រីវ័យក្មេងចូលរួម និងចេញពីកម្លាំងពលកម្មមុនបុរស ។ អត្រាសកម្មភាពសេដ្ឋកិច្ច របស់ស្ត្រីបន្តនៅខ្ពស់ជាងបុរសបន្តិចក្នុងអំឡុងមួយទសវត្សរ៍នេះ ។

អត្រាមនុស្សពេញវ័យចូលរួមកម្លាំងពលកម្ម បានកើនឡើងពី ៨៤,៧ ភាគរយ (ជិត ៣,៨ លាន នាក់) ក្នុងឆ្នាំ ១៩៩៨ ទៅ ៨៧,៥ ភាគរយ (៥,២ លាននាក់) ក្នុងឆ្នាំ ២០០៨ ។

អត្រាចូលរួមកម្លាំង ពលកម្មរបស់មនុស្សពេញវ័យខ្ពស់ ក្នុងចំណោមបុរស ហើយអត្រាមិនមានការប្រែប្រួលក្នុងអំឡុងមួយ ទស្សវត្សរ៍ ។ បើប្រៀបធៀបជាមួយឆ្នាំ ១៩៩៨ ចំនួនបុរសពេញវ័យ បានកើនឡើងជិត ៦៦៨.០០០ នាក់ ក្នុងឆ្នាំ ២០០៨ ។ ចំនួនស្ត្រីពេញវ័យបានកើនឡើង ៧២២.០០០នាក់ ឬ ៤,៨ ភាគរយ ។ ដូច្នេះគំលាតយេនឌ័រ ក្នុងអត្រាចូលរួមកម្លាំងពលកម្មរបស់មនុស្សពេញវ័យបានថយចុះក្នុងអំឡុងមួយទស្សវត្សរ៍ (ពី ១៦,៨ ភាគរយ ខុសគ្នាក្នុង ឆ្នាំ ១៩៩៨ ទៅ ១២,១ ភាគរយខុសគ្នាក្នុង ឆ្នាំ ២០០៨) ។

រូប ៣.៥ អត្រាចូលរួមកម្លាំងពលកម្មសម្រាប់ប្រជារាស្ត្រអាយុ ១៥ ឆ្នាំឡើង




## ៣.២.២ ការងារ

អត្រាប្រជារាស្ត្រ មានការងារធ្វើធៀបនឹងប្រជារាស្ត្រទាំងអស់ត្រូវបានកំណត់ជាសមាមាត្រនៃ ប្រជាជនក្នុងអាយុធ្វើការ ។ ផលធៀបខ្ពស់មានន័យថាសមាមាត្រខ្ពស់នៃប្រជារាស្ត្រក្នុងប្រទេសមានការ ងារធ្វើ ខណៈដែលផលធៀបតូចមានន័យថាចំនួនច្រើននៃប្រជារាស្ត្រមិនចូលរួមដោយផ្ទាល់ក្នុងសកម្មភាព ទាក់ទងទីផ្សារ ព្រោះពួកគេអាចគ្មានការងារធ្វើ ឬនៅក្រៅកម្លាំងពលកម្ម[13]។

ប្រជារាស្ត្រកម្ពុជាមានការងារធ្វើប្រែប្រួលក្នុងរយៈពេលមួយទស្សវត្សរ៍ (សូមមើលតារាង ១៥ ក្នុង ឧបសម័ន្ធ)។ នៅឆ្នាំ ២០០៨ ចំនួនប្រជារាស្ត្រមានការងារធ្វើអាយុ ១៥ ឆ្នាំឡើងមាន ៦,៨ លាននាក់ ឬកើន ឡើង ២,១ លាននាក់ (ជាមធ្យម ៣,៧ ភាគរយក្នុងមួយឆ្នាំ) ពីឆ្នាំ១៩៩៨ ។ អត្រាអ្នកមានការងារធ្វើធៀប នឹងប្រជារាស្ត្រកើនឡើង ៤ ភាគរយក្នុងអំឡុងពេលដូចគ្នានេះទៅ ៧៧ ភាគរយ ។ ពិនិត្យតាមភេទ អត្រា ប្រជារាស្ត្រមានការងារធ្វើធៀបនឹងប្រជារាស្ត្រទាំងអស់ សម្រាប់បុរសខ្ពស់ជាងស្ត្រីនៅឆ្នាំ ២០០៨ គឺ ៧៩,៦ ភាគរយ ទល់នឹង ៧៤,៧ ភាគរយ ។ នៅឆ្នាំ ១៩៩៨ បុរសមាន ៧៧,៤ ភាគរយ និងស្ត្រី ៦៩,២ ភាគរយ។

នៅឆ្នាំ ២០០៨ អត្រាយុវជនមានការងារធ្វើធៀបនឹងប្រជាជនទាំងអស់បានកើនឡើងប្រមាណ ៤,៨ ភាគរយ គឺមាន ៥៨,១ ភាគរយ ។ ធៀបទៅនឹងទិន្នន័យឆ្នាំ

[13] ILO. *Key indicators of the labour market*, Sixth Edition.

១៩៩៨ ចំនួនដាច់ខាតនៅ ឆ្នាំ ២០០៨ បានកើនឡើងជិត ៦២៣.០០០ នាក់ ។ ជាទូទៅអត្រាយុវជន មានការងារធ្វើធៀប នឹងប្រជាជនទាំងអស់ ជាស្ត្រីច្រើនជាងអត្រាបុរសទាំងពីរឆ្នាំ។ នេះដោយសារសមាមាត្រខ្ពស់នៃស្ត្រីវ័យក្មេង ធ្វើការឲ្យគ្រួសារដោយមិនយកប្រាក់ឈ្នួល ។ វាទំនងជាស្ត្រីចូលរួមក្នុងកម្លាំងពលកម្មមុនបុរសនេះដោយសារបុរស ចំណាយពេលវេលាក្នុងការសិក្សាយូរជាងស្ត្រី ។

អត្រាប្រជារាស្ត្រពេញវ័យ មានការងារធ្វើធៀបនឹងចំនួនប្រជារាស្ត្រទាំងអស់កើនឡើងពី ៣,៧ លាននាក់ (៨២,២ ភាគរយ) នៅក្នុងឆ្នាំ ១៩៩៨ ទៅ ៥,១ លាននាក់ (៨៦,៦ លននាក់) ក្នុងឆ្នាំ ២០០៨។ អត្រាប្រជារាស្ត្រពេញវ័យមានការងារធ្វើជាបុរសខ្ពស់ជាងស្ត្រីពេញវ័យ ។ ប៉ុន្តែបើពិនិត្យលើកំណើនវិញ ឃើញថាអត្រាបុរសកើនឡើងតិចតួចប៉ុណ្ណោះគឺ ១,៥ ភាគរយ ហើយស្ត្រីកើនច្រើនរហូតដល់ ៦,៥ ភាគរយ ។

រូប ៣.៦ អត្រាមានការងារធ្វើធៀបនឹងប្រជារាស្ត្រសម្រាប់កម្មករអាយុ ១៥ ឆ្នាំឡើង




ដូចបានកត់សំគាល់ពីមុនមកប្រជារាស្ត្រមានការងារធ្វើអាយុ ១៥ ឆ្នាំឡើងមាន ៦,៨ លាននាក់ ឬកើនឡើង ២,១ លាននាក់ (៤ ភាគារយ) ពីឆ្នាំ ១៩៩៨ ។ អត្រាកំណើនការងារមួយទស្សវត្សរ៍ស្មើនឹង ៤៣,៣ ភាគរយហើយអត្រាកំណើនជាមធ្យមប្រចាំឆ្នាំមាន ៣,៦ ភាគរយក្នុងចន្លោះមួយទស្សវត្សរ៍ ។ អត្រាកំណើនយុវជន មានការងារធ្វើមួយទស្សវត្សរ៍មាន ៥៥,៩ ភាគរយ ឬជាមធ្យមប្រចាំឆ្នាំ ៤,៤ ភាគរយ ខណៈដែល ៣៩,៥ ភាគរយ ក្នុងចំណោមប្រជាជនពេញវ័យ ឬជាមធ្យមប្រចាំឆ្នាំកើនឡើង ៣,៣ ភាគរយ ។

តារាង ៣.៦ អត្រាកំណើនការងារ

| ក្រុមអាយុ | ឆ្នាំ | | អត្រាកំណើន | |
|---|---|---|---|---|
| | ១៩៩៨ | ២០០៨ | មួយទស្សវត្សរ៍ (%) | ប្រចាំឆ្នាំ (%) |
| ទាំងពីរភេទ | | | | |
| 15+ | **4 773 488** | **6 841 272** | 43.3 | 3.6 |
| 15–24 | 1 114 189 | 1 736 962 | 55.9 | 4.4 |
| 25+ | 3 659 299 | 5 104 310 | 39.5 | 3.3 |
| ប្រុស | | | | |
| 15+ | **2 330 301** | **3 345 926** | 43.6 | 3.6 |
| 15–24 | 502 134 | 828 975 | 65.1 | 5.0 |
| 25+ | 1 828 167 | 2 516 951 | 37.7 | 3.2 |
| ស្រី | | | | |

| | | | | |
|---|---|---|---|---|
| 15+ | **2 443 187** | **3 495 346** | 43.1 | 3.6 |
| 15–24 | 612 055 | 907 987 | 48.4 | 3.9 |
| 25+ | 1 831 132 | 2 587 359 | 41.3 | 3.5 |

ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨

- NIS/MOP ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨

កំណត់សំគាល់: មានការងារធ្វើសំដៅលើមនុស្សទាំងឡាយណាដែលបានធ្វើការចាប់ពី ៦ ខែ (១៨៣ ថ្ងៃ) ឬច្រើនជាងក្នុងរយ: ពេលមួយឆ្នាំមុនពេលធ្វើជំរឿន i/ និយោជិកទទួលប្រាក់ឈ្នួល (ធ្វើការនៅស្ថប័នសាធារណ: ឬវិស័យឯកជន ។ល។) ii/ អ្នកដែល សន្មត់ថាមានការងារធ្វើ ដូចជាធ្វើការទទួលប្រាក់កំរៃ ប្រាក់ខែ ធ្វើការឲ្យគ្រួសារជាសាច់ប្រាក់ ឬជារបស់ iii/ អ្នកដែលមិនមានការងារធ្វើដោយសារ (រដូវកាល ដូចកសិករ ឬអ្នកនេសាទ) សំរាកដោយជំងឺ ឬឈប់មិនមានកំរៃ មិនអាចធ្វើការបានដោយសារ បាតុកម្ម ឬកន្លែងធ្វើការបិទទ្វារ iv/ អ្នកធ្វើការងារផ្ទាល់ខ្លួន (ដូចជាធ្វើអាជីវកម្មលក់ដូរដោយខ្លួនឯង លក់គ្រឿងហូបចុក ជាវេជ្ជ បណ្ឌិត អ្នកច្បាប់ ។ល។

## *ការងារតាមកំរិតសិក្សាអប់រំ*

ក្នុងចំណោម ៦,៨ លាននាក់នៃប្រជារាស្ត្រមានការងារធ្វើអាយុ ១៥ ឆ្នាំឡើងក្នុងឆ្នាំ ២០០៨ មាន ៧៥,៥ ភាគរយជាអ្នកចេះអាន និងសរសេរ ដែលបានកើនឡើង ២ លាននាក់ ស្មើនិង ៨,៦ ភាគរយចាប់ តាំងពីឆ្នាំ ១៩៩៨ ។ ក្នុងចំណោមនោះស្ត្រីមានការកើនឡើងខ្លាំងពី ៥៦,៣ ភាគរយ ក្នុងឆ្នាំ ១៩៩៨ ទៅ ៦៩,១ ភាគរយ ក្នុងឆ្នាំ ២០០៨ ទន្ទឹមនឹងសមាមាត្របុរសកើនពី ៧៨,៣ ភាគរយទៅ ៨២,៧ ភាគរយ (ឧបសម្ព័ន្ធ តារាង ១៩) ។

ដូច្នេះមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលសម្រាប់សមាមាត្រប្រជារាស្ត្រមានការងារធ្វើអាយុ ១៥ ឆ្នាំ ឡើងដែលជាអក្ខរជនថយចុះ ពី ៣៣ ភាគរយក្នុងឆ្នាំ ១៩៩៨ មកនៅត្រឹម ២៤,៣ ភាគរយនៅឆ្នាំ ២០០៨ នោះឡើយ ។ សមាមាត្រនៃអ្នកមានការងារធ្វើ ដែលមិនបានបញ្ចប់កំរិតបឋមសិក្សាក៏ថយចុះពី ៣៨,៦ ភាគរយមក ៣៩,៥ ភាគរយ ។ អ្នកដែលបានបញ្ចប់កំរិតបឋមសិក្សា ឬមធ្យមសិក្សាបឋមភូមិ បានកើន ឡើងពី ១៧,២ ភាគរយ ទៅ ២៣ ភាគរយ និង ៧,២ ភាគរយ ទៅ ១៣,៧ ភាគរយតាមលំដាប់រៀង ។ ជាអកុសល សមាមាត្រប្រជារាស្ត្រមានការងារធ្វើ ដែលបានបញ្ចប់ថ្នាក់មធ្យមសិក្សាបានថយចុះពី ២,៤ ភាគរយមក ១,៥ ភាគរយ ។

ទំរង់ស្រដៀងគ្នាក្នុងចំណោមយុវជន និងមនុស្សពេញវ័យ ។ ជាថ្មីម្តងទៀត ការប្រែប្រួល គឺជាការ ថយចុះនៃស្ត្រីអាយុ ១៥ ឆ្នាំឡើងដែលចាត់ជាអនក្ខរភាពពី ៤៣,៧ ភាគរយមកនៅ ៣០,៩ ភាគរយ ។ ប៉ុន្តែសមាមាត្រអ្នកមានការងារធ្វើជាស្ត្រីដែលមិនបានបញ្ចប់កំរិតបឋមសិក្សា (៣៦,១ ភាគរយ) នៅតែជាចំនួនធំជាងសមាមាត្របុរស (៣២,៨ ភាគរយ) ។ ម៉្យាងទៀត តាមកំរិតលំដាប់នៃការសិក្សាអប់រំដែល ទទួលបានសមាមាត្រស្ត្រី នៅមានកំរិតតូចជាងបុរសសម្រាប់តួលេខជំរឿនទាំងពីរ ។

### ប្រអប់-១
### ស្ត្រីមានការរីកចំរើនក្នុងការអប់រំ ប៉ុន្តែនៅតែមានគំលាតយេនឌ័រ

អក្ខរភាពក្នុងចំណោមស្ត្រី បានកើនឡើងខ្លាំងគួរឲ្យកត់សំគាល់ ។ ប៉ុន្តែលទ្ធភាពបានទទួលការអប់រំផ្អែក តាមលទ្ធផលជំរឿនបង្ហាញថា បុរសនៅតែច្រើនជាងស្ត្រីបានទទួលផលប្រយោជន៍ ។ គំលាតយេនឌ័រមាន

ទំនាក់ទំនងផ្ទាល់ទៅនឹងឱកាសការងាររបស់ស្ត្រី ។ ផែនការរាជរដ្ឋាភិបាល គឺដោះស្រាយដោយធ្វើអគុល្យ ការយេនឌ័រ ដោយបង្កើតកម្មវិធីអាហាររូបករណ៍សម្រាប់ក្មេងស្រី និងសាងសង់អនុវិទ្យាល័យច្រើនទៀត ដើម្បីបន្ថយចំងាយធ្វើដំណើរទៅសិក្សា ដែលអាចជំរុញក្មេងស្រីឲ្យបានចូលរៀននៅថ្នាក់អនុវិទ្យាល័យ ឬថ្នាក់ខ្ពស់ជាង ។ ទោះជាយ៉ាងណាក៏ដោយ ការប្តេជ្ញាចិត្ត និងការវិនិយោគនឹងត្រូវការបន្ថែមទៀតដើម្បីសម្រេចបាននូវគុណភាពអប់រំ ។ រាជរដ្ឋាភិបាលបានកំណត់គោលដៅដើម្បីលុបបំបាត់គំលាតយេនឌ័រក្នុង កំរិតវិទ្យាល័យ និងមហាវិទ្យាល័យនៅក្នុងឆ្នាំ ២០១៥ ប៉ុន្តែក៏ត្រូវការផងដែរក្នុងការធ្វើឲ្យកើនឡើងចំនួនបញ្ចប់កំរិតវិទ្យាល័យ ។ មានកំណើនសម្រាប់ចំនួនយុវជនបញ្ចប់កំរិតវិទ្យាល័យ ។

ប្រភព : ក្រសួងផែនការ ឆ្នាំ ២០០៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ រាជរដ្ឋាភិបាលកម្ពុជា

## *ការងារតាមវិស័យ*

ចំពោះការបែងចែកតាមវិស័យ សមាមាត្រនៃប្រជារាស្ត្រធ្វើការក្នុងវិស័យទីមួយ បានថយចុះក្នុង ទសវត្សរ៍ ខណៈដែលសមាមាត្រប្រជារាស្ត្រធ្វើការក្នុងវិស័យទីពីរ និងវិស័យទីបីបានកើនឡើង ។ មានន័យថាចំនួនច្រើនក្នុងវិស័យកសិកម្មបានថយចុះបន្តិចម្តងៗ ហើយភាពមានការងារត្រូវបានផ្លាស់ប្តូរ ។

ក្នុងឆ្នាំ ២០០៨ ប្រមាណ ៧២,១ ភាគរយនៃប្រជារាស្ត្រមានការងារធ្វើអាយុ ១៥ ឆ្នាំឡើងធ្វើការ ក្នុងវិស័យទីមួយ (កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ) បន្ទាប់មក ១៩,៣ ភាគរយអ្នកធ្វើការក្នុងវិស័យទីបី (សេវាកម្ម និងលក់ដូរ) និង ៨,៦ ភាគរយក្នុងវិស័យទីពីរ (ផលិតកម្ម) ។ នៅឆ្នាំ ១៩៩៨ វិស័យទាំងនេះ មានសមាមាត្រ ៧៧ ភាគរយ ១៨,៣ ភាគរយ និង ៤,២ ភាគរយ ។ ដូចបង្ហាញក្នុងតារាង ៣.៧ ប្រជារាស្ត្រស្ត្រីធ្វើការក្នុងវិស័យទី១ មានសមាមាត្រខ្ពស់ជាងបុរសទាំងនៅឆ្នាំ ១៩៩៨ និង ២០០៨ ។ ទិន្នន័យក៏ បានបង្ហាញផងដែរ ថាស្ត្រីមានតួនាទីចម្បងក្នុងផលិតកម្ម កសិកម្ម ទោះបីបុរស និងស្ត្រីមានភារកិច្ច ជាក់លាក់ខុសគ្នាក៏ដោយ ។

ជាទូទៅភារៈកិច្ចរបស់បុរសជាប់ទាក់ទងនឹងការងារប្រើកម្លាំង ឬប្រើបច្ចេកទេស និងម៉ាស៊ីន ។ ឧទាហរណ៍: ក្នុងការធ្វើស្រែ ស្ត្រីទទួលខុសត្រូវរៀបចំពូជ និងស្ទូង (ត្រាំពូជ សំអាតដី សាបព្រោះ និង ស្ទូង) បោចស្នៅ និងពិនិត្យការបំផ្លាញដោយជំងឺសត្វល្អិត ។ បុរសទទួលខុសត្រូវភ្ជួររាស់ ដាក់ទឹក ដាក់ជី ឬបាញ់ថ្នាំសំលាប់សត្វល្អិត និងបោកបែនស្រូវ (Norris et al., 2001) ។

### តារាង ៣.៧ ការងារតាមវិស័យ អាយុ និងភេទ

| ភេទ វិស័យ និងអាយុ | ១៩៩៨ | | | ២០០៨ | | |
|---|---|---|---|---|---|---|
| | 15+ | 15-24 | 25+ | 15+ | 15-24 | 25+ |
| ទាំងពីរភេទ | **4 773 488** | **1 114 189** | **3 659 299** | **6 841 272** | **1 736 962** | **5 104 310** |
| វិស័យទីមួយ | 77.0 | 79.1 | 76.4 | 72.1 | 68.6 | 73.3 |

| | | | | | | |
|---|---|---|---|---|---|---|
| វិស័យទីពីរ | 4.2 | 6.5 | 3.5 | 8.6 | 15.5 | 6.2 |
| វិស័យទីបី | 18.3 | 13.7 | 19.7 | 19.3 | 15.9 | 20.5 |
| មិនបានរាយការណ៍ | 0.4 | 0.7 | 0.4 | 0.0 | 0.0 | 0.0 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |
| **ប្រុស** | **2 330 301** | **502 134** | **1 828 167** | **3 345 926** | **828 975** | **2 516 951** |
| វិស័យទីមួយ | 71.1 | 75.7 | 69.8 | 69.2 | 70.6 | 68.7 |
| វិស័យទីពីរ | 5.0 | 6.2 | 4.7 | 8.1 | 11.9 | 6.9 |
| វិស័យទីបី | 23.4 | 17.2 | 25.1 | 22.7 | 17.5 | 24.4 |
| មិនបានរាយការណ៍ | 0.5 | 0.8 | 0.4 | 0.0 | 0.0 | 0.0 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |
| **ស្រី** | **2 443 187** | **612 055** | **1 831 132** | **3 495 346** | **907 987** | **2 587 359** |
| វិស័យទីមួយ | 82.7 | 81.9 | 82.9 | 75.0 | 66.9 | 77.8 |
| វិស័យទីពីរ | 3.5 | 6.8 | 2.4 | 9.0 | 18.7 | 5.6 |
| វិស័យទីបី | 13.5 | 10.8 | 14.3 | 16.0 | 14.4 | 16.6 |
| មិនបានរាយការណ៍ | 0.4 | 0.5 | 0.4 | 0.0 | 0.0 | 0.0 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |

ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨
- NIS/MOP ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨

## *ប្រជាពលរដ្ឋពេញវ័យ និងយុវជនគ្មានការងារធ្វើ*

អត្រាគ្មានការងារធ្វើ ជាទូទៅមានអត្រាទាបនៅកម្ពុជា ពីព្រោះប្រជាពលរដ្ឋភាគច្រើនក្នុងអាយុធ្វើ ការមិនអាចចំណាយពេលច្រើនសម្រាប់ស្វែងរក "ការងារសមស្រប" ។ នៅពេលដែលគ្មានផលតំលៃពីភាព គ្មានការងារ ឬការសន្សំរបស់គ្រួសារ អ្នកគ្មានការងារធ្វើ ជាទូទៅស្ថិតនៅក្រោមសម្ពាធដែលត្រូវទទួល យកការងារណាក៏ដោយសម្រាប់ជីវិតរស់នៅ ។

បន្ថែមពីនេះ អត្រាគ្មានការងារធ្វើ បានបង្ហាញនិន្នាការថយចុះក្នុងមួយទសវត្សរ៍ (តារាង ៣.៨) ។ អត្រាគ្មានការងារធ្វើក្នុងចំណោមប្រជាពលរដ្ឋទាំងអស់អាយុ ១៥ ឆ្នាំឡើងបានថយចុះពី ៥,៣ ភាគរយក្នុង ឆ្នាំ ១៩៩៨ មក ១,៦ ភាគរយនៅឆ្នាំ ២០០៨ ។ ក្នុងចំណោមពួកគេ អត្រាគ្មានការងារធ្វើជាស្ត្រី មានអត្រា ខ្ពស់បន្តិចបន្តួចនៅឆ្នាំ ២០០៨ ។ ជាទូទៅ អត្រាគ្មានការងារធ្វើនៅជនបទទាបជាងតំបន់ទីប្រជុំជន ព្រោះ ខ្វះប្រព័ន្ធសុវត្ថិភាពសង្គម និងមានចំនួនកម្មករច្រើនធ្វើការក្នុងវិស័យកសិកម្ម ដែលមានផលិតផលទាប ។

បើពិនិត្យមើលអត្រាគ្មានការងារធ្វើតាមអាយុជាក់លាក់ សមាមាត្រខ្ពស់ជាងគេ គឺក្នុងចំណោម យុវជន ។ អត្រាគ្មានការងារធ្វើរបស់យុវជនមាន ៣,៣ ភាគរយធៀបនឹងអត្រាមនុស្សពេញវ័យគ្មានការងារ ធ្វើ ដែលមានតែ ១,១ ភាគរយប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ អត្រាគ្មានការងារធ្វើក្នុងមួយទសវត្សរ៍ បានថយចុះក្នុងចំណោមយុវជនពី ១២,៣ ភាគរយទៅ ៣,៤ ភាគរយក្នុងចំណោមបុរស និង ១២ ភាគរយ ទៅ ៣,៣ ភាគរយក្នុងចំណោមស្ត្រី ។ និន្នាការនេះមានភាពស្រដៀងគ្នាចំពោះប្រជាពលរដ្ឋពេញវ័យ ទោះបី ការថយចុះ មានតែបន្តិចបន្តួចក៏ដោយ ។

ក្នុងចំណោមប្រជារាស្ត្រគ្មានការងារធ្វើអាយុ ១៥ ឆ្នាំឡើងក្នុងឆ្នាំ ២០០៨ មាន ៨០,៧ ភាគរយ គឺជាអ្នកចេះអក្សរ ។ ក្នុងនោះ ៣,៧ ភាគរយ មិនបានបញ្ចប់ថ្នាក់ណាមួយ ២៨,៥ ភាគរយមិនបានបញ្ចប់ កំរិតបឋមសិក្សា ២៥,២ ភាគរយបានបញ្ចប់ត្រឹមកំរិតបឋមសិក្សា ហើយ ១៩,៤ ភាគរយបានបញ្ចប់មធ្យមសិក្សាបឋមភូមិ ។ មានតែ ៣,៩ ភាគរយនៃអ្នកគ្មានការងារធ្វើបានបញ្ចប់កំរិតសិក្សាក្រោយមធ្យម សិក្សាបឋមភូមិ ។ សមមាត្រនៃយុវជន និងមនុស្សពេញវ័យគ្មានការងារធ្វើដែលមិនចេះអក្សរ ឬអ្នកដែលមិនទាន់បានបញ្ចប់កំរិតបឋមសិក្សា គ្មានកាងារធ្វើបានថយចុះទាំងប្រុស និងស្រីក្នុងមួយទស្សវត្សរ៍នេះ ។ ប៉ុន្តែមានការកើនឡើងអ្នកគ្មានការងារធ្វើដែលចេះអក្សរទាំងប្រុស និងស្រីដែលបានបញ្ចប់កំរិតបឋម សិក្សា និងមធ្យមសិក្សាបឋមភូមិ ឬក្រោយមធ្យមសិក្សាបឋមភូមិ (ឧបសម្ព័ន្ធ តារាង ២០) ។

### តារាង ៣.៨ អត្រាគ្មានការងារធ្វើ

| ក្រុមអាយុ | ១៩៩៨ | ២០០៨ |
|---|---|---|
| ទាំងពីរភេទ | | |
| 15+ | 5.3 | 1.6 |
| 15–24 | 12.2 | 3.3 |
| 25–64 | 2.9 | 1.1 |
| 65+ | 2.9 | 1.0 |
| ប្រុស | | |
| 15+ | 4.6 | 1.5 |
| 15–24 | 12.3 | 3.4 |
| 25–64 | 2.3 | 0.8 |
| 65+ | 2.0 | 0.8 |
| ស្រី | | |
| 15+ | 5.8 | 1.8 |
| 15–24 | 12.0 | 3.3 |
| 25–64 | 3.6 | 1.3 |
| 65+ | 3.9 | 1.3 |

ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨
- NIS/MOP ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨

### ប្រអប់ ២
### វិធានការដើម្បីកែលម្អការងាររបស់យុវជន

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ បានដាក់វិធានការដើម្បីអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ សម្រាប់កំណើនការងារសមធម៌និងប្រសិទ្ធភាព និងដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (CMDGs) ឆ្នាំ ២០១០ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ NSDP រួមមានគោលនយោបាយតាមប្រព័ន្ធ ដើម្បីបង្កើតការងារ បន្ថែម ជាពិសេសសម្រាប់យុវជនចូលក្នុងទីផ្សារការងារ តាមរយ:វិធានការជាច្រើន i) បង្កើនផលិតភាពកសិកម្ម ដើម្បីបង្កើតឱកាសការងារនៅជនបទដែលនឹងមានសារ:សំខាន់ដល់ប្រសិទ្ធភាពនៃចំរុះវិស័យ រួមទាំងការបង្កើន តំរូវការសម្រាប់ទំនិញ និងសេវាកម្ម ii) លើកទឹកចិត្តដល់ការវិនិយោគផ្ទាល់ក្នុងស្រុក និងពីបរទេសក្នុងវិស័យអាទិ ភាព ពិសេសកសិកម្ម កសិឧស្សាហកម្ម គំរោង និងឧស្សាហកម្មដែលត្រូវការកម្មករច្រើន

និងទេសចរណ៍ iii) បង្កើតបណ្តាញអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស ដើម្បីបំរើទាំងបុរស និងស្ត្រីតាមលក្ខណៈសមធម៌ ជាពិសេសអ្នកក្រីក្រ ពិការ និងដើម្បីក្រុមងាយរងគ្រោះ និងបំពេញតំរូវការទីផ្សារការងារ សម្រាប់រយៈពេលខ្លី និងរយៈពេលវែង iv) អភិវឌ្ឍទិន្នន័យមូលដ្ឋាននៃការងារ និងប្រព័ន្ធស្ថិតិដែលផ្តល់តួលេខបែងចែកតាមភេទ ពិការភាព និងកត្តាទាក់ទងសង្គមផ្សេងទៀត និង v) ជួយប្រជាពលរដ្ឋកម្ពុជាឲ្យស្វែងរកការងារនៅបណ្តា ប្រទេសផ្សេងទៀត ។

ប្រភព : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ រាជរដ្ឋាភិបាលកម្ពុជា

## *ការងារងាយរងគ្រោះ*

ទិន្នន័យជំរឿនឆ្នាំ ២០០៨ បានឲ្យដឹងពីចំនួនដ៏ធំនៃការងារងាយរងគ្រោះដែលកំណត់ដោយអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល និងអ្នកធ្វើការដោយប្រើទុនផ្ទាល់ខ្លួនដែលមាន ៨២,៥ ភាគរយនៃ ប្រជាពលរដ្ឋមានការងារធ្វើអាយុ ១៥ ឆ្នាំឡើង (ឧបសម្ព័ន្ធតារាង១៨) ។ ចំនួននេះកើនឡើង ៤,១ លាននាក់ នៅឆ្នាំ ១៩៩៨ ប៉ុន្តែសមាមាត្រថយចុះពី ៨៦,៨ ភាគរយ ។ នេះបង្ហាញថា ចំនួនអ្នកធ្វើការដ៏ច្រើនត្រូវបានចាត់ចូលក្នុងនិយមន័យការងារងាយរងគ្រោះ ។

សមាមាត្រនៃយុវជន និងប្រជាពលរដ្ឋពេញវ័យធ្វើការងារងាយរងគ្រោះបានថយចុះក្នុងអំឡុងមួយ ទស្សវត្សរ៍នេះ។ នៅឆ្នាំ ១៩៩៨ យុវជនទាំងពីរភេទ និងមនុស្សពេញវ័យស្ត្រី មានភាពលើសលប់ក្នុងការងារ នេះ ។ ទោះបីមានការថយចុះក្នុងសមាមាត្រយុវជនក្នុងមួយទស្សវត្សរ៍ក៏ដោយ ក៏ការថយចុះនេះមានទំហំធំ សម្រាប់ស្ត្រីមាន ១៥,៤ ភាគរយក្នុងឆ្នាំ ២០០៨ ធៀបជាមួយនឹង ៣,៩ ភាគរយសម្រាប់បុរស ។ ក្នុងចំណោម ប្រជាពលរដ្ឋដែលធ្វើការងារងាយរងគ្រោះស្ត្រី មានសមាមាត្រខ្ពស់ជាងពាក់កណ្តាល គឺ៥៣,១ ភាគរយ ។

ក្នុងចំណោមបុរសធ្វើការងារងាយរងគ្រោះ ភាគច្រើនជាកម្មករធ្វើការដោយប្រើទុនផ្ទាល់ខ្លួន ៦១,៥ ភាគរយនៅឆ្នាំ ១៩៩៨ និង ៥៤,៥ ភាគរយក្នុងឆ្នាំ ២០០៨ ។ ហើយភាគច្រើននៃស្ត្រី (៦២,១ ភាគរយក្នុងឆ្នាំ ១៩៩៨ និង ៦០,៦ ភាគរយក្នុងឆ្នាំ ២០០៨) ធ្វើការឲ្យគ្រួសារមិនទទួលប្រាក់ឈ្នួល ឬក៏ធ្វើការដោយមិនមានប្រាក់ឈ្នួល ។ សមាមាត្រនៃកម្មករធ្វើការងារដោយប្រើទុនផ្ទាល់ខ្លួន បានថយចុះ ក្នុងមួយទស្សវត្សរ៍នេះ ខណៈដែលសមាមាត្រនៃនិយោជិតទទួលប្រាក់ឈ្នួល និងធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួលបានកើនឡើង ។ សមាមាត្រអ្នកធ្វើការមិនយកប្រាក់ឈ្នួលចំណោមស្ត្រីធ្វើការបានថយចុះ បន្តិច ។ សមាមាត្រអ្នកធ្វើការដោយប្រើទុនផ្ទាល់ខ្លួនបានថយចុះ ខណៈដែលសមាមាត្រនៃនិយោជិតទទួល ប្រាក់ឈ្នួលបានកើនឡើងគួរឲ្យកត់សំគាល់ ។

រូប ៣.៧ សមាមាត្រការងារងាយរងគ្រោះធៀប និងការងារទូទៅ




ទោះបីការប៉ាន់ស្មានវិស័យ ការងារមិនរៀបរយ មិនអាចធ្វើទៅបាន តែភាគច្រើននៃអ្នកធ្វើការក្នុង ការងារងាយរងគ្រោះ គឺស្ថិតក្នុងសេដ្ឋកិច្ចមិនរៀបរយ ដែលការងារនេះមានចំណូលតិចតួច ហើយមិន ទទួលបានបណ្តាញការពារសង្គម ឬសន្តិសុខការងារ ឬចំណូល ហើយលក្ខខណ្ឌការងារជាទូទៅអន់ និង គ្មានតំណាងការងារ ។

## ៣.២.៣ បំលាស់ប្តូរលំនៅដ្ឋាន ដើម្បីការងារក្នុងស្រុក និងក្រៅស្រុក

ដូចបានបង្ហាញក្នុងតារាង ៣.៩ ចំនួនអ្នកផ្លាស់ប្តូរលំនៅដ្ឋានដើម្បីការងារក្នុងស្រុក[14] មានការកើន ឡើងក្នុងមួយទស្សវត្សរ៍ពី ២,៣ លាននាក់ ទៅ ២,៥ លាននាក់ ។ ភាគច្រើននៃពួកគេ រកការងារក្នុងវិស័យ ការងារទីមួយ ទោះបីសមាមាត្រនៃពួកគេបានថយចុះ ១០ ភាគរយ ។ ចំនួនស្រ្តីផ្លាស់ប្តូរលំនៅដ្ឋានដើម្បីការងារមានចំនួនតិចជាងបុរសសម្រាប់ជំរឿនទាំងពីរ ។ សមាមាត្រការនៃការផ្លាស់ប្តូរលំនៅដ្ឋានដើម្បី ការងារក្នុងស្រុកសម្រាប់ការងារកសិកម្មជាទូទៅថយចុះទាំងបុរស (ពី ៥៦,៣ ភាគរយ នៅឆ្នាំ ១៩៩៨ ទៅ ៤៩,៧ ភាគរយក្នុងឆ្នាំ ២០០៨) និងស្រ្តី (ពី ៦៨,៥ ភាគរយមក ៥៣,៨ ភាគរយ) ។ ការផ្លាស់លំនៅដ្ឋានដើម្បីការងារក្នុងវិស័យទីបី ឬ(ជំនួញ និងសេវាកម្ម) បានកើនពី ៣១ ភាគរយនៅឆ្នាំ ១៩៩៨ ទៅ ៣៤,៩ ភាគរយក្នុងឆ្នាំ ២០០៨ បន្ទាប់មកការកើនឡើងក្នុងវិស័យទីពីរ (ផលិតកម្ម) ពី ៧,៣ ភាគរយ ទៅ ១៣,៦ ភាគរយ ។

### តារាង ៣.៩ កម្មករផ្លាស់ប្តូរលំនៅដ្ឋាន ដើម្បីការងារ

| ភេទ និងអាយុ | វិស័យ | ១៩៩៨ | | | ២០០៨ | | |
|---|---|---|---|---|---|---|---|
| | | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |

[14] An internal migrant worker is someone who has moved residence for employment from one geographical location to another within the country.

និន្នាការពលកម្មនិង សង្គមកម្ពុជា ២០១០

| សរុប (ចំនួន) | 2 337 854 | 1 292 047 | 1 045 807 | 2 516 502 | 1 382 575 | 1 133 927 |
|---|---|---|---|---|---|---|
| វិស័យទីមួយ | 61.7 | 56.3 | 68.5 | 51.5 | 49.7 | 53.8 |
| វិស័យទីពីរ | 7.3 | 8.0 | 6.3 | 13.6 | 12.3 | 15.1 |
| វិស័យទីបី | 31.0 | 35.7 | 25.2 | 34.9 | 38.0 | 31.1 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |
| **15–24** | **389 456** | **198 597** | **190 859** | **497 030** | **239 374** | **257 656** |
| វិស័យទីមួយ | 55.5 | 52.7 | 58.3 | 41.2 | 44.5 | 38.2 |
| វិស័យទីពីរ | 14.8 | 13.3 | 16.4 | 27.7 | 21.4 | 33.6 |
| វិស័យទីបី | 29.7 | 34.0 | 25.3 | 31.1 | 34.1 | 28.2 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |
| **25+** | **1 933 897** | **1 087 045** | **846 852** | **2 000 595** | **1 133 677** | **866 918** |
| វិស័យទីមួយ | 63.0 | 56.9 | 70.8 | 53.9 | 50.6 | 58.3 |
| វិស័យទីពីរ | 5.7 | 7.1 | 4.0 | 10.1 | 10.4 | 9.7 |
| វិស័យទីបី | 31.3 | 36.1 | 25.2 | 36.0 | 38.9 | 32.1 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |

ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨
- NIS/MOP ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨

ទិន្នន័យរាយការណ៍ក្នុងផ្នែកនេះ ស្តីពីការធ្វើអន្តោប្រវេសន៍ ដែលទាក់ទងនឹងការចុះបញ្ជីធ្វើការនៅ បរទេសតែប៉ុណ្ណោះ ។ ដូចបានរាយការណ៍ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) (តារាង ៣.១០) ចំនួនពលករទាំងអស់ប្រចាំឆ្នាំទៅធ្វើការនៅឯបរទេសខ្ពស់នៅឆ្នាំ ២០០៧ (៩,៤៧៦ នាក់) និងធ្លាក់មក ៧,៣៤០ នាក់នៅក្នុងឆ្នាំ ២០០៨ ។ ចាប់ពីឆ្នាំ ២០០៤ ចំនួនស្ត្រីសរុបទៅធ្វើការនៅបរទេស ខ្ពស់ជាងបុរស ។ ពលករកម្ពុជា បានចេញទៅធ្វើការជាផ្លូវការនៅប្រទេសម៉ាឡេស៊ីតាំងពីឆ្នាំ ១៩៩៨ ខណៈ ដែលទទួលបានការយល់ព្រមជាផ្លូវការជាមួយសាធារណៈរដ្ឋកូរ៉េនៅឆ្នាំ ២០០៧ ថៃនៅឆ្នាំ ២០០៦ និងរាជា ណាចក្រជប៉ុននៅឆ្នាំ ២០០៧ ។ ចំនួនពលករចេញទៅធ្វើការនៅប្រទេសថៃនៅឆ្នាំ ២០០៧ (៥,៦៧០នាក់) ខ្ពស់ជាងទៅប្រទេសម៉ាឡេស៊ី (៣,២១៩នាក់) បន្ទាប់មកសាធារណរដ្ឋកូរ៉េ (៥៨៤ នាក់) និងជប៉ុន (៣ នាក់) ។ ស្ថានភាពនេះ បានផ្លាស់ប្តូរនៅក្នុងឆ្នាំ ២០០៨ ដែលពលករជាច្រើនទៅធ្វើការនៅប្រទេស ម៉ាឡេស៊ី (២,៦៥៤ នាក់) និងសាធារណៈរដ្ឋកូរ៉េ (២,៥៣១ នាក់) ទៅប្រទេសថៃ (២,១១៦ នាក់) និងជប៉ុន (៣៩ នាក់)[15] ។

តារាង ៣.១០ ចំនួនពលករកម្ពុជាទៅធ្វើការនៅឯបរទេសតាមប្រទេស

| ឆ្នាំ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|---|
| សរុប | **1 329** | **1 483** | **2 244** | **3 636** | **9 476** | **7 340** | **14 924** |
| ប្រុស | 711 | 624 | 899 | 1 798 | 4 611 | 3 616 | 4 292 |
| ស្រី | 618 | 859 | 1 345 | 1 838 | 4 865 | 3 724 | 10 636 |

[15] These are figures on officially available legal migration.

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ថៃ** | | | | **445** | **5 670** | **2 116** | **3 543** |
| ប្រុស | | | | 226 | 3 935 | 1 425 | 1 968 |
| ស្រី | | | | 219 | 1 735 | 691 | 1 575 |
| **ម៉ាឡេស៊ី** | **573** | **809** | **1 776** | **1 690** | **3 219** | **2 654** | **9 682** |
| ប្រុស | 73 | 105 | 467 | 231 | 174 | 53 | 876 |
| ស្រី | 500 | 704 | 1 309 | 1 459 | 3 045 | 2 601 | 8 806 |
| **ជប៉ុន** | | | | | **3** | **39** | **16** |
| ប្រុស | | | | | 3 | 13 | 10 |
| ស្រី | | | | | 0 | 26 | 6 |
| **សាធារណៈរដ្ឋកូរ៉េ** | **756** | **674** | **468** | **1 501** | **584** | **2 531** | **1 687** |
| ប្រុស | 638 | 519 | 432 | 1 341 | 499 | 2 125 | 1 438 |
| ស្រី | 118 | 155 | 36 | 160 | 85 | 406 | 249 |

ប្រភព: នាយកដ្ឋានមុខរបរ និងហាត្ថពលកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ប្រអប់ទី ៣
## យុទ្ធសាស្ត្រដើម្បីបង្កើនការងារនៅក្រៅប្រទេសសម្រាប់ប្រជារាស្ត្រកម្ពុជា

ការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពជាច្រើន ដែលកំណត់ដោយក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ គឺលើកកំពស់សមភាព និងធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅក្នុងចំណោមប្រជារាស្ត្រកម្ពុជា ការលើកកំពស់ការងារក្នុង និងក្រៅប្រទេស គឺជាអាទិភាពមួយចំបងក្នុងការងារអាទិភាពផ្សេងទៀត ។ MOLVT និងសមភាគីកូរ៉េ បានផ្តល់ប្រព័ន្ធអនុញ្ញាតិការងារដើម្បីជ្រើសរើស បញ្ជូន និងគ្រប់គ្រងពលករកម្ពុជាទៅ កាន់សាធារណៈរដ្ឋកូរ៉េ ។ បន្ថែមលើការគ្រប់គ្រងពលករនៅបរទេស MOLVT បានបង្កើតប្រព័ន្ធសហាការជាមួយស្ថាប័នផ្សេងទៀតសម្រាប់ទទួល និងដោះស្រាយបណ្តឹងរបស់ពលករ ។ បច្ចុប្បន្ន MOLVT កំពុងធ្វើការជាមួយ អង្គការអន្តរជាតិ ដូចជាអង្គការ ILO និងអង្គការអន្តោប្រវេសន៍អន្តរជាតិ (IOM) ដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រង ពលករកម្ពុជានៅបរទេស ។ ក្នុងចំណោមបញ្ហាដែលត្រូវកែតំរូវគឺ: i) ការខ្វះព័ត៌មាន និងការយល់ដឹងក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និងលទ្ធភាពនៃការធ្វើបែបបទក្នុងការជ្រើសរើសនៅថ្នាក់ខេត្ត ii) បែបបទនៃការជ្រើសរើសមាន រយៈពេលយូរ និងចំណាយខ្ពស់ iii) ភាពទន់ខ្សោយនៃស្ថាប័នទទួលខុសត្រូវសម្រាប់គ្រប់គ្រង និងការពារការធ្វើអន្តោប្រវេសន៍របស់ពលករ iv) គ្មានប្រសិទ្ធភាពបណ្តុះបណ្តាលមុនចេញដំណើររបស់ពលករ v) ខ្វះជំនាញដែល ត្រូវការដោយនិយោជិតនៅឯក្រៅប្រទេស និង vi) ខ្វះប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់តាមដានពលករម្នាក់ៗ (ប្រព័ន្ធទិន្នន័យមូលដ្ឋានដែលផ្តល់ដោយ IOM មិនគ្រប់ជ្រុងជ្រោយ ។

ប្រភព: MOLVT ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០០៩ របាយការណ៍សមិទ្ធផលរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់អាណត្តិទី ៣ និងគោលដៅសម្រាប់អនុវត្តបន្ត។

ពលករទៅធ្វើការក្រៅប្រទេសចន្លោះឆ្នាំ ២០០៣ និងឆ្នាំ ២០០៨ ដូចបង្ហាញក្នុងតារាង ៣.១១ បញ្ជាក់ថា ភាគច្រើននៃពួកគេគឺធ្វើការក្នុងវិស័យផលិតកម្ម និងកម្មន្តសាលបន្ទាប់មកការងារបំរើតាមផ្ទះ និងកសិកម្ម ។

តារាង ៣.១១ ចំនួនពលករកម្ពុជាទៅធ្វើការ ក្រៅប្រទេសតាមវិស័យ

| ឆ្នាំ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|
| សរុប | **1 329** | **1 483** | **2 244** | **3 636** | **9 476** | **7 340** |
| បំរើតាមផ្ទះ | 37.6 | 39.2 | 44.9 | 31.4 | 22.3 | 35.2 |
| កម្មន្តសាល | 62.4 | 55.6 | 49.4 | 68.3 | 76.0 | 50.2 |
| កសិកម្ម | 0.0 | 5.1 | 5.7 | 0.3 | 1.6 | 13.2 |
| សំណង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.9 |
| មន្ត្រីផ្លូវការ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.5 |

ប្រភព: នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ៣.២.៤ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអភិវឌ្ឍន៍ជំនាញ និងតំរូវការទីផ្សារការងារ

ដើម្បីធានាថា រដ្ឋាភិបាលខិតខំអភិវឌ្ឍន៍គុណភាពបច្ចេកទេស និងវិជ្ជាជីវៈក្នុងចំណោមប្រជារាស្ត្រ កម្ពុជា ដើម្បីគាំទ្រដល់ការកើនឡើងនៃបច្ចេកវិទ្យា ផលប្រយោជន៍សង្គមឲ្យស្របតាមយុទ្ធសាស្ត្រជាតិ កាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលឆ្នាំ ២០០៣-២០០៥ និងយុទ្ធសាស្ត្រចតុកោណសម្រាប់កំណើន សមធម៌ និងប្រសិទ្ធភាពការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់លទ្ធភាពបណ្តុះបណ្តាលជំនាញសម្រាប់ឆ្នាំសារពើព័ន្ធ ២០០៧-២០០៨ ។ វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបច្ចុប្បន្នមានគ្រឹះស្ថានចំនួន ៣៩ ស្ថិតក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ ក្នុងនោះមានចំនួន ១១ គ្រឹះស្ថាន បានបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រ សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ កម្រិត ១ ២ ៣ សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស បរិញ្ញាបត្រ ឬវិស្វករ និងអនុបណ្ឌិត (ចំនួន ០៧ គ្រឹះស្ថានមានទីតាំងនៅភ្នំពេញ ០១ នៅខេត្តកណ្តាល ០១ នៅខេត្តកំពត ០២ នៅ ខេត្តបាត់ដំបង) និង ២៦ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្តធ្វើការបណ្តុះបណ្តាលកម្រិត វិញ្ញាបនបត្រ (ចំនួន ០១ មជ្ឈមណ្ឌលនៅរាជធានីភ្នំពេញ និង ២៥ នៅតាមបណ្តាខេត្តនានា) ។ ក្រសួង បានផ្តល់កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី និងវែងឲ្យដល់គ្រឹះស្ថានឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ផងដែរ ។ ប្រមាណ ៣០-៣៥ អង្គភាពបានបណ្តុះបណ្តាល ៣០០-៥០០ នាក់ក្នុងមួយឆ្នាំ ក្នុងកម្មវិធីរយៈ ពេលខ្លី[16]។

ក្រសួងការងារ និងបណ្តុះបណ្តាលវីជ្ជាជីវៈបានបង្ហាញចំនួនបញ្ចប់ TVET បានកើនឡើងពី ៨៨.៣៦៧ នាក់នៅឆ្នាំ ២០០៧ ទៅ ១១៣.៦៤៨ នាក់នៅឆ្នាំ ២០០៨ (តារាង ៣.១២) ។ ជាងពាក់ កណ្តាលនៃអ្នកបញ្ចប់ការសិក្សានៅឆ្នាំ ២០០៨ (៥៩,១

[16] ADB. 2009. *Report and recommendations of the president to the board of directors on a proposed fund grant,* Kingdom of Cambodia. Strengthening Technical and Vocational Education and Training Project.

ភាគរយ) បានចូលរួមវគ្គបណ្តុះបណ្តាលបឋមរយៈ ពេលខ្លីនៅវិទ្យាស្ថានសាធារណៈ ខណៈដែលជាងមួយភាគបី (៣៥,៣ ភាគរយ) សិក្សានៅមជ្ឍមណ្ឌលបណ្តុះបណ្តាលឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ។ មានតែ ២,៨ ភាគរយដែល បានបញ្ចប់ការសិក្សាទទួលសញ្ញាបត្របច្ចេកទេស ឬវិញ្ញបនបត្រពីវិទ្យាស្ថានសាធារណៈនៅឆ្នាំ ២០០៨ ។ ចំនួនកាន់តែតិចតួច គឺ ១,៣ ភាគរយ ដែលបានទទួលកម្មវិធីបណ្តុះបណ្តាលបឋមរយៈពេលវែងតាមវិទ្យាស្ថានសាធារណៈ និង ១,២ ភាគរយទទួលការបណ្តុះបណ្តាលកំរិតលើសបរិញ្ញបត្រ ។

### តារាង ៣.១២ សិស្ស-និស្សិតចូលរួមវគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

| កំរិត | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|
| ចំនួន-ទាំងពីរភេទ | **24 587** | **27 894** | **47 986** | **88 367** | **113 648** | **168 630** |
| បរិញ្ញាប័ត្រ និងខ្ពស់ជាង | 0.0 | 3.7 | 2.3 | 1.3 | 1.2 | 0.79 |
| សញ្ញាប័ត្រមធ្យមសិក្សាបច្ចេកទេសសាធារណៈ | 7.0 | 4.4 | 4.6 | 2.5 | 2.8 | 1.75 |
| វគ្គបណ្តុះបណ្តាលបឋមរយៈពេលវែងសាធារណៈ | 8.1 | 2.1 | 1.0 | 1.8 | 1.3 | 0.72 |
| វគ្គបណ្តុះបណ្តាលបឋមរយៈពេលខ្លីសាធារណៈ | 24.4 | 38.3 | 36.9 | 73.5 | 59.1 | 69.52 |
| ឯកជន /NGO និងអង្គការអន្តរជាតិ | 60.5 | 51.4 | 55.1 | 20.9 | 35.5 | 27.21 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |
| ចំនួន-ប្រុស | **12 777** | **15 574** | **27 999** | **56 494** | **59 745** | **80 743** |
| បរិញ្ញាប័ត្រ និងខ្ពស់ជាង | 0.0 | 5.3 | 2.9 | 1.5 | 1.9 | 1.33 |
| សញ្ញាប័ត្រមធ្យមសិក្សាបច្ចេកទេសសាធារណៈ | 9.1 | 5.3 | 5.4 | 2.6 | 3.7 | 2.37 |
| វគ្គបណ្តុះបណ្តាលបឋមរយៈពេលវែងសាធារណៈ | 13.7 | 3.5 | 1.7 | 2.2 | 2.1 | 1.01 |
| វគ្គបណ្តុះបណ្តាលបឋមរយៈពេលខ្លីសាធារណៈ | 26.8 | 36.0 | 31.0 | 68.1 | 54.4 | 61.73 |
| ឯកជន /NGO និងអង្គការអន្តរជាតិ | 50.4 | 49.9 | 59.0 | 25.5 | 37.9 | 33.56 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |
| ចំនួន-ស្រី | **11 810** | **12 320** | **19 987** | **31 873** | **53 903** | **87 887** |
| បរិញ្ញាប័ត្រ និងខ្ពស់ជាង | 0.0 | 1.7 | 1.5 | 1.0 | 0.5 | 0.29 |
| សញ្ញាប័ត្រមធ្យមសិក្សាបច្ចេកទេសសាធារណៈ | 4.8 | 3.4 | 3.5 | 2.2 | 1.7 | 1.19 |
| វគ្គបណ្តុះបណ្តាលបឋមរយៈពេលវែងសាធារណៈ | 2.1 | 0.4 | 0.1 | 1.0 | 0.5 | 0.45 |
| វគ្គបណ្តុះបណ្តាលបឋមរយៈពេលខ្លីសាធារណៈ | 21.8 | 41.2 | 45.3 | 83.1 | 64.3 | 76.68 |
| ឯកជន /NGO និងអង្គការអន្តរជាតិ | 71.4 | 53.2 | 49.6 | 12.8 | 32.9 | 21.38 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |

និន្នាការពលកម្មនិង សង្គមកម្ពុជា ២០១០

ប្រភព: នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

### ប្រអប់-៤
### គណៈកម្មការជាតិបណ្តុះបណ្តាលដើម្បីធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពបណ្តុះបណ្តាល

ដើម្បីសំរេចគោលដៅយុទ្ធសាស្ត្រចតុកោណ គណៈកម្មការជាតិបណ្តុះបណ្តាល (NTB) ជាក្រុមប្រឹក្សាកំពូលនៃ TVET ត្រូវបានបង្កើតឡើងសម្រាប់រៀបចំគោលនយោបាយ គំរោងផែនការជាតិសំរបសំរួល អប់រំ បណ្តុះបណ្តាល បច្ចេកទេស និងផ្តោតទៅលើគុណភាព និងប្រសិទ្ធភាព ។ NTB ក៏ឆ្លើយតបទៅនឹងតម្រូវការក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម និងសេវាកម្មផងដែរ ។ NTB ដំណើរការតាមគោលដៅដូចតទៅ: i) ណែនាំគោលនយោបាយអភិវឌ្ឍន៍ TVET ដើម្បីជួយកាត់បន្ថយភាពក្រីក្រ ii) ធ្វើវិមជ្ឈការខាងកម្មវិធី TVET iii) គាំទ្រកំណើនសហគ្រាសជាមួយនិងជំនាញការងារ iv) លើកទឹកចិត្តសហគមន៍ និងសហគ្រាសតាមរយៈការបណ្តុះបណ្តាល v) ជួយ យុវជនដែលបោះបង់ការអប់រំទូទៅ vi) លើកទឹកចិត្ត អ្នកធ្វើការដោយផ្ទាល់ខ្លួន និងផ្តល់ជំនួយឥណទាន vii) ជួយសហគ្រាសខ្នាតតូចឲ្យចាប់ផ្តើម និងការរីកចម្រើន viii) អភិវឌ្ឍន៍ភាពជាដៃគូជាមួយឯកជន និងសាធារណៈដើម្បី ចែករំលែកធនហិរញ្ញវត្ថុ និងដើម្បីចូលរួមវិស័យឯកជនក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល និងពង្រីកជម្រើស TVET ix) ធានាគុណភាពនៃលក្ខខណ្ឌ TVET និងកែលម្អគុណភាពនៃការដឹកនាំ ការគ្រប់គ្រង និងសម្របសម្រួល TVET x) បង្កើតយន្តការព័ត៌មានទីផ្សារការងារ។ xi) អភិវឌ្ឍន៍ស្តង់ដារជាតិស្តីពីសមត្ថភាព ។

លើសពីនេះ NTB បង្កើតគណៈកម្មការចំនួនបី ដែលនីមួយៗ ទទួលខុសត្រូវដូចតទៅ: i) បង្កើតទំនុកចិត្តវគ្គបណ្តុះ បណ្តាលកម្មវិធី និងគ្រឹះស្ថានរបស់ TVET ii) អភិវឌ្ឍន៍ស្តង់ដាជាតិ ការសាកល្បង និងចេញវិញ្ញាបនប័ត្រ iii) បង្កើតការទទួលស្គាល់កម្មវិធីវគ្គ និងគ្រឹះស្ថាន TVET និង iv) បង្កើតប្រព័ន្ធព័ត៌មានទីផ្សារការងារ ។

NTB ក៏បង្កើតផងដែរនូវគេហទំព័រ (www.ntb.gov.kh) ក៏ដូចជាទីភ្នាក់ងារជាតិ សម្រាប់ការងារថ្មី ដើម្បីផ្តល់ សេវាកម្មការងារ តាមរយៈមជ្ឈមណ្ឌលការងារ និងព័ត៌មានទីផ្សារការងារ ។

ប្រភព: MOLVT ថ្ងៃទី ២០ ឆ្នាំ ខែកុម្ភៈ ២០០៩ របាយការណ៍សមិទ្ធិផលរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់អាណត្តិទី ៣ និងគោលដៅសម្រាប់អនុវត្តន៍បន្ត ។

ទិន្នន័យបានពីគណៈកម្មការវិនិយោគកម្ពុជា (ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបង្ហាញក្នុងតារាង៣.១៣) បង្ហាញថា វិស័យឧស្សាហកម្មត្រូវការពលកម្មច្រើនក្នុងរវាង ៣ ឆ្នាំ គឺពីឆ្នាំ ២០០៣ និង ២០០៨ ពិសេស ដោយសារការកើនឡើងនៃចំនួនគំរោងវិនិយោគ ពី ៣៦ ទៅ ៦៦ ។ ក្នុងឆ្នាំ ២០០៨ តំរូវការពលកម្ម តាមរយៈគំរោងវិនិយោគក្នុងវិស័យសេវាកម្មបានកើនឡើងគួរឲ្យកត់សំគាល់ ៣៩,៨ ភាគរយនៃពលកម្ម ទាំងអស់ពីប្រមាណ ៧ ភាគរយនៅឆ្នាំ ២០០៦ និងឆ្នាំ ២០០៧ ។

ទោះជាយ៉ាងណាក៏ដោយ តំរូវការពល កម្មតាមរយៈគំរោងវិនិយោគក្នុងវិស័យកសិកម្មបានថយចុះច្រើនក្នុងចន្លោះឆ្នាំ ២០០៦ និង ២០០៨ គឺពី ៣៥,៧ ភាគរយមកត្រឹមតែ ២,៨ ភាគរយ ។

### តារាង ៣.១៣ តំរូវការពលកម្មតាមរយៈគំរោងវិនិយោគ តាមវិស័យ ឆ្នាំ ២០០៨

| វិស័យ | ពលកម្ម | % | ចំនួនគំរោង |
|---|---|---|---|
| ២០០៨ | | | |
| កសិកម្ម | 4 729 | 2.8 | 5 |
| ឧស្សាហកម្ម | 98 583 | 57.4 | 66 |
| សេវាកម្ម | 68 398 | 39.8 | 27 |
| សរុប | 171 710 | 100.0 | 98 |
| ២០០៧ | | | |
| កសិកម្ម | 2 198 | 3.7 | 3 |
| ឧស្សាហកម្ម | 52 761 | 89.0 | 36 |
| សេវាកម្ម | 4 355 | 7.3 | 8 |
| សរុប | 59 314 | 100.0 | 47 |
| ២០០៦ | | | |
| កសិកម្ម | 68 367 | 35.7 | 20 |
| ឧស្សាហកម្ម | 109 344 | 57.1 | 61 |
| សេវាកម្ម | 13 851 | 7.2 | 17 |
| សរុប | 191 562 | 100.0 | 98 |

ប្រភព: - របាយការណ៍ស្តីពីព័ត៌មានទីផ្សារការងារ ឆមាសទី ១ ឆ្នាំ ២០០៩
នាយកដ្ឋានព័ត៌មានទីផ្សារការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ៣.២.៥ ផលិតភាពការងារ

បញ្ហាប្រឈមជាមូលដ្ឋានសម្រាប់កម្ពុជា គឺបង្កើនល្បឿនកំណើនផលិតភាព និងធានាផលិតភាព តាមលក្ខខណ្ឌការងារល្អប្រសើរ និងប្រាក់ឈ្នួលខ្ពស់។ តារាង ៣.១៤ ឆ្លុះបញ្ចាំងអំពីកំរិតនៃ GDP សម្រាប់ អ្នកធ្វើការម្នាក់តាមវិស័យពីឆ្នាំ ១៩៩៨ ដល់ ២០០៨ ។ ការប៉ាន់ស្មានបានឲ្យដឹងថា ផលិតភាពការងារ (តំលៃបន្ថែមសម្រាប់អ្នកធ្វើការម្នាក់) បានកើនប្រមាណ ២,៤ លានរៀល (៦៣១ ដុល្លារអាមេរិក) ក្នុងឆ្នាំ ១៩៩៨ ទៅជិត ៤,២ លានរៀល (១.០៣២ ដុល្លារអាមេរិក) នៅឆ្នាំ ២០០៨ ។ អត្រាកំណើនមធ្យមប្រចាំ ឆ្នាំមាន ៥,៧ ភាគរយគិតជាប្រាក់រៀល និង ៤,៩ ភាគរយគិតជាប្រាក់ដុល្លារ ។ ការប្រែប្រួលជាមធ្យម ប្រចាំឆ្នាំខ្ពស់ជាងគេក្នុងផលិតភាពកាងារ គឺនៅចន្លោះឆ្នាំ ១៩៩៨ និង ២០០៨ ក្នុងវិស័យរុករករ៉ែ និងថ្ម (១៩,៤ ភាគរយ) បន្ទាប់មកវិស័យហិរញ្ញវត្ថុ និងសេវាកម្មផ្សេងទៀត (៨,៦ ភាគរយ) ដឹកជញ្ជូន និងទូរ គមនាគមន៍ (៥,៨ ភាគរយ) សំណង់ (៣,៧ ភាគរយ) និងកម្មន្តសាល (៣,១ ភាគរយ) ។ កំណើនជា

មធ្យមប្រចាំឆ្នាំនៃផលិតភាពការងារ (គិតជារៀល) ក្នុងវិស័យកសិកម្មក្នុងរយៈពេលដូចគ្នាបានកើនឡើង យឺត ១,៧ ភាគរយក៏ដូចជាពាណិជ្ជកម្មមាន ១ ភាគរយ ។ ប៉ុន្តែអត្រាកំណើនជាមធ្យមប្រចាំឆ្នាំបានធ្លាក់ចុះ ចំពោះសណ្ឋាគារ និងភោជនីយដ្ឋាន ១ ភាគរយ និងអគ្គីសនី ឧស្ម័ន និងការផ្គត់ផ្គង់ ទឹក ៣,៩ ភាគរយ ។

តារាង ៣.១៩ ផលិតភាពការងារតាមវិស័យ (តំលៃបន្ថែមសម្រាប់អ្នកធ្វើការម្នាក់ តាមថ្លៃថេរ ឆ្នាំ ២០០០)

| វិស័យ | ១៩៩៨ | | ២០០៨ | | អត្រាកំណើនជាមធ្យមប្រចាំឆ្នាំ(%) | |
|---|---|---|---|---|---|---|
| | លានរៀល | (US$) | លានរៀល | (US$) | រៀល | US$ |
| **សរុប** | **2,380** | **631** | **4,190** | **1,030** | **5.7** | **4.9** |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 1,294 | 343 | 1,537 | 378 | 1.7 | 1.0 |
| រុករករ៉ែ និងថ្ម | 3,637 | 964 | 25,341 | 6,229 | 19.4 | 18.7 |
| កម្មន្តសាល | 9,735 | 2,580 | 13,339 | 3,279 | 3.1 | 2.4 |
| អគ្គិសនី ឧស្ម័ន និងផ្គត់ផ្គង់ទឹក | 15,849 | 4,200 | 10,695 | 2,629 | -3.9 | -4.7 |
| សំណង់ | 9,337 | 2,474 | 13,553 | 3,332 | 3.7 | 3.0 |
| ពាណិជ្ជកម្ម | 4,156 | 1,101 | 4,598 | 1,130 | 1.0 | 0.3 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 24,378 | 6,460 | 22,068 | 5,425 | -1.0 | -1.7 |
| ដឹកជញ្ជូន និងទូរគមនាគមន៍ | 6,042 | 1,601 | 10,824 | 2,661 | 5.8 | 5.1 |
| ហិរញ្ញវត្ថុ និងសេវាកម្មផ្សេងទៀត | 4,292 | 1,137 | 10,096 | 2,482 | 8.6 | 7.8 |

ប្រភព - NIS/MOP

ទោះបីផលិតភាពកើនឡើង ក៏កម្រិតទិន្នផលសម្រាប់មនុស្សធ្វើការម្នាក់នៅទាបធៀបទៅនឹងបណ្តាប្រទេសក្នុងអាស៊ានដូចមានក្នុងរូប ៣.៨ ។ ការកើនឡើងនៃកំរិតផលិតភាពនៅកម្ពុជាគឺជាការចាំបាច់ ប្រសិនបើប្រទេសស្ថិតក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាងក្នុងអាស៊ាន ពិសេសបន្ទាប់ពីទទួលរង នូវវិបត្តិសេដ្ឋកិច្ច ។

រូប ៣.៨ ទិន្នផលសម្រាប់អ្នកធ្វើការម្នាក់សម្រាប់ប្រទេសក្នុងអាស៊ាននៅឆ្នាំ ២០០៨ (ថ្លៃថេរឆ្នាំ ២០០៩

ជាដុល្លារអាមេរិក)




ប្រភព: ILO ឆ្នាំ ២០១០ និន្នាការ ការងារ និងសង្គមអាស៊ានឆ្នាំ ២០១០ ការងើបឡើងវិញ និងការអភិវឌ្ឍន៍តាមរយៈការងារសមរម្យ

### ៣.២.៦ ការគាំពារសង្គម

ទោះបីមានវឌ្ឍនភាពក្នុងសូចនាករអភិវឌ្ឍន៍ជាច្រើន ប៉ុន្តែសមាមាត្រនៃប្រជាពលរដ្ឋក្នុងកំរិតគួរឲ្យ កត់សំគាល់នៅតែស្ថិតក្នុងភាពក្រីក្រនៅឡើយ ហើយ ៨២,៥ ភាគរយស្ថិតក្នុងការងារងាយរងគ្រោះនៅឆ្នាំ ២០០៨ ។ វិបត្តិសេដ្ឋកិច្ច និងបន្ទាប់មកវិបត្តិម្ហូបអាហារបានធ្វើឲ្យបញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរ ។ ការបង្កើនជំនួយសង្គម និងការគាំពារសង្គម នៅតែជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ។

បច្ចុប្បន្នការគាំពារសង្គមរួមមាន i) បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់និយោជិតឯកជន ដែលផ្តល់នូវការធានារ៉ាប់រងដល់ការរងគ្រោះថ្នាក់ដោយការងារ ii) បេឡាជាតិ របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលដែលផ្តល់ប្រាក់សោធន iii) កម្មវិធីគាំពារសុខភាពសង្គមផ្តោតលើអ្នកក្រីក្រ និង អ្នកធ្វើការក្នុងវិស័យសេដ្ឋកិច្ចមិនរៀបរយ ដូចជាបេឡាសមធម៌សុខភាព និងគំរោងធានារ៉ាប់រងសុខភាព តាមសហគមន៍ យុទ្ធសាស្រ្តគាំពារសុខភាពសង្គមត្រូវបានពង្រាង (ដោយសហការណ៍ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ ក្រសួងសុខាភិបាល ភ្នាក់ងារអភិវឌ្ឍន៍បារាំង ភ្នាក់ងារអភិវឌ្ឍន៍សហប្រតិបត្តិ ការបច្ចេកទេសអាល្លឺម៉ង់ (GTZ) និងអង្គការសុខភាពពិភពលោក) និងដាក់ស្នើសុំការអនុម័តចុងក្រោយ iv) កម្មវិធីសំណាញ់សុវត្ថិភាពសង្គមជាច្រើន (ឬជំនួយសង្គមកិច្ច) ផ្តោតលើជនក្រីក្រ

និងងាយរងគ្រោះ ។ កម្ម វិធីទាំងនេះ ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ដូចជាធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធី ស្បៀងអាហារពិភពលោក និង UNICEF ។

## *បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់និយោជិតវិស័យឯកជន*

ច្បាប់ស្តីពីរបបសន្តិសុខសង្គមបានអនុម័តក្នុងឆ្នាំ ២០០២ ផ្តល់សិទ្ធិដល់និយោជិតវិស័យឯកជននូវ ប្រយោជន៍សង្គមសម្រាប់ជនទាំងឡាយណា ដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារនៅក្នុងព្រះរា ជាណាចក្រកម្ពុជា ។

បេឡាជាតិរបបសន្តិសុខសង្គម (NSSF) ជាអង្គភាពមានភារកិច្ចគ្រប់គ្រង និងចាត់ចែងរបប សន្តិសុខសង្គមដែលមានចែងនៅក្នុងច្បាប់ ។ កម្មវិធីនេះរៀបចំឡើងដើម្បីអនុវត្តក្នុងបីដំណាក់កាល គឺទី ១ សម្រាប់របបធានារ៉ាប់រងហានិភ័យការងារនៅឆ្នាំ ២០០៨ បន្ទាប់មកគម្រោងថែទាំសុខភាព និងជាចុង ក្រោយ គឺគម្រោងសោធន ។ របបសន្តិសុខសង្គមបានផ្តល់ដល់មនុស្សគ្រប់រូប ដែលស្ថិតនៅក្រោមច្បាប់ បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលក្នុងដំណាក់កាលដំបូង អនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានដែលមាន កម្មករ និយោជិតចាប់ពី ៨ នាក់ឡើង ។

ការទទួលប្រាក់បំណាច់ពីហានិភ័យការងារ ដូចមានចែងក្នុងមាត្រាទី ១៥ បានគ្របដណ្តប់ការ គ្រោះថ្នាក់នៅកន្លែងការងារ និងជម្ងឺវិជ្ជាជីវៈ ក៏ដូចជាគ្រោះថ្នាក់ទាក់ទងនឹងការធ្វើដំណើរវវាងផ្ទះ និង កន្លែងការងារ ។ ពិសេសគ្របដណ្តប់លើ i) សេវាថែទាំ និងព្យាបាល ii) ប្រាក់បំណាច់ប្រចាំថ្ងៃ iii) ប្រាក់សោធនសម្រាប់ការបាត់បង់ការងារអចិន្ត្រៃ និង iv) ប្រាក់សម្រាប់បុណ្យសព និងប្រាក់សោធនឧត្តរជីវី ។

បន្ទាប់ពី NSSF បង្កើតឡើងនៅខែមិថុនា ឆ្នាំ ២០០៧ MOLVT បានចាប់ផ្តើមគំរោងគ្រោះថ្នាក់ការ ងារ បច្ចុប្បន្នគ្របដណ្តប់លើ ១.៦៦៤ សហគ្រាស និងមានសមាជិកជាង ៥០០.០០០ នាក់ ។ ភាគច្រើន នៃសមាជិកជាស្ត្រី ដែលធ្វើការក្នុងសហគ្រាសផលិតសំលៀកបំពាក់ និងស្បែកជើង ក៏ដូចជាក្នុងធនាគារ សណ្ឋាគារ និងសំណង់ ។ មុនការណែនាំគម្រោងគ្រោះថ្នាក់ដោយការងារ MOLVT មិនសូវទទួលបាន កំណត់ត្រាគ្រោះថ្នាក់ទាក់ទងនឹងការងារឡើយ ។ ក្នុងរយៈពេលពីរខែដំបូង បន្ទាប់ពីយន្តការត្រូវបាន អនុវត្តន៍ NSSF បានទទួលប្រមាណ ២០០ ករណី[17] ។

NSSF មានផែនការពង្រីកវិសាលភាពគំរោងគ្រោះថ្នាក់ដោយការងារ ជាពិសេសតំបន់ក្រៅ រាជធានីភ្នំពេញ ។ គំរោងសុខភាពកំពុងដំណើរការរៀបចំ ។

## *បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ការស៊ីវិល*

[17] MOLVT. 20 February 2009. *Report on the achievements of the Ministry of Labour and Vocational Training for the third mandate and its objectives to be continued.*

NSSF សម្រាប់មន្ត្រីរាជការស៊ីវិល (NSSF-C) បានបង្កើតឡើងដោយព្រះរាជក្រឹតចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៨ និងចាប់អនុវត្តន៍នៅខែ ឧសភា ឆ្នាំ ២០០៩ ។ ក្រសួងពីរមានសមាសភាពជាក្រុមប្រឹក្សានាយក គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ មានមន្ត្រី ៣៤ នាក់ធ្វើការនៅការិយាល័យកណ្តាល និងប្រមាណ ៥០០ នាក់ធ្វើការនៅមូលដ្ឋាន ។ បេឡានេះគ្រប ដណ្តប់ ១៨០.០០០ នាក់ជាមន្ត្រីរាជការស៊ីវិល និងគ្រួសាររបស់គេមានប្រមាណ១-២ ភាគយនៃប្រជារាស្ត្រទាំងអស់ ។

NSSF-C រួមមានគំរោងសោធន ដែលហិរញ្ញប្បទានពីថវិការរបស់រដ្ឋាភិបាល ។ NSSF-C មាន ផែនការប្តូរទៅប្រព័ន្ធរួមវិភាគទាន ដើម្បីផ្តល់នូវផលប្រយោជន៍មួយចំនួនៈ ប្រាក់សោធន (រាប់បញ្ចូលទាំងអ្នករស់នៅបន្ទាប់ពីគ្រោះថ្នាក់) និងមានវិសាលភាពសម្រាប់ពិការភាព មាតុភាព គ្រោះថ្នាក់ការងារ និងមរណភាព ។ ការសិក្សាជាក់ស្តែងបានកំណត់តំរូវការនៃការចូលរួមមាន ២៤ ភាគរយនៃប្រាក់បៀវត្សរ៍របស់និយោជិតម្នាក់ៗ គឺ ១៨ ភាគរយចំណាយដោយរដ្ឋ និង ៦ ភាគរយដោយមន្ត្រីរាជការស៊ីវិល ។ បញ្ហា ប្រឈមចំបងសម្រាប់បេឡា គឺការរៀបចំនិងការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ។ NSSF-C មានផែនការផ្តល់គំរោងធានារ៉ាប់រងសុខភាពសង្គម ឧបត្ថម្ភដោយ GTZ ការសិក្សាជាក់ស្តែងនឹងធ្វើឡើងនៅឆ្នាំ ២០១០ ដើម្បីកំនត់អត្រាចូលរួមចំណែក និងផលប្រយោជន៍ ។

## *កម្មវិធីគាំពារសុខភាពសង្គមផ្តោតលើប្រជារាស្ត្រក្រីក្រ និងអ្នកធ្វើការក្នុងវិស័យសេដ្ឋកិច្ចមិនរៀបរយៈ បេឡាសមធម៌ខាងសុខភាព និងគំរោងធានារ៉ាប់រងសុខភាពតាមរយៈសហគមន៍*

បេឡាសមធម៌ខាងសុខភាព (HEF) គឺជាយន្តការផ្តល់សេវាសុខភាពសម្រាប់ព្យាបាលជំងឺអ្នកដែលកំណត់ថាជាជនក្រីក្របំផុតដែលពុំមានប្រាក់បង់ ។ បេឡានេះបានបង្កើតឡើងនៅឆ្នាំ ២០០៣ និងបញ្ចូល ក្នុងគំរោងគាំទ្រវិស័យសុខភាពពីឆ្នាំ ២០០០៤-២០០៨ ហើយបន្ទាប់មកក្នុងគំរោងលើកទី ២ សម្រាប់ឆ្នាំ ២០០៩-២០១៣ ។ បន្ទាប់ពីការសាកល្បង HEF បានណែនាំគំរូ ៤ យ៉ាងទាក់ទងនឹងអ្នកអនុវត្តន៍ និងអ្នកប្រតិបត្តិកញ្ចប់ថវិកា និងយន្តការហិរញ្ញវត្ថុ ។ នៅខែ មីនា ឆ្នាំ ២០០៩ HEF បានអនុវត្តន៍ ៥០ ក្នុងចំណោម ៧២ ស្រុកប្រតិបត្តិដែលគ្របដណ្តប់ (ចំបង) លើប្រជារាស្ត្រ ៣.១៦៨.៨៨៣ នាក់ ឬ ៦៨ ភាគរយនៃ ប្រជារាស្ត្រក្រីក្រ (ទោះបីការប្រើប្រាស់ជាក់ស្តែងដោយជនក្រីក្រមានទំហំទាបជាងក៏ដោយ) ។

គំរោងការធានារ៉ាប់រងសុខភាព តាមរយៈសហគមន៍ស្ម័គ្រចិត្ត CBHI បានអនុវត្តន៍និងដំណើរការ ក្រោមសេចក្តីណែនាំទូទៅតាំងពីឆ្នាំ ២០០៦ ។ គំរោង CBHI

ផ្តោតលើអ្នកដែលស្ថិតជិតចំណាត់ថ្នាក់ក្រីក្រ ដែលអាចចំណាយប្រាក់តិចតួចដើម្បីដូរយកកញ្ចប់សម្រាប់ថែរក្សាសុខភាព ។ ក្នុងឆ្នាំ ២០០៨ មានគំរោង ១២ បានដំណើរការដោយអង្គការជាតិ និងអន្តរជាតិដែលគ្របដណ្តប់លើសមាជិក ៧៩.៨៧៣ នាក់ ។ នៅ ឆ្នាំ ២០០៩ CBHI បង្កើន១៣ គំរោងដែលកើនសមាជិកដល់ ១២២.៨២៩ នាក់ ។

*កម្មវិធីសំណាញ់សុវត្ថិភាពសង្គម (ជំនួយសង្គមកិច្ច) ផ្តោតលើប្រជារាស្ត្រក្រីក្រ និងងាយរងគ្រោះ*

កម្មវិធីជំនួយសង្គមកិច្ច រួមមានជាចំបង គឺការផ្តល់ចំណីអាហារ ផ្តល់ការសិក្សា ផ្តល់ម្ហូបអាហារ សម្រាប់ការងារ និងផ្តល់សាច់ប្រាក់សម្រាប់កម្មវិធីការងារសាធារណ: ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និង ជនបទ (ក្រោមក្រុមប្រឹក្សារដ្ឋមន្ត្រី) បច្ចុប្បន្នកំពុងចាប់ផ្តើមយុទ្ធសាស្ត្រគាំពារសង្គម សម្រាប់ប្រជារាស្ត្រ ក្រីក្រ និងងាយរងគ្រោះ ដែលផ្តល់នូវក្របខ័ណ្ឌការងាររយ:ពេលវែង សម្រាប់ប្រព័ន្ធគាំពារដ៏ទូលំទូលាយ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររយ:ពេលវែង ។

### ៣.២.៧ សុខភាព និងសុវត្ថិភាពការងារ

តាមរយ:ផែនការមេស្តីពីសុខភាព និងសុវត្ថិភាពការងារលើកទី ១ ឆ្នាំ ២០០៩-២០១៣ ត្រូវបាន MOLVT បានយកចិត្តទុកដាក់ធ្វើឲ្យប្រសើរឡើងនូវសុខភាព និងសុវត្ថិភាពការងាររបស់និយោជិត ដើម្បី បង្ការគ្រោះថ្នាក់ និងជម្ងឺក្នុងវិជ្ជាជីវ:ផ្សេងៗនៅកន្លែងធ្វើការ ។ នៅឆ្នាំ ២០០៩ MOLVT បានផ្សព្វផ្សាយផែនការមេ OSH ដំបូង[18] ដោយកំណត់គោលដៅជាអាទិភាពចំនួន ៦ សម្រាប់អនុវត្តន៍គំរោង i) ពង្រឹង ប្រព័ន្ធ OSH ថ្នាក់ជាតិ ii) កែលម្អការធ្វើអធិការកិច្ច និងការតវ៉ា iii) លើកកំពស់សកម្មភាព OSH ដោយ រៀបចំជាស្ថាប័ននិយោជក និងនិយោជិត iv) អនុវត្តន៍កម្មវិធីសង្គមសម្រាប់មុខរបរទំរង់ធ្ងន់ធ្ងរ v) ពង្រីក ការការពារ OSH ដល់សហគ្រាសធន់តូច និងការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជនបទ និង vi) លើកកំពស់ កិច្ចសហការលើសកម្មភាពទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារគំរោង AIDS សម្រាប់ការសម្របកំរិតខ្ពស់ជាង ។ របាយការណ៍ពីនាយកដ្ឋានសុខភាព និងសុវត្ថិភាពការងារ បង្ហាញថាចំនួននិយោជិតដែលបានធ្វើការពិនិត្យ កាយសម្បទា មានកើនឡើងគួរឲ្យកត់សម្គាល់ពីឆ្នាំ ២០០៧ ។ ក្នុងឆ្នាំនីមួយៗ ចំនួនកម្មករនារីបានពិនិត្យ កាយសម្បទាច្រើនជាងកម្មករបុរស (តារាង ៣.១៥) ។

MOLVT កំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយគណ:កម្មការជាតិ AIDS កម្ពុជាដើម្បីអនុវត្ត ប្រកាសលេខ ០៨៦ ស្តីពីការបង្កើតគណ:កម្មការអេដស៍នៅតាមសហគ្រាសគ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ ។ កិច្ចសហប្រតិបត្តិការនេះរាប់បញ្ចូលទាំងការ បង្កើតយន្តការសម្របសម្រួលថ្នាក់ជាតិបីភាគ

[18] MOLVT. The First Occupational Safety and Health Master Plan 2009–2013. Available at: http://www.ilo.org/asia/whatwedo/publications/lang--en/docName--WCMS_112931/index.htm

គឺស្ដីពី HIV/ AIDS ក្នុងកន្លែងការងារដោយបង្កើតគណៈ កម្មាធិការ និងគោលនយោបាយព្រមទាំងកម្មវិធីក្នុងសហគ្រាសមួយចំនួន ។ កម្មវិធីមូលដ្ឋានសហគ្រាស ទាំងនេះ រៀបចំដើម្បីការពារសិទ្ធិការងាររបស់អ្នកមានមេរោគ HIV ទទួលបានការការពារ និងបង្កើន លទ្ធភាពការធ្វើតេស្តរកមេរោគ HIV និងសេវាកម្មព្យាបាល[19] ។

## តារាង ៣.១៥ កម្មករដែលបានពិនិត្យកាយសម្បទា

| ភេទ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|
| ទាំងពីរភេទ | **34 646** | **43 100** | **23 547** | **142 837** | **121 525** | **98 480** |
| ស្រី | 24 518 | 29 014 | 17 074 | 110 796 | 92 534 | 58 670 |
| ប្រុស | 10 128 | 14 086 | 6 473 | 32 041 | 28 991 | 39 810 |

ប្រភព: នាយកដ្ឋានសុខភាព និងសុវត្ថិភាពការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

តារាង ៣.១៦ បង្ហាញពីចំនួនគ្រោះថ្នាក់ដោយការងារ ដែលរាយការណ៍ដោយនាយកដ្ឋានសន្តិសុខ សង្គមពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០០៥ ។ ភាគច្រើននៃរបាយការណ៍បានមកពីកម្មការិនីដែលធ្វើការក្នុង ឧស្សាហកម្មសំលៀកបំពាក់។ ភាគច្រើននៃចំនួនករណីគ្រោះថ្នាក់ គឺការខ្សោយ ឬសន្លប់ដោយសារបរិយា កាសកន្លែងធ្វើការក្តៅ និងធូលី ឬដោយការធ្វើការថែមម៉ោងហួសកំរិត ។ មូលហេតុចំបងនៃគ្រោះថ្នាក់ ដល់ស្លាប់ គឺដោយសារគ្រោះថ្នាក់ចរាចរណ៍ ។ ចំនួនគ្រោះថ្នាក់ក្នុងវិស័យសំណង់នៅមានកំរិតទោះបីការ ងារសំណង់ជាការងារមួយប្រឈមនឹងគ្រោះថ្នាក់ក៏ដោយ ។ គេត្រូវពង្រឹងរបាយការណ៍ស្តីពីការគ្រោះថ្នាក់ ក្នុងវិស័យសំណង់ ក៏ដូចជាវិស័យកម្មន្តសាល ។ ដូចមានពន្យល់ក្នុងប្រអប់ ៥ រដ្ឋាភិបាលកំពុងធ្វើការ កែលម្អប្រព័ន្ធរាយការណ៍ ។

## តារាង ៣.១៦ របាយការណ៍គ្រោះថ្នាក់ការងារ

| | ២០០៣ | | ២០០៣ | | ២០០៣ | | ២០០៤ | | ២០០៥ | |
|---|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| ឧស្សាហកម្មសំលៀកបំពាក់ | 2(2) | 242(7) | 29 | 211 (1) | 14 | 373(3) | 1 | 269 | 1 | 208 |
| ឡុតដ្ឋ | 0 | 0 | 0 | 0 | 0 | 0 | 1 | | 2 | 0 |
| កម្មន្តសាល | 1(1) | 6(6) | 1(1) | 0 | 0 | 0 | 2 (1) | 130 | 0 | 0 |
| សំណង់ | 0 | 0 | 1(1) | 0 | 0 | 0 | 0 | 0 | 0 | 0 |
| សរុប | 3(3) | 248(13) | 31(2) | 211(1) | 14 | 373(3) | 4(1) | 399 | 3 | 208 |

ប្រភព: នាយកដ្ឋានសន្តិសុខសង្គម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ប្រអប់ទី ៥
## ប្រព័ន្ធអភិវឌ្ឍន៍ដើម្បីកែលម្អបាយការណ៍គ្រោះថ្នាក់នៅកន្លែងធ្វើការ

[19] Report on the Achievements of Ministry of Labour and Vocational Training for the Third Mandate and Its Objectives to be continued, dated 20 February 2009.

ប្រទេសកម្ពុជាបច្ចុប្បន្នកំពុងកែលម្អប្រព័ន្ធរាយការណ៍គ្រោះថ្នាក់ដោយសារការងារ និងជម្ងឺ ដើម្បីបង្កើតស្ថិតិជាតិមួយដែលអាច ទុកចិត្តបាន និងផ្តល់ការទូទាត់សមស្របដល់ជនរងគ្រោះ ។ ព័ត៌មានស្ថិតិគ្របដណ្តប់មួយផ្នែកនៃការរងគ្រោះថ្នាក់ និងជម្ងឺ និង ការប្រុងប្រយ័ត្ន ។ តារាងខាងក្រោមផ្តល់នូវចំនួនគ្រោះថ្នាក់ដោយមុខរបរតាមវិស័យការងារ ភេទ និងប្រភេទគ្រោះថ្នាក់ដែលបានរាយការណ៍ដោយបេឡាជាតិ សន្តិសុខសង្គមឆ្នាំ ២០០៩ ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យគ្រោះថ្នាក់ដោយមុខរបរមិន បានគ្របដណ្តប់គ្រប់ខេត្ត និងកន្លែងធ្វើការឡើយ ពីព្រោះគំរោងគ្រោះថ្នាក់ដោយការងារ ពួកគេគ្របដណ្តប់តែការចុះបញ្ជី សម្រាប់វិស័យការងាររៀបរយ ដែលភាគច្រើននៅរាជធានីភ្នំពេញ និងខេត្តមួយចំនួនជាប់ភ្នំពេញដូចជាកណ្តាល និងកំពង់ស្ពឺ ។ ទោះបីទិន្នន័យនេះនៅមានកំរិត តែវាបានបង្ហាញច្បាស់ថា កម្មការិនីជាច្រើនក្នុងវិស័យកាត់ដេរ និងកម្មន្តសាលរងគ្រោះថ្នាក់ ដោយការងារ និងត្រូវយកចិត្តទុកដាក់ដល់ការកែលម្អលក្ខខណ្ឌការងាររបស់ពួកគេ ។

## ហានិភ័យការងារតាមសកម្មភាពសេដ្ឋកិច្ច ភេទ និងកម្រិតគ្រោះថ្នាក់ ឆ្នាំ ២០០៨ ២០០៩ ២០១០ (ដល់ខែតុលា)

| សកម្មភាពសេដ្ឋកិច្ច | ចំនួនជនរងគ្រោះ | | | | កម្រិតគ្រោះថ្នាក់ | | |
|---|---|---|---|---|---|---|---|
| | សរុប | ស្រី | ប្រុស | ស្លាប់ | អសមត្ថភាពបណ្តោះអាសន្ន | អសមត្ថភាពអចិន្ត្រៃយ៍>20% | អសមត្ថភាពអចិន្ត្រៃយ៍<20% |
| កាត់ដេរ | 8 061 | 6 967 | 1 094 | 26 | 8 011 | 8 | 16 |
| ធនាគារ | 409 | 108 | 301 | 2 | 407 | 0 | 0 |
| សណ្ឋាគារ | 272 | 111 | 161 | 4 | 268 | 0 | 0 |
| ផ្សារទំនើប | 43 | 17 | 26 | 0 | 43 | 0 | 0 |
| ព្រលានយន្តហោះ | 21 | 4 | 17 | 0 | 21 | 0 | 0 |
| សំណង់ | 25 | 4 | 21 | 0 | 25 | 0 | 0 |
| ទូរគមនាគមន៍ | 24 | 6 | 18 | 2 | 22 | 0 | 0 |
| សន្តិសុខ | 57 | 7 | 50 | 1 | 56 | 0 | 0 |
| ផលិតស្រាបៀរ | 73 | 31 | 42 | 0 | 73 | 0 | 0 |
| រោងពុម្ព | 105 | 56 | 49 | 0 | 105 | 0 | 0 |
| ដឹកជញ្ជូន | 36 | 6 | 30 | 0 | 36 | 0 | 0 |
| ផលិតស្បៀង | 13 | 8 | 5 | 0 | 13 | 0 | 0 |
| លក់ប្រេងឥន្ធនៈ | 21 | 3 | 18 | 0 | 21 | 0 | 0 |
| ផលិតខ្សែកាប | 9 | 0 | 9 | 0 | 8 | 0 | 1 |
| ផលិតគ្រឿង | 6 | 0 | 6 | 0 | 5 | 1 | 0 |
| អនាម័យ | 44 | 9 | 35 | 1 | 41 | 2 | 0 |
| ផលិតចំណីសត្វ | 3 | 0 | 3 | 0 | 3 | 0 | 0 |
| ផលិតស្បែកជើង | 621 | 501 | 120 | 8 | 602 | 4 | 7 |
| ទិញ-លក់អចលនទ្រព្យ | 20 | 4 | 16 | 0 | 20 | 0 | 0 |
| បោកគក់ | 9 | 5 | 4 | 0 | 9 | 0 | 0 |
| ប្ដូរប្រេង និងឧស្ម័ន | 5 | 1 | 4 | 0 | 5 | 0 | 0 |
| ផលិតកម្មក្រដាស់ | 5 | 1 | 4 | 0 | 5 | 0 | 0 |
| តម្បាញ | 431 | 416 | 15 | 0 | 431 | 0 | 0 |
| លក់កុំព្យូទ័រ | 5 | 1 | 4 | 0 | 5 | 0 | 0 |
| ផលិតដែក | 19 | 0 | 19 | 1 | 18 | 0 | 0 |
| ភោជនីយដ្ឋាន | 43 | 27 | 16 | 1 | 42 | 0 | 0 |
| ការចិញ្ចឹមសត្វ និងដាំដំណាំ | 4 | 0 | 4 | 0 | 4 | 0 | 0 |
| ផលិតកម្មចំណី | 2 | 0 | 2 | 0 | 2 | 0 | 0 |
| ការអប់រំ | 16 | 9 | 7 | 0 | 16 | 0 | 0 |
| ផលិតឈើ និងស្មោរ | 17 | 9 | 8 | 0 | 17 | 0 | 0 |
| លក់ម៉ាស៊ីន បរិក្ខារ និងផ្គត់ផ្គង់ | 3 | 2 | 1 | 0 | 3 | 0 | 0 |
| ជ្រើសរើសពលករ | 1 | 0 | 1 | 0 | 1 | 0 | 0 |
| សកម្មភាពកំពង់ផែ | 5 | 0 | 5 | 0 | 5 | 0 | 0 |
| ផលិតកម្មផ្លាស្ទីក | 1 | 0 | 1 | 0 | 1 | 0 | 0 |
| ផលិតម៉ូតូ | 41 | 19 | 22 | 0 | 41 | 0 | 0 |
| លក់រថយន្ត | 1 | 0 | 1 | 0 | 1 | 0 | 0 |
| ធានារ៉ាប់រង | 8 | 4 | 4 | 0 | 8 | 0 | 0 |
| អគ្គិសនី | 28 | 3 | 25 | 0 | 28 | 0 | 0 |
| វេចខ្ចប់ | 17 | 7 | 10 | 0 | 17 | 0 | 0 |
| ផលិតល្បែងក្មេងកំសាន្ត | 3 | 3 | 0 | 0 | 3 | 0 | 0 |
| ផលិតកម្មដែក និងស័ង្កសី | 9 | 1 | 8 | 0 | 9 | 0 | 0 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| លក់ទំនិញគ្រួសារ | 1 | 1 | 0 | 0 | 1 | 0 | 0 |
| លក់ដុំទំនិញផ្សេង ៗ | 16 | 7 | 9 | 0 | 16 | 0 | 0 |
| សកម្មភាពកីឡា | 3 | 1 | 2 | 0 | 3 | 0 | 0 |
| បំរើសេវាកម្មផ្សេង ៗ | 6 | 3 | 3 | 0 | 6 | 0 | 0 |
| អង្គការក្រៅរដ្ឋាភិបាល | 3 | 1 | 2 | 0 | 3 | 0 | 0 |
| ផលិតកម្មសំភារៈវេចខ្ចប់ | 2 | 0 | 2 | 0 | 2 | 0 | 0 |
| មន្ទីរពេទ្យ | 1 | 1 | 0 | 0 | 1 | 0 | 0 |
| ម៉ាស្សា | 2 | 0 | 2 | 0 | 2 | 0 | 0 |
| ផលិតទឹកស៊ីអ៊ីវ | 1 | 0 | 1 | 0 | 1 | 0 | 0 |
| លក់អាហារភេសជ្ជៈ និងថ្នាំជក់ | 1 | 1 | 0 | 0 | 1 | 0 | 0 |
| ផលិតកង់ | 13 | 9 | 4 | 0 | 13 | 0 | 0 |
| ផលិតប៉ូឡូង | 4 | 1 | 3 | 0 | 4 | 0 | 0 |
| ផលិតទឹកកក | 1 | 0 | 1 | 1 | 0 | 0 | 0 |
| ទឹកស្អាត | 1 | 0 | 1 | 0 | 1 | 0 | 0 |
| លក់វត្ថុអនុស្សាវរីយ៍ | 5 | 5 | 0 | 0 | 5 | 0 | 0 |
| ក្រុមហ៊ុនទេសចរណ៍ | 1 | 0 | 1 | 0 | 1 | 0 | 0 |
| **សរុប** | **10 597** | **8 380** | **2 217** | **47** | **10 511** | **15** | **24** |

ប្រភព: របាយការណ៍ប្រចាំឆ្នាំ ស្តីពីបេឡាជាតិរបបសន្តិសុខសង្គម ២០១០

## ៣.២.៨ កុមារធ្វើការ

រាជរដ្ឋាភិបាលកម្ពុជា កំពុងពិនិត្យមើលការប្រើប្រាស់ពលកម្មកុមារ ដោយផ្តោតលើចំណុចពីរជា ចំបង គឺ i) លប់បំបាត់ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងកាត់បន្ថយគ្រោះថ្នាក់ដោយឧប្បត្តិហេតុលើកុមារ និង ii) ប្រយុទ្ធប្រឆាំងការជួញដូរកុមារ និងស្ត្រី ។

តារាង ៣.១៧ បង្ហាញអំពីចំនួនកុមារធ្វើការ[20] តាមសកម្មភាពចំបង និងសមាមាត្រនៃកុមារអាយុ ៥-១៧ ឆ្នាំ។ "សកម្មភាពចំបង" កំណត់ដោយការងារក្នុងរយៈពេល ៦ ខែឡើង(១៨៣ ថ្ងៃ) ឬច្រើនជាងក្នុង រយៈពេលមួយឆ្នាំមុនកាលបរិច្ឆេទធ្វើជំរឿន ។ យោងតាមលទ្ធផលសមាមាត្រនៃកុមារធ្វើការបានកើនឡើង ពី ៨,៣ ភាគរយនៃកុមារទាំងអស់ក្នុងឆ្នាំ ១៩៩៨ ទៅ ៩,៧ ភាគរយនៅឆ្នាំ ២០០៨ ។ កំណើននេះដោយ សារក្មេងប្រុសធ្វើការមានចំនួនច្រើន (៩,១ ភាគរយ) នៅឆ្នាំ ២០០៨ ជាងនៅឆ្នាំ ១៩៩៨ (៦,៤ ភាគរយ)។ សមាមាត្រក្មេងស្រីធ្វើការនៅរក្សាដូចគ្នាសំរាប់ឆ្នាំទាំងពីរ ទោះបីកំរិត ១០,៣ ភាគរយវាខ្ពស់ជាងកំរិតក្មេង ប្រុសក៏ដោយ ។

### តារាង ៣ .១៧ សមាមាត្រនៃកុមារធ្វើការអាយុ ៥-១៧ ឆ្នាំ តាមប្រភេទ

| ភេទ | ១៩៩៨ | | ១៩៩៨ | |
|---|---|---|---|---|
| | កុមារសរុប | កុមារធ្វើការ (%) | កុមារសរុប | កុមារធ្វើការ (%) |
| ទាំងពីរភេទ | 4 302 819 | 8.3 | 4 115 093 | 9.7 |
| ប្រុស | 2 192 072 | 6.4 | 2 122 599 | 9.1 |
| ស្រី | 2 110 747 | 10.3 | 1 992 494 | 10.3 |

ប្រភព - NIS/MOP ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨
- NIS/MOP ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨

ទិន្នន័យជំរឿនបង្ហាញថាចំនួនកុមារធ្វើការ (អាយុ៥-១៧ ឆ្នាំ) បានកើនឡើង ៤០.៤០០ នាក់ (១១.៣ ភាគរយ) ។ ចំពោះកុមារអាយុ ៥-១៤ ឆ្នាំបានកើនឡើងដល់ ៣២,១ ភាគរយ ។ សមាមាត្រកុមារ ធ្វើការក្នុងវិស័យកសិកម្ម បានថយចុះក្នុងអំឡុងមួយទស្សវត្សរ៍ ខណៈដែលសមាមាត្រក្នុងវិស័យឧស្សាហា កម្ម និងសេវាកម្មបានកើនឡើង ។ ក្នុងវិស័យឧស្សាហាកម្មចំនួនកុមារធ្វើការមាន ១១,២ ភាគរយនៃកុមារ ធ្វើការទាំងអស់នៅឆ្នាំ ២០០៨ ដោយកើនឡើងពី ៥,២ ភាគរយនៅឆ្នាំ ១៩៩៨ ។ សមាមាត្រក្មេងស្រីធ្វើការ ក្នុងវិស័យឧស្សាហាកម្មនៅឆ្នាំ ២០០៨ កើនឡើងដល់ ១៤,៥ ភាគរយបន្ទាប់ពីមានតែ ៥,៩ ភាគរយនៅឆ្នាំ ១៩៩៨ និងច្រើនជាងក្មេងប្រុស (៧,៧ ភាគរយ) ។ ទោះជាយ៉ាងណាក៏ដោយ សមាមាត្រនៃក្មេងប្រុសធ្វើ ការក្នុងវិស័យសេវាកម្មនៅឆ្នាំ ២០០៨ មានក្នុងអត្រា (១៣,៣ ភាគរយ) ខ្ពស់ជាងក្មេងស្រី (៩,៨ ភាគ រយ) ។ អ្វីដែលគួរឲ្យកត់សំគាល់នោះ

[20] "Children who worked" is defined as those children whose "main" activity was "employed" in the past 12 months.

គឺចំនួនកុមារធ្វើការភាគច្រើនស្ថិតក្នុងអាយុ ១៥-១៧ ឆ្នាំហើយ ចំនួនក្មេងប្រុសធ្វើការបានកើនឡើងគួរឲ្យកត់សម្គាល់ក្នុងក្រុមអាយុនេះរវាងឆ្នាំ ១៩៩៨ និង ២០០៨ (មើលឧបសម្ព័ន្ធ តារាង ២៥) ។

ដូចបានរៀបរាប់រួចមកហើយកុមារទាំងអស់ដែលមានអាយុ ៦ ឆ្នាំចុះត្រូវបានសន្មត់ជាអនក្ខរភាព ទោះបីគេទៅសាលារៀន ឬមានលទ្ធភាពអាចអាន និងសរសេរខ្លះៗក៏ដោយ ។ ជំរឿនទាំងពីរសួរអំពីថ្នាក់ដែលបានបញ្ចប់ខ្ពស់ជាងគេរបស់គ្រប់មនុស្សដែលបានរាយការណ៍ថា គេធ្លាប់បានចូលរៀនសាលា ឬគ្រឹះ ស្ថានអប់រំណាមួយ ។ កុមារធ្វើការភាគច្រើនមានកំរិតបឋមសិក្សា ឬចាប់ផ្តើមចូលរៀន ឬបានបោះបង់ការ សិក្សា ។ ការផ្លាស់ប្តូរធំជាងគេបានបង្ហាញក្នុងចំណោមកុមារធ្វើការបានបញ្ចប់កំរិតបឋមសិក្សាបានកើន ឡើង ៣១ ភាគរយ ក្នុងឆ្នាំ ២០០៨ បន្ទាប់ពី ១៣ ភាគរយនៅឆ្នាំ ១៩៩៨ ។ ប៉ុន្តែសមាមាត្រនៃកុមារធ្វើការដែលទទួលបានកំរិតមធ្យមសិក្សាបឋមភូមិនៅឆ្នាំ ២០០៨ បានកើនឡើង ៨,៦ ភាគរយនៃកុមារទាំង អស់ ២,១ ភាគរយនៅឆ្នាំ ១៩៩៨ (សូមមើលឧបសម្ព័ន្ធ តារាង ២៧)។

## ៣.២.៩ ទំនាក់ទំនងវិជ្ជាជីវៈ ដំណោះស្រាយវិវាទ និងអនុសញ្ញារួម

### *ទំនាក់ទំនងវិជ្ជាជីវៈ*

ចាប់ពីស្ទើរគ្មានអ្វីសោះនៅដើមឆ្នាំ ១៩៩០ ទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជាបានរីកចំរើនយ៉ាងលឿន ក្នុងរយៈពេល ១៥ ឆ្នាំកន្លងទៅ និងជាពិសេសក្នុងរយៈពេល ៥ ឆ្នាំកន្លងមក ។ សហជីពបានចាប់ផ្តើមបង្កើតឡើងមុនការយល់ព្រមច្បាប់ការងារឆ្នាំ ១៩៩៧ ។ ប្រព័ន្ធដោះស្រាយវិវាទត្រូវបានបង្កើតភ្លាម ហើយ បច្ចុប្បន្ន រួមមានយន្តការសំរុះសំរួល និងអាជ្ញាកណ្តាល។ ការបង្កើតនូវអនុសញ្ញារួម ដែលបានចាប់ផ្តើមក្នុងវិស័យសណ្ឋាគារក្នុង ឆ្នាំ ២០០៤ ។ និយោជិត និងនិយោជកបានធ្វើការពិភាក្សាជាប្រចាំ ហើយរាជរដ្ឋាភិ បាលបានអនុម័តគោលនយោបាយដើម្បីលើកកំពស់អនុសញ្ញារួម ។

### *ច្បាប់ និងក្របខ័ណ្ឌការងារច្បាប់*

ច្បាប់ការងារឆ្នាំ ១៩៩៧ ការពារសិទ្ធិនិយោជិត វិស័យឯកជន ដើម្បីបង្កើតនិងចូលរួមក្នុងសហជីព ទៅតាមជំរើសរបស់ពួកគេ។ ច្បាប់នេះបានផ្តល់ផងដែរនូវនីតិវិធីសម្រាប់ធ្វើកូដកម្ម និងការផ្អាកសកម្មភាព និងដោះស្រាយវិវាទ និងអនុសញ្ញារួម ។ ច្បាប់នេះបានបន្ថែមដោយប្រកាសមួយចំនួន និងបទបញ្ញត្តិផ្សេង ៗ ទៀតដែលគ្របដណ្តប់លើការធ្វើកូដកម្ម និងនីតិវិធីធ្វើកូដកម្ម ការចុះបញ្ជីសហជីព នីតិវិធីធ្វើអនុសញ្ញា រួម និងតំណាងសហជីព ។

ប្រទេសកម្ពុជាបានឲ្យសច្ចាប័នលើអនុសញ្ញាចំនួន ៨ របស់ ILO ក្នុងឆ្នាំ ១៩៩៩ ដែលគ្របដណ្តប់ទៅលើបញ្ហាទាំងនេះ។

## *ស្ថាប័ន*

ចំនួនស្ថាប័នដ៏ច្រើន និងសហជីពជាន់ខ្ពស់បានបង្កើតឡើងតាំងពីពាក់កណ្តាលឆ្នាំ ១៩៩០។ បច្ចុប្បន្ន សហជីពមានចំនួន ១.៦៨៧ បានចុះបញ្ជីតាំងពីមានច្បាប់ស្តីពីការងារ ដែលស្ថិតនៅក្រោមសហព័ន្ធចំនួន ៤២ និង ៥ សហភាពសហព័ន្ធសហជីព ក៏ដូចជាស្ថាប័នឯករាជ្យ ឬមិនមែនសាខា ។ សហព័ន្ធ ២៨ តំណាងឲ្យកម្មករក្នុងវិស័យកាត់ដេរ ។ សហព័ន្ធនិយោជកកម្ពុជា និងសមាគមអាជីវកម្ម (បង្កើតនៅឆ្នាំ ២០០០) ជាស្ថាប័នបំរើឲ្យសមាគមនិយោជកដែលមានសមាជិកដោយផ្ទាល់ និងដោយប្រយោលជាង ៩០០ ។ សមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) គឺជាសមាគមនិយោជកចំណាស់ជាងគេ និងផ្តល់ទំនាក់ ទំនងវិជ្ជាជីវៈ និងសេវាកម្មដោះស្រាយវិវាទឲ្យគ្រប់សមាជិក ។ MOLVT ទទួលខុសត្រូវចុះបញ្ជីសហជីព និងសហព័ន្ធ សហជីព និងអង្គការនិយោជក ។

### តារាង ៣.១៨ ការចុះបញ្ជីសហជីព

| | ២០០៨ | ២០០៩ | | សរុប |
|---|---|---|---|---|
| | | សមាជិកថ្មី | ចុះបញ្ជីឡើងវិញ | |
| ចំនួនសហជីពដែលបានចុះបញ្ជីកំរិតសហគ្រាស | 265 | 163 | 182 | 610 |

ប្រភព - MOLVT

ពីឆ្នាំ ១៩៩៧ រហូតដល់ចុងឆ្នាំ ២០០៩ MOLVT បានចេញវិញ្ញាប័នបត្រចុះបញ្ជីឲ្យសហជីព សហគ្រាសចំនួន ១.៦៨៧ ។ ទិន្នន័យនេះមិនរាប់បញ្ចូលសហព័ន្ធសហជីពចំនួន ៣៩ និងសហភាពសហព័ន្ធសហជីពចំនួន៧។ បន្ថែមពីនេះទៀត សហជីពសហគ្រាសចំនួន ៣៨ និងសហព័ន្ធសហជីពចំនួន ២ បានចុះ បញ្ជីក្នុងត្រីមាសទីមួយឆ្នាំ ២០១០ ដែលនៅចុងឆ្នាំ ២០០៩ មានសហជីពដែលបានចុះបញ្ជីចំនួន ១.៧២៥ ។ តាមការប៉ាន់ស្មាន មួយភាគបីនៃសហជីពដែលបានចុះបញ្ជីនេះ កំពុងមានសកម្មភាព ។ នេះដោយសារវិញ្ញាប័នបត្រចុះបញ្ជី មានសុពលភាពត្រឹមរយៈពេល ២ ឆ្នាំដែលកំណត់ឲ្យសហជីពដែលបានចុះបញ្ជីឆ្នាំ ២០០៨ ត្រូវផុតកំណត់ ។ នៅឆ្នាំ ២០០៩ មានតែ ១៦៣ សហជីពសហគ្រាសដែលបានចុះបញ្ជីថ្មី ។ ដូច្នេះ ចំនួនពិតនៃសហជីពសហគ្រាសនៅមានសកម្មភាពត្រូវបានប៉ាន់ស្មានប្រមាណ ៦១០ (សរុបដោយបន្ថែម តួលេខឆ្នាំ ២០០៨ (២៦៥) ជាមួយតួលេខឆ្នាំ ២០០៩ (១៦៣) និងចំនួនបានចុះបញ្ជីឡើងវិញក្នុងឆ្នាំ ២០០៩ (១៨២) ។

ស្ថាប័នជាតិត្រីភាគី គឺជាគណៈកម្មាធិការប្រឹក្សាការងារដឹកនាំដោយ MOLVT។ នេះជាយន្តការសំ រាប់ពិភាក្សា និងអនុម័តគោលនយោបាយជាតិស្តីពីការងាររួមទាំងការកំណត់ប្រាក់ឈ្នួលអប្បមរមា ។ ថ្មីៗនេះរាជរដ្ឋាភិបាលបានបង្កើតក្រុមការងារចំនួន ៨ ស្តីពីទំនាក់ទំនងវិជ្ជាជីវៈក្រោមវេទិការាជរដ្ឋាភិបាល និង វិស័យឯកជន និងយុត្តធិកាសំខាន់ៗផ្សេងទៀតសម្រាប់ពិភាក្សាអំពីការងារ និងបញ្ហាទំនាក់ទំនងវិជ្ជាជីវៈ ។

## *វិវាទ និងដំណោះស្រាយវិវាទ*

ប្រទេសកម្ពុជា បានអភិវឌ្ឍន៍ឆាប់រហ័សនូវសមត្ថភាពនៃប្រព័ន្ធដោះស្រាយវិវាទតាមរយៈនាយកដ្ឋានវិវាទការងារ (DLD) នៃ MOLVT ដែលមានទទួលខុសត្រូវក្នុងការសម្រុះសម្រួល មន្ទីរការងាររាជធានី ខេត្តឲ្យអនុវត្តមុខងារស្រដៀងគ្នានេះ ។ DLD ជាលេខាធិកាឲ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្កើតឡើងនៅឆ្នាំ ២០០៣ បានក្លាយទៅជាសមាសភាគមួយដ៏សំខាន់នៃប្រព័ន្ធ ទំនាក់ទំនងវិជ្ជាជីវៈ ។ ក្រុមប្រឹក្សានេះមានអាជ្ញាកណ្តាលធ្វើការមិនពេញម៉ោងចំនួន ៣០ នាក់ដែលមួយ ក្រុមមាន ១០ នាក់ជ្រើសដោយសហជីពនិយោជក និង MOLVT ដែលត្រូវបានជ្រើសតាំងដោយច្បាប់ ដើម្បីដោះស្រាយវិវាទរួម ដែលមិនអាចដោះស្រាយបាន តាមរយៈការសម្រុះសម្រួល ។ ក្រុមប្រឹក្សាអាជ្ញា កណ្តាលបានទទួលជាង ៩០០ ករណី និងកើនឡើងទៀតតាមការជឿជាក់របស់អ្នកប្រើប្រាស់ ។ អ្នក សង្កេតបានកត់សម្គាល់ថាគេអាចបន្តពង្រឹងក្រុមប្រឹក្សានេះតាមរយៈការប្រើប្រាស់អាជ្ញាកណ្តាល សម្រាប់សិទ្ធិក្នុងវិវាទ ។

តារាង ៣.១៩ វិវាទការងារ

| សកម្មភាព | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|---|---|---|
| វិវាទ | **146** | **118** | **155** | **229** | **148** | **217** | **186** | **174** | **131** |
| ដោះស្រាយ | 140 | 116 | 138 | 157 | 82 | 142 | 103 | 90 | 44 |
| បញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល | 0 | 0 | 15 | 72 | 66 | 75 | 83 | 84 | 87 |

ប្រភព - នាយកដ្ឋានវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ការធ្វើកូដកម្មក្នុងសណ្ឋាគារនៅឆ្នាំ ២០០៤ នាំឲ្យមានកិច្ចព្រមព្រៀងរវាងសហជីព និងអ្នក គ្រប់គ្រងដែលបានពិនិត្យពិច័យជាច្រើនលើក ។ ទាំងនេះអាចជួយឲ្យមានទំនាក់ទំនងល្អរវាងភាគី និង ដើម្បីលុបបំបាត់ការធ្វើកូដកម្មក្នុងសហគ្រាសដែលមានកិច្ចព្រមព្រៀងដ៏ល្អមួយ ។

## *ភាពជាតំណាងបំផុត និងអនុសញ្ញារួម*

ច្បាប់ស្តីពីការងារកម្ពុជា និងបទបញ្ញត្តិគាំទ្រទស្សនាទាននៃភាពជាតំណាងបំផុត (MRS) ដោយ ហេតុនេះសហជីពមួយមានយ៉ាងហោចណាស់ ៥១ ភាគរយនៃកម្មករធ្វើការក្នុងសហគ្រាស ជាសមាជិត អាចត្រូវបានកំណត់សិទ្ធិដើម្បីតំណាងឲ្យកម្មករទាំងអស់ក្នុងសហគ្រាស សម្រាប់គោលបំណងអនុសញ្ញា រួម ។ ពហុសហជីពត្រូវបានអនុញ្ញាត្តិឲ្យដំណើរការនេះ គឺជាគន្លឹះដើម្បីឲ្យអនុសញ្ញារួមចាស់របស់និយោ ជកអាចចរចារជាមួយសហជីព ។ បទប្បញ្ញត្តិថ្មីនៅឆ្នាំ ២០០៨ ជួយសំរួលចេញវិញ្ញាបនបត្រ សហជីព MRS ដោយ MOLVT ជាលទ្ធផលមាន ៩០០ ភាគរយ បានកើនឡើងវិញ្ញាបនបត្រថ្មីដែលមានចំនួន ២០០ វិញ្ញាបនបត្រ MRS ។

តារាង : ៣.២០ ភាពជាតំណាងបំផុត (MRS)

| | ២០០២-២០០៦ | ២០០៧ | ២០០៨ | ២០០៩ | សរុប |
|---|---|---|---|---|---|
| ចំនួនវិញ្ញាប័នបត្រ MRS | 122 | 9 | 36 | 35 | **202** |

ប្រភព - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អនុសញ្ញារួម បានក្លាយជាការអនុវត្តន៍ដ៏ល្អមួយ ក្នុងចំណោមសណ្ឋាគារ និងសហគ្រាសជាច្រើន ប៉ុន្តែនៅកែសំរួលក្នុងឧស្សាហកម្មកាត់ដេរ ។ ជាការពិត ការសន្ទនា និងសមត្ថភាពក្នុងចំណោមភាគីបន្ត បង្កើតឡើង ហើយកំពុងទទួលយក និងអនុវត្តន៍ដ៏ទូលំទូលាយ ។

តារាង ៣.២១ កិច្ចព្រមព្រៀងអនុសញ្ញារួម

| | ២០០២-២០០៦ | ២០០៧ | ២០០៨ | ២០០៩ | សរុប |
|---|---|---|---|---|---|
| ចំនួនកិច្ចព្រមព្រៀងអនុសញ្ញារួម | 45 | 19 | 11 | 131 | **206** |

ប្រភព - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

នៅឆ្នាំ ២០០៧ និងឆ្នាំ ២០០៨ របាយការណ៍បង្ហាញពីការកើនឡើងនៃការចុះបញ្ជី CBA នៅក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងអត្រាប្រចាំឆ្នាំ ១៥ ភាគរយដែលខ្ពស់ជាងអត្រាមធ្យម ១១ CBA ក្នុងមួយឆ្នាំ ២០០៣ និង ២០០៦ ។ ចំនួន CBA កើនឡើងរហូតដល់ ១៣១ នៅឆ្នាំ ២០០៩ និងនៅត្រីមាសទី ១ ឆ្នាំ ២០១០ មានចំនួន CBA ២៤ ទៀតបានចុះបញ្ជី ។ ទោះជាយ៉ាងណាក៏ដោយប្រហែលពាក់កណ្តាលនៃ CBA ជឿថាបានបញ្ចប់ដោយបានកាន់កាប់ហាងទំនិញ និងប្រមាណពីរភាគបីដែលនៅសល់មួយភាគបាន បញ្ចប់ដោយសហជីពភាគតិច ។ លើសពីនេះទៅទៀត CBA ជាប់ទាក់ទងភាគច្រើនជាបញ្ហាទោល និង ស្ថិតលើមូលដ្ឋានតូចតាចជាជាងតាមរយៈដំណើរការអនុសញ្ញារួម ។

ដូច្នេះតាមការប៉ាន់ស្មាន CBA ដែល មានគុណភាពខ្ពស់ចំនួន ៣០ ត្រូវបានបញ្ចប់ដោយ MRS សហជីពលើគ្រប់វិស័យ (កាត់ដេរសំលៀកបំពាក់ និងផលិតផលស្បែកជើង សណ្ឋាគារ ម្ហូបអាហារ និងភេសជ្ជៈ សំណង់...។ល។)

## *ការកំណត់ប្រាក់ឈ្នួលអប្បបរមា*

វាមានសារៈសំខាន់ណាស់ ក្នុងការទម្លុះភាពទាល់ច្រកក្នុងឆ្នាំ ២០០៦ ដែលជាលើកទីមួយហើយ ដែលគ្រប់សហព័ន្ធសហជីពក្នុងវិស័យកាត់ដេរ និង GMAC បានយល់ព្រមចរចារប្រាក់ឈ្នួលអប្បបរមាថ្មី សម្រាប់កម្មករក្នុងវិស័យតម្បាញ និងកាត់ដេរ ។ ការចរចារនេះមានរយៈពេលបួនខែ ហើយដែលចុងបញ្ចប់ ភាគីទាំងសងខាងមិនបានឈានដល់កិច្ចព្រមព្រៀងឡើយ ។ បទពិសោធន៍នេះ បង្កើតជាមូលដ្ឋានសម្រាប់ ធ្វើឲ្យប្រសើរឡើងនូវការទំនាក់ទំនង ។

## ៣.៣ សេចក្តីសន្និដ្ឋាន

ជំពូកនេះបង្ហាញពីនិន្នាការសេដ្ឋកិច្ច សង្គមកិច្ច និងការងារនៅកម្ពុជា ។ ចំណុចសំខាន់ៗ ដែលបានពី ការវិភាគរួមមានៈ

- កម្ពុជាមានសក្ខីកម្មបញ្ជាក់ពីកំណើនសេដ្ឋកិច្ចដ៏រឹងមាំមួយ យ៉ាងហោចណាស់មុនវិបត្តិសេដ្ឋកិច្ច និង បានរួមចំណែកបន្ថយភាពក្រីក្រ និងភាពគ្មានការងារធ្វើ ។ ក្នុងពេលដូចគ្នានេះដែរប្រទេសបានធ្វើ ការអភិវឌ្ឍន៍គួរឲ្យកត់សម្គាល់ក្នុងការកែលម្អបរិយាកាសទំនាក់ទំនងវិជ្ជាជីវៈ ដោយបង្កើតនូវ ស្ថាប័នសមស្រប ។ ទោះជាយ៉ាងណាក៏ដោយ ការបែងចែកកំណើនសេដ្ឋកិច្ចនេះមិនគ្រប់គ្រាន់ ឡើយដែលនាំឲ្យមានវិសមភាពខាងចំណូល និងចំណាយ ។
- កម្លាំងពលកម្មរបស់ប្រទេសមានការប្រែប្រួលក្នុងមួយទស្សវត្សរ៍កន្លងមក ខណៈដែលអត្រាចូល រួមកម្លាំងពលកម្មកើនឡើងបន្តិច ហើយសមាមាត្រនៃស្ត្រីក្នុងកម្លាំងពលកម្ម បានកើនឡើងគួរ ឲ្យកត់សម្គាល់ និងបន្ថយគំលាតយេនឌ័រក្នុងអត្រាចូលរួមកម្លាំងពលកម្ម ។ នេះគឺជាផ្នែកមួយ នៃចំនួនដ៏ច្រើនរបស់ស្ត្រីធ្វើការឲ្យគ្រួសារដោយមិនយកប្រាក់ឈ្នួល និងជាផ្នែកមួយនៃការកើន ឡើងប្រាក់ឈ្នួលការងារក្នុងវិស័យកាត់ដេរ ។ ស្ត្រីចូលរួមក្នុងកម្លាំងពលកម្ម នៅអាយុក្មេងជាង បុរស

ពីព្រោះបុរសត្រូវបានលើកទឹកចិត្តឲ្យនៅសិក្សាបានយូរ ។ សមាមាត្រការងារក្នុងវិស័យ ទីមួយបានធ្លាក់ចុះ និងការផ្លាស់ប្តូរលំនៅដ្ឋានក្នុងស្រុក (ភាគច្រើនពីជនបទទៅកាន់ទីប្រជុំជន) មានចំនួនកើនឡើងជាមួយនឹងសមាមាត្រនៃស្ត្រីផ្លាស់ប្តូរលំនៅដ្ឋានក្នុងស្រុកបានកើនបន្តិច ។

- ខណៈដែលរាជរដ្ឋាភិបាល កំពុងធ្វើការបង្កើតប្រព័ន្ធគាំពារសង្គមដែលវិសាលភាពនៅមានកំរិត ទោះបីខ្វះព័ត៌មានថ្នាក់ជាតិដែលគួរឲ្យជឿជាក់លើវិស័យនេះក៏ដោយ ។ ដោយអវត្តមាននៃ ប្រព័ន្ធគាំពារសង្គម អត្រាគ្មានការងារធ្វើទាបនៅកម្ពុជា ដូចនៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេង ទៀត ។ ជាងនេះទៅទៀតអត្រាគ្មានការងារធ្វើបានធ្លាក់ចុះក្នុងរយៈពេលមួយទស្សវត្សរ៍នេះ ។ ប៉ុន្តែ អត្រាគ្មានការងារធ្វើរបស់យុវជនរក្សានៅខ្ពស់ជាងអត្រាគ្មានការងារធ្វើរបស់ប្រជារាស្ត្រពេញវ័យ ដែលធ្វើឲ្យភាពគ្មានការងារធ្វើជាបញ្ហាចំបងសម្រាប់យុវជន ។ បីភាគនៃយុវជន និងប្រជា រាស្ត្រពេញវ័យគ្មានការងារធ្វើ មិនបានបញ្ចប់កំរិតបឋមសិក្សា ។
- ភាគច្រើននៃប្រជារាស្ត្រមានការងារធ្វើទាំងអស់មាន ៨២,៥ ភាគរយជាអ្នកធ្វើការងារងាយរង គ្រោះ ។ នេះរួមបញ្ចូលទាំងចំនួនកុមារធ្វើការដែលបានកើនឡើងប្រមាណមួយភាគបួននៃកម្លាំង ពលកម្មជាអ្នកមិនចេះអាន និងសរសេរ ហើយកំរិតផលិតភាពការងារនៅកម្ពុជានៅទាបជាង បណ្តាប្រទេសផ្សេងទៀតក្នុងអាស៊ាន ហើយនេះជាបញ្ហាកង្វល់មួយនៃគុណភាពការងារ និងសមត្ថភាពធ្វើការងារសម្រាប់ប្រកួតប្រជែងក្នុងតំបន់ និងពិភពលោក ។

# ជំពូក ៩

## ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលលោក លើទីផ្សារការងារ ជាពិសេសវិស័យកាត់ដេរ

នៅចុងឆ្នាំ ២០០៨ វិបត្តសេដ្ឋកិច្ចសកលលោក (ផ្តើមមកពីវិបត្តិហិរញ្ញវត្ថុ) បានបង្កើតនូវការជ្រួល ច្របល់ដ៏ខ្លាំងខាងសេដ្ឋកិច្ច សង្គមកិច្ច និងទីផ្សារការងារដល់ប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍។ ប្រទេសកម្ពុជាក៏មិនអាចជៀសផុតនិងបានទទួលផលប៉ះពាល់ផងដែរ ជាសំខាន់តាមរយៈពាណិជ្ជកម្ម និងវិនិយោគ ។ ជាពិសេសគឺការថយចុះតម្រូវការរបស់បរទេស (ភាគច្រើន គឺសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប) សម្រាប់សំលៀកបំពាក់ធ្វើនៅកម្ពុជា ដែលជាវិបត្តដ៏ធ្ងន់ធ្ងរដល់ជាង ៣០០ រោងចក្រកាត់ដេរ ដែលក្នុងនោះ មួយចំនួនត្រូវបង្ខំបិទទ្វារ ឬព្យួរដំណើរការដោយបណ្តោះអាសន្ន ។ លទ្ធផលតាមការប៉ាន់ស្មានការបាត់បង់ការងារពីរោងចក្រកាត់ដេរ មានប្រមាណក្នុងចន្លោះ ១៥ និង ២០ ភាគរយនៃកម្លាំងពលកម្មខ្ពស់បំផុតនៅ ឆ្នាំ ២០០៨ ។ ការបាត់បង់ការងារនេះរួមមានទាំងការថយចុះក្នុងវិស័យដទៃទៀត (ជាពិសេសវិស័យ សំណង់ និងទេសចរណ៍ ព្រមទាំងកាត់ដេរ និងកសិកម្មដែលជាកំណើនសំខាន់បួននៃសេដ្ឋកិច្ច) ដែលផ្តល់ផលអាក្រក់ខាងហិរញ្ញវត្ថុដល់គ្រួសារក្រីក្រ ទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ ។ ដោយការឡើងថ្លៃ នៃម្ហូបអាហារនៅឆ្នាំ ២០០៧ និងឆ្នាំ ២០០៨ វិបត្តសេដ្ឋកិច្ចសកលលោក បានធ្វើឱ្យកាន់តែលំបាកឡើង និងធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា ដូចជាអ្នកធ្វើការបានបាត់បង់ ការងារ និងប្រាក់បញ្ញើឱ្យទៅតំបន់ជនបទថយចុះ ។

ជំពូកនេះពិភាក្សា ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលលោក ដែលបណ្តាលឲ្យសេដ្ឋកិច្ចធ្លាក់ចុះក្នុង ទីផ្សាការងារ ជាពិសេសវិស័យដែលទទួលឥទ្ធិពលខ្លាំង-កម្មន្តសាលកាត់ដេរ- និងការឆ្លើយតបរបស់រាជរដ្ឋា ភិបាល ។

### ៩.១ ផលប៉ះពាល់លើសេដ្ឋកិច្ច និងទីផ្សារការងារ

មុនវិបត្តិហិរញ្ញវត្ថុកើតឡើង ប្រទេសកម្ពុជាបានទទួលជោគជ័យក្នុងការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងឆ្នាំបន្តបន្ទាប់ជាមួយនឹងផលិតផលក្នុងស្រុកសរុប (GDP) កើនឡើងខ្ពស់ (ជាមធ្យម ១១,១ ភាគរយ នៅចន្លោះឆ្នាំ ២០០៤ និង ២០០៧) ។ ក្នុងនោះវិស័យសំខាន់ដែលបានចូលរួមមាន សំណង់ ទេសចរណ៍ និងឧស្សាហកម្មកាត់ដេរ ដែលធ្វើឲ្យមានកំណើនពីខ្ទង់អស់រយៈពេលដ៏យូរ ក៏ដូចជាធ្វើឲ្យប្រសើរឡើងនូវ ទិន្នផល និងផលិតភាពក្នុងវិស័យកសិកម្ម (ដែលភាគច្រើននៃកម្លាំងពលកម្មនៅមានការងារធ្វើ) ។ ស្ថាន ភាពនៃវិស័យកាត់ដេរ បានបង្ហាញនៅតារាង ៤.១ ។ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ២០០០ វិស័យនេះមានប្រមាណ ១៤-១៦ ភាគរយនៃ GDP ។

ជាលទ្ធផលនៃវិបត្តិ អត្រាកំណើននៃ GDP បានថយចុះពី ១០,២ ភាគរយនៅឆ្នាំ ២០០៧ មក ៦,៧ ភាគរយនៅឆ្នាំ ២០០៨ ។ វិធានការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល រួមមានបង្កើនការវិនិយោគក្នុងវិស័យ កសិកម្ម និងអភិវឌ្ឍន៍ទូលំទូលាយខាងវិស័យមិនមែនកសិកម្ម ព្រមជាមួយនឹងស្ថេរភាពខាងនយោបាយ ការ ចូលរួមដ៏សកម្មពីវិស័យឯកជន បង្កើនជំនួយអភិវឌ្ឍន៍ផ្លូវការ និងគាំទ្រការវិនិយោគផ្ទាល់ពីបរទេស បាន រក្សាសេដ្ឋកិច្ចកម្ពុជាឲ្យនៅល្អ ទោះបីមានការធ្លាក់ចុះក្នុងវិស័យខ្លះក៏ដោយ ។ កំណើន GDP នៅឆ្នាំ ២០០៩បានរក្សានៅវិជ្ជមាន ០,១ ភាគរយ ខណៈដែលកំណើននៅឆ្នាំ ២០១០ ត្រូវបានរំពឹងប្រមាណ ៥ ភាគរយ (លទ្ធផលម៉ាក្រូសេដ្ឋកិច្ចបច្ចុប្បន្ន www.mef.gov.kh ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។ ទោះបីយ៉ាងណា ក៏ដោយលទ្ធផលនឹងបង្ហាញពីទំហំ និងល្បឿនស្តារក្នុងបរិយាកាសកំណើនដែលអាចស្របទៅនឹងការងារ ដែលដើបឡើង ជាពិសេសការជះឥទ្ធិពលពីវិស័យដែលប៉ះពាល់យ៉ាងណា ។

### តារាង៤.១ អត្រាកំណើននៃផលិតផលក្នុងស្រុកសរុបពិត និងវិស័យកាត់ដេរ

| សូចនាករ | ឯកតា | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|
| កំណើន GDP ពិត | % | 10.3 | 13.3 | 10.8 | 10.2 | 6.7 |
| កំណើន GDP ពិត | ១ ពាន់លានរៀល | 19 434 | 22 009 | 24 380 | 26 870 | 28 668 |
| កំណើន GDP ពិត | ១ លានដុល្លារអាមេរិច | 4 840 | 5 378 | 5 942 | 6 600 | 7 061 |
| វិស័យកាត់ដេរ | ១ ពាន់លានរៀល | 2 947 | 3 217 | 3 873 | 4 261 | 4 355 |
| វិស័យកាត់ដេរ | ១ លានដុល្លារអាមេរិច | 734 | 786 | 944 | 1 047 | 1 073 |
| វិស័យកាត់ដេរ | % នៃ GDP | 15.2 | 14.6 | 15.9 | 15.9 | 15.2 |
| វិស័យកាត់ដេរ | កំណើន % | 24.9 | 9.2 | 20.4 | 10.0 | 2.2 |

**Source:** NIS/MOP

ចំពោះវិស័យទេសចរណ៍ដែលផ្តល់ច្រើនជាង ១៣ ភាគរយនៃ GDP នោះ នេះជាការថយចុះលើក ទីមួយហើយក្នុងជាងមួយទសវត្សរ៍នេះ។ ការប្រែប្រួលនេះអាចបង្ហាញថា ការថយចុះចំណូលពីទេសចរណ៍ ដោយសារការថយចុះចំនួនអ្នកទេសចរណ៍មកពីបស្ចឹមប្រទេស និងអាស៊ីព្រមទាំងសម្ព័ន្ធរបស់គេ ហើយ មានការចំណាយទាប និងការស្នាក់អាស្រ័យរយៈពេលខ្លីរបស់អ្នកទេសចរណ៍ក្នុងរយៈពេលនៃការធ្លាក់ចុះសេដ្ឋកិច្ច ។

ដូចបានបញ្ជាក់ពីខាងលើមកហើយថា ការផលិតសំលៀកបំពាក់ជាវិស័យនាំមុខគេនៅប្រទេស កម្ពុជា ។ ការនាំចេញនៃវិស័យនេះបានបង្ហាញថា ពីមួយឆ្នាំទៅមួយឆ្នាំបានកើនឡើងតាំងពីដើមទសវត្សរ៍ឆ្នាំ ២០០០ ហើយនៅឆ្នាំ ២០០៨ ការនាំចេញមានប្រមាណ ៦៧ ភាគរយនៃការនាំចេញសរុប ។ យោងតាមក្រសួងពាណិជ្ជកម្ម វិស័យនេះមានរោងចក្រចំនួន ៧០ ត្រូវបានបិទទ្វារ និងប្រមាណ ៧០.០០០ ការងារ បានបាត់បង់នៅចន្លោះខែតុលា ឆ្នាំ ២០០៨ និង ខែតុលា ឆ្នាំ ២០០៩ ដោយសារវិបត្តិសេដ្ឋកិច្ចសកលលោក បានវាយប្រហារដល់តម្រូវការពិភពលោកសម្រាប់សំលៀកបំពាក់ធ្វើនៅកម្ពុជា ។ ដោយសារភាគច្រើននៃកម្មករធ្វើការក្នុងវិស័យកាត់ដេរជាស្ត្រី វិបត្តិបានធ្វើឲ្យប៉ះពាល់ដល់កម្មការិនី ។ ការកើនឡើងនៃវិស័យកាត់ ដេរ តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ បានផ្តល់ឱកាសការងារផ្លូវការ ដែលមិនដែលមានពីមុនមក ដល់ស្ត្រីរាប់ពាន់នាក់ ដែលមិនសូវមានជំនាញពិសេសមកពីតំបន់ជនបទ ។ ទោះជាយ៉ាងណាក្តី តំណាងភាគច្រើនក្នុងវិស័យកាត់ដេរ ដែលជាស្ត្រី បានជួបវិបត្តិជាអវិជ្ជមានក្នុងរយៈពេលសេដ្ឋកិច្ចធ្លាក់ចុះ ដូចជា បន្ថយម៉ោងធ្វើការ បញ្ឈប់ការងារ ព្យួរការងារ និងកាត់បន្ថយការងារ ។

ទោះបីសង្ឃឹមទទួលបានមកវិញនៃវិស័យនេះនៅឆ្នាំ ២០១០ ក៏ដោយ កត្តាសំខាន់ៗ មួយចំនួនរួម មានការប្រកួតប្រជែង ផលិតភាពការងារ និងសន្តិភាពក្នុងការងារត្រូវយកចិត្តទុកដាក់តាំងពីមុនពេល សេដ្ឋកិច្ចធ្លាក់ចុះមកម្ល៉េះ ។ រោងចក្រល្អនៅកម្ពុជា ជាកម្មវិធីតាមដាន និងគ្រប់គ្រងរបស់អង្គការ ILO ដែលប្រតិបត្តិក្នុងវិស័យកាត់ដេរតាំងពីឆ្នាំ ២០០១ បានធ្វើការជាមួយទាំងនិយោជក និងសហជីព ដើម្បីរក ដំណោះស្រាយដល់បញ្ហាប្រឈមទាំងនេះ ក៏ដូចជាណែនាំកម្មករ និងម្ចាស់រោងចក្រអំពីការគ្រប់គ្រងប្រកប ដោយចិរភាព ចំពោះរោងចក្រដែលបិទរួចបន្តឡើងវិញ (ទោះបីមានចំនួនតិចជាង) នៅឆ្នាំ ២០១០ ។

ក្រុមហ៊ុនកាត់ដេរនៅកម្ពុជា ក៏បានបាត់បង់អ្នកប្រកួតប្រជែងតាមតំបន់នានាក្នុងពេលសេដ្ឋកិច្ច ធ្លាក់ចុះផងដែរ ។ ទិន្នន័យពីនាយកដ្ឋានពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក បង្ហាញថាការនាំចេញសំលៀក

បំពាក់ពីប្រទេសកម្ពុជានៅ ៦ ខែដំបូងនាឆ្នាំ ២០០៩ បានថយចុះជាខ្លាំង ២៩,៩ ភាគរយ បើប្រៀបធៀប ទៅនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ។ ការនាំចូលពីប្រទេសវៀតណាម ទោះជាយ៉ាងណាក៏ដោយ ក៏មិនមាន ការប្រែប្រួលខ្លាំងឡើយក្នុងរយៈពេលនេះ ខណៈដែលការនាំចូលពីប្រទេសចិន និងបង់ក្លាដេសបានកើនឡើង ៣,៧ ភាគរយ និង៦,៨ ភាគរយ តាមលំដាប់រៀង ។

តាមការប៉ាន់ស្មាន មូលហេតុសម្រាប់ដំណើរការខុសគ្នារបស់កម្ពុជា បានផ្តោតទៅលើកត្តារួមនៃ រចនាសម្ព័ន្ធ និងបរិបទដែលមានពីមុនមក ដោយរួមទាំងផលិតផលនៅមានកំណត់ និងភាពផ្សេង ៗ គ្នានៃ ទីផ្សារ ការថយចុះនៃការអនុគ្រោះពាណិជ្ជកម្ម បញ្ហាទំនាក់ទំនងវិជ្ជាជីវៈ និងកត្តាវិបត្តិជាយថាហេតុដទៃ ទៀត ដូចជាសមត្ថភាព ឬអសមត្ថភាព ក្នុងករណីនៅកម្ពុជា ដើម្បីផលិតបានបរិមាណច្រើនសម្រាប់ការ ចំណាយតិចក្នុងមួយឯកតា ។

### តារាង៤.២ ការនាំចូលសំលៀកបំពាក់របស់សហរដ្ឋអាមេរិក តាមប្រទេស (គិតជាលានដុល្លារអាមេរិក)

| ប្រទេស | Year to date June 2008 | Year to date June 2009 | % change |
|---|---|---|---|
| ពិភពលោក | 32 995.69 | 28 907.09 | -14.14% |
| ចិន | 9 069.47 | 9 421.43 | 3.73% |
| អាស៊ាន | 7 480.58 | 6 614.11 | -13.10% |
| វៀតណាម | 2 349.51 | 2 347.60 | 0.00% |
| ឥណ្ឌូនេស៊ី | 2 020.72 | 1 947.19 | -3.77% |
| **កម្ពុជា** | **1 155.46** | **889.82** | **-29.85%** |
| ឥណ្ឌា | 1 744.13 | 1 593.69 | -9.44% |
| បង់ក្លាដេស | 1 623.46 | 1 741.16 | 6.76% |
| ស្រីឡង្កា | 727.44 | 634.24 | -14.69% |
| ប៉ាគីស្ថាន | 688.39 | 597.87 | -15.14% |

ប្រភព UNDP Cambodia. 5 August 2009. *Crisis impact watch*, Volume 1, Issue.

ដូចបានកត់សម្គាល់ ការបិទទ្វាររោងចក្រតាំងពីចុងឆ្នាំ ២០០៨ បានធ្វើឲ្យបាត់បង់ការងារដ៏ច្រើន ក្នុងវិស័យកាត់ដេរ ។ ជាងនេះទៀតរោងចក្រមួយចំនួនដែលនៅសល់ ត្រូវអនុវត្តក្នុងកម្រិតតឹងតែងដែលជះឥទ្ធិពលជាអវិជ្ជមានដល់កម្លាំងពលកម្មរបស់ពួកគេ ។ ទាំងនេះរួមមានការព្យួរដោយបណ្តោះអាសន្ន (ដែលត្រូវបានកំណត់ដោយច្បាប់រហូតដល់ពីរខែ) បន្ថយសប្តាហ៍ការងារ និងបន្ថយម៉ោងលើស ។ ការងារលើស ម៉ោងតែងផ្តល់នូវការរិះគន់សម្រាប់កម្មករកាត់ដេរមួយចំនួន ដោយសារវាបាននាំឲ្យពួកគាត់បានបង្កើន ប្រាក់បៀវត្សរ៍

(ប្រាក់ឈ្នួលជាអប្បបរមាក្នុងវិស័យកាត់ដេរ ៥០ ដុល្លារអាមេរិកក្នុងមួយខែ) ដែលអនុញ្ញាតឲ្យពួកគាត់បានផ្ញើលុយទៅផ្ទះ និងបានចាយវាយគ្រប់គ្រាន់ដោយខ្លួនឯង ដូចជាម្ហូបអាហារ ធ្វើដំណើរ និងផ្ទះស្នាក់នៅ ។

មិនមានទិន្នន័យថ្នាក់ជាតិ អំពីផលប៉ះពាល់នៃវិបត្តិទៅលើគ្រួសារឡើយ ។ ទោះជាយ៉ាងនេះក្តីការ ប៉ាន់ស្មានបានបង្ហាញថា ផលប៉ះពាល់ទៅលើកម្មករក្នុងវិស័យដែលមានផលប៉ះពាល់ និងទៅលើគ្រួសាររបស់ពួកគេ (ដូចជាប្រាក់បញ្ញើទៅផ្ទះ) ទំនងជាមានកំរិតគួរឲ្យកត់សម្គាល់ រួមទាំងកុមាររបស់គ្រួសារក្រី ក្រ និងងាយរងគ្រោះ (ប្រអប់ ៦) ។ ហានិភ័យនៃការកើនឡើងរបស់ពលកម្មកុមារ និងគ្រួសារក្រីក្របាននាំឲ្យការផ្តល់ចំណីអាហារថយចុះ និងព្យាបាលជំងឺតិចជាងមុន ។

វិបត្តិក្នុងវិស័យកាត់ដេរ និងវិស័យដទៃទៀតជាទូទៅក៏បានបង្ហាញពីសេចក្តីត្រូវការដ៏សំខាន់ សម្រាប់បង្កើនការគាំពារសង្គម និងសំណាញ់សុវត្ថិភាពសង្គម ដើម្បីជួយដល់កម្មករ ជាពិសេសភាពក្រីក្រ និងភាពងាយរងគ្រោះ ដែលត្រូវគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពក្នុងរយៈពេលដែលសេដ្ឋកិច្ចជួបការ លំបាក ។

## ប្រអប់៦
## ការសិក្សារបស់អង្គការ ILO អំពីវិស័យកាត់ដេរបានឲ្យដឹងពីការលំបាកថ្មី និងយន្តការដោះស្រាយ

ការស្រាវជ្រាវបានដំណើរការដោយអង្គការ ILO នៅចុងឆ្នាំ ២០០៩ បានឲ្យដឹងថា ចំណូលជាមធ្យមបានថយចុះ ១៧ ដុល្លារអាមេរិកក្នុងមួយ ខែក្នុងចំណោមកម្មករធ្វើការក្នុងរយៈពេលសេដ្ឋកិច្ចធ្លាក់ចុះ ។ មូលហេតុចម្បង តាមការសិក្សាបានរកឃើញថា ដោយសារការកាត់បន្ថយការ ងារលើសម៉ោង ។

ការស្រាវជ្រាវដូចគ្នានេះ បានផ្តល់នូវសូចនាករនៃវិសាលភាពចំណូលក្នុងវិស័យកាត់ដេរដែលថយចុះ ដែលអាចមានផលប៉ះពាល់ច្រើនដល់កម្ម ករ។ ដូចបានដឹងហើយថា ភាគច្រើននៃកម្មកររោងចក្រនៅក្មេង ហើយជាស្ត្រីដែលផ្លាស់មកពីតំបន់ជនបទនៅកម្ពុជា។ ច្រើនជាងនេះទៀត ការធ្វើសេចក្តីសម្រេចចិត្តចូលក្នុងការងាររោងចក្រ គឺដោយសារតម្រូវការចាំបាច់ខាងសេដ្ឋកិច្ច ការងារនៅផ្ទះមានតិចតួច ហើយសេចក្តីត្រូវ ការដើម្បីផ្គត់ផ្គង់ដល់គ្រួសារដ៏ធំរួមមាន បងប្អូន ឪពុកម្តាយ ជីតាជីដូន និងកូន ដែលក្នុងនោះករណីមួយចំនួនដូចជាការផ្ញើប្រាក់ទៅផ្ទះ គឺជា អាទិភាពទីមួយរបស់កម្មករ។ ដូច្នេះកម្រិតនៃចំណូលរបស់កម្មករ ដែលទទួលបានក្នុងរោងចក្រអាចមានផលប៉ះពាល់ដោយផ្ទាល់លើសុខុមាល ភាព លំបាកក្នុងការចាយវាយ និងការចែករំលែកដល់គ្រួសារដ៏ធំនៅជនបទដែលពឹងផ្អែកលើប្រាក់បញ្ញើ។ ចំណុចដែលគួរឲ្យចាប់អារម្មណ៍គឺ ការស្រាវជ្រាវរបស់អង្គការ ILO បង្ហាញថាជិតមួយគ្រួសារក្នុងចំណោមប្រាំពីរគ្រួសាររបស់កម្មករ ការសម្រេចចិត្តត្រូវបានធ្វើឡើងក្នុងរយៈពេលសេដ្ឋកិច្ចធ្លាក់ចុះ ដើម្បីបញ្ជូនសមាជិកគ្រួសារដែលភាគច្រើនជាបងប្អូនស្ត្រីទៅក្នុងកម្លាំងពលកម្មដើម្បីរកការងារធ្វើ។ ទាំងនេះអាចត្រូវបានគិតថាជាយន្តការដោះស្រាយមួយដើម្បីជំនះលើការធ្លាក់ចុះនៃប្រាក់ចំណូល ដែលទទួលបានតាមសមត្ថភាពរបស់កម្មករក្នុងរយៈពេលនេះ។

ការសិក្សារបស់អង្គការ ILO ក៏បានរកឃើញថា អ្នករកការងារធ្វើឡើងវិញ ភាគច្រើនចង់ត្រឡប់ទៅរោងចក្រកាត់ដេរវិញ។ ជាធម្មតាដោយសារកម្មករតែងមានបណ្តាញទំនាក់ទំនងល្អក្នុងរោងចក្រ។ ប៉ុន្តែកម្មករមួយចំនួនក៏មិនបានដឹងពីឱកាសការងារទូលំទូលាយដល់ពួកគេផងដែរ។ កម្មករមួយចំនួនបានស្វែងរកការងារខាងក្រៅរោងចក្រ ភាគច្រើនរកការងារជាជាងកាត់ដេរ អ្នកតែងគ្រឿងសំអាង និងអ៊ុតសក់ ក៏ដូចជាការ ងារមិនរៀបរយដែលមិនស្ថិតស្ថេរ ដូចជាលក់ម្ហូបអាហារនៅតាមចិញ្ចើមផ្លូវ។ ដើម្បីរកបានការងារថ្មី កម្មករត្រូវទៅរកការណែនាំពីមិត្តភក្តិ និងប្រភពដទៃទៀត ដូចជាសហជីព សាច់ញាតិ អង្គការមិនមែនរដ្ឋាភិបាល និងសារព័ត៌មាន។

### ការលំបាកថ្មីលើកម្មករ




ប្រភព: Chandararot, K. and Dannet, L. 2010. *Tracking study of Cambodian garment sector workers affected by the global economic crisis:*

*Benchmarking survey report*. ILO. មាននៅក្នុង: www.betterfactories.org. គំហើញនៃការសិក្សាពីការអនុវត្តន៍មូលដ្ឋាននៃការសិក្សាតាមដានរយៈពេលប្រាំមួយខែ ពិនិត្យពីផលវិបាកនៃវិបត្តិរបស់កម្មករកាត់ដេរមានការងារធ្វើ និងគ្មានការងារធ្វើ ។ សូមមើល ILO. 2010. *ការស្រាវជ្រាវ: Garment workers tracking study* មាននៅក្នុង: *www.betterfactories.org/content/documents/1/ Research%20Snapshot%20on%20 Garment%20Workers%20Survey%20(Eng).pdf*

នៅពេលកម្មករប្រឈមនឹងការបាត់បង់ការងារ ដូចជាក្នុងវិស័យកាត់ដេរថ្មីៗនេះ ការស្វែងរក ការងារ ជាពិសេសសម្រាប់អ្នកក្រីក្រ និងអ្នកដែលមានការអប់រំ និងជំនាញតិចតួច អាចជាបញ្ហាប្រឈម ដ៏ចម្បងមួយ ។ ព័ត៌មានទីផ្សារការងារ និងសេវាកម្មការងារសាធារណៈ ភាគច្រើនមិនចាប់អារម្មណ៍ដល់ ក្រុមទាំងនេះឡើយ ។ នេះជាឧបសគ្គដ៏ចម្បងមួយ ដើម្បីទទួលបាននូវភាពសមរម្យ និងផលិតភាពការងារ។ ទាំងនេះហើយដែលនាំឲ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចាប់ផ្តើមបង្កើតនៅឆ្នាំ ២០០៩ នូវ បណ្តាញនៃមជ្ឈមណ្ឌល ការងារតំបន់ មានបំណងផ្តល់នូវសេវាកម្មការងារ អនុវត្តន៍សម្រាប់អ្នកស្វែងរក ការងារធ្វើ រួមទាំងអ្នកត្រូវបញ្ឈប់ពីការងារ ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ចផងដែរ ។ ជាមួយនឹងការ ឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការ ILO ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន បើកមជ្ឈមណ្ឌលសាកល្បងថ្មីពីរនៅភ្នំពេញ និងនៅខេត្តបាត់ដំបង និងពីរផ្សេងទៀតបើកនៅឆ្នាំ ២០១០ ។ មជ្ឈមណ្ឌលទាំងនេះ នឹងផ្តល់សេវាកម្មសំដៅចំពោះកាលានុវត្តភាពការងារដែលមានសក្តានុពល និងការបណ្តុះបណ្តាលវិជ្ជាជីវសម្រាប់អ្នករកការងារធ្វើនៅតាមវិស័យទាំងអស់ ។

## ៤.២ ការឆ្លើយតបទៅនឹងវិបត្តិ

ដើម្បីបន្ថយផលប៉ះពាល់នៃវិបត្តិ សេដ្ឋកិច្ចសកលលោក រាជរដ្ឋាភិបាលចាប់ផ្តើមវិធានការជាច្រើន ដើម្បីជួយគាំទ្រដល់សេដ្ឋកិច្ច ក៏ដូចជាក្រុមហ៊ុន និងកម្មករដែលមានផលប៉ះពាល់ ។ គោលនយោបាយសារ ពើពន្ធ ត្រូវបានពង្រីក ជាសំខាន់ចំពោះការកាត់ពន្ធគោលដៅ និងការលើកទឹកចិត្តសម្រាប់វិស័យសំខាន់ៗ (រួមមានកម្មន្តសាល កាត់ដេរ និងទេសចរណ៍) ត្រូវបានអនុវត្តន៍ដើម្បីកាត់បន្ថយផលប៉ះពាល់ខាងហិរញ្ញ វត្ថុបន្ទាន់មួយចំនួនលើក្រុមហ៊ុន ក៏ដូចជាដើម្បីបន្ថយការបញ្ឈប់បុគ្គលិកដែលជាវិធានការឆ្លើយតប ។ ចំ ពោះការងារនេះ រាជរដ្ឋាភិបាលបានបញ្ចេញនូវមូលនិធិ ពិសេសសម្រាប់ការបណ្តុះបណ្តាលឡើងវិញដល់កម្មករដែលត្រូវកាត់បន្ថយ ផ្តល់ការបណ្តុះបណ្តាលមុខវិជ្ជាជីវៈរយៈពេលខ្លីមួយចំនួនដើម្បីធ្វើឲ្យជំនាញ កាន់តែប្រសើរឡើងបានជាង ៤០.០០០ កម្មករសម្រាប់អ្នករកការងារធ្វើឡើងវិញទាំងក្នុង និងក្រៅ វិស័យ ។ គម្រោងបានបញ្ចប់នៅឆ្នាំ ២០០៩ ប៉ុន្តែដំណាក់កាលទីពីរ នៅកំពុងពិចារណា ។

តាំងពីឆ្នាំ ២០០៩ រាជរដ្ឋាភិបាលបានពង្រឹងការគាំទ្រដល់ការគាំពារសង្គម (រួមទាំងសំណាញ់សុវត្ថិភាព) ដែលបានជួយជ្រោមជ្រែងដោយបណ្តាក្រសួង និងស្ថាប័នដើម្បីជួយក្រុមងាយរងគ្រោះ និងគ្រប់ គ្រងវិបត្តិសេដ្ឋកិច្ចនាពេលអនាគត ។ ចំណុចស្នូលនៃការខិតខំប្រឹងប្រែងទាំងនេះ គឺការអភិវឌ្ឍន៍នៃយុទ្ធសាស្ត្រជាតិគាំពារសង្គម (NSPS) រៀបចំដើម្បីសហាការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍។ សមាសធាតុស្នូល នៃយុទ្ធសាស្ត្រ រួមមានការពង្រីកលក្ខខណ្ឌផ្ទេរប្រាក់ កម្មវិធីការងារសាធារណៈខាងការងារប្រើកម្លាំង ពលកម្មច្រើន និងមូលនិធិសមធម៌ខាងសុខភាព ។ បច្ចុប្បន្នរាជរដ្ឋាភិបាលកំពុងរៀបចំកិច្ចសម្រុះសម្រួលជាចាំបាច់ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រ ដែលជាឧបករណ៍អចិន្ត្រៃយ៍មួយសម្រាប់ដោះស្រាយទាំងភាពក្រីក្រ និងឥទ្ធិពលដែលធ្វើឲ្យខូចប្រយោជន៍នៃវិបត្តិខាងក្រៅ ដូចជាវិបត្តិសេដ្ឋកិច្ច និងថ្លៃទំនិញ និងមហន្តរាយ ធម្មជាតិ ដូចជាទឹកជំនន់ និងការរាំងស្ងួត ។

បន្ថែមពីលើវិធានការបន្ទាន់រយៈពេលខ្លី រាជរដ្ឋាភិបាលក៏បានខិតខំកាន់តែខ្លាំងឡើង ដើម្បីបង្កើតដំណោះស្រាយប្រកបដោយចិរភាពដល់បញ្ហាប្រឈមតាមវិស័យ ជាពិសេសវិស័យកាត់ដេរ ។ ទាំងនេះរួម មានទាំងការបញ្ចុះបញ្ចូលសម្រាប់កិច្ចព្រមព្រៀងការអនុគ្រោះពាណិជ្ជកម្មថ្មីសម្រាប់ការនាំចេញសំលៀក បំពាក់ ដើម្បីជំនួសទំនិញផុតកំណត់បច្ចុប្បន្ន ការរុករកទីផ្សារនាំចេញថ្មី (ជាពិសេសក្នុងអាស៊ី) និងធ្វើការ ពិភាក្សាដំបូងអំពីការអភិវឌ្ឍន៍នៃតម្បាញ និងកម្មន្តសាលគ្រឿងបរិក្ខារ (ដើម្បីជួយឲ្យប្រទេសកម្ពុជាបាន ប្រកួតប្រជែងជាមួយនឹងប្រទេសដែលមានផលិតផលកាត់ដេររួមគ្នាច្រើនជាមូលដ្ឋាន) ។

យុទ្ធសាស្ត្រដែលចេញពីការពង្រីកសារពើពន្ធ បច្ចុប្បន្នជាការពិចារណាដ៏សំខាន់មួយសម្រាប់អ្នកធ្វើ គោលនយោបាយសេដ្ឋកិច្ចឆ្នាំ ២០១០ ។ ថវិកាឆ្នាំ ២០១០ បានទុកមួយផ្នែកសម្រាប់ការលើកទឹកចិត្តដើម្បីធានាដល់ស្ថេរភាពនៃសារពើពន្ធ តាមរយៈពន្ធទ្រព្យសម្បត្តិ និងតាមការទប់ទល់កំណើននៃចំណាយជា ពិសេសប្រាក់បៀវត្សរ៍ខាងវិស័យសាធារណៈ ។ ទាំងនេះបានធ្វើឲ្យឱនភាពធ្លាក់ចុះ ខាងការគ្រប់គ្រងបន្ថែម ទៀត ចំពោះតម្រូវការហិរញ្ញប្បទានអប្បបរមាពីថវិកាបម្រុង ។ ទោះជាយ៉ាងណាក៏ដោយ តុល្យភាពនេះ ជាមួយនឹងសេចក្តីត្រូវការ ចំពោះការងើបឡើងវិញនៃសេដ្ឋកិច្ចមិនទៀងទាត់ ជាបញ្ហាប្រឈមដ៏សំខាន់ក្នុង ឆ្នាំខាងមុខ ។

ចំពោះគោលនយោបាយរូបិយវត្ថុ ការឆ្លើយតបជាបន្ទាន់របស់ធនាគារជាតិនៃកម្ពុជា រួមទាំងការ ធ្វើឲ្យងាយស្រួលដល់គោលនយោបាយរូបិយវត្ថុ និងការអនុវត្តន៍វិធានការទូលំទូលាយដើម្បីជួយ និងពង្រឹង ប្រព័ន្ធហិរញ្ញវត្ថុ និងធនាគារ ។

រាជរដ្ឋាភិបាលបានជឿជាក់ថា តាមការអនុវត្តន៍ដ៏មានប្រសិទ្ធភាពនៃរបៀប វារៈគោលនយោបាយសេដ្ឋកិច្ច សង្គមកិច្ចសម្រាប់នីតិកាលទីបួន (ក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាល ទី II) ជាពិសេស ការអនុវត្តន៍គោលនយោបាយធ្វើឲ្យមានមូលដ្ឋានសេដ្ឋកិច្ចច្រើន និងទូលំទូលាយ និងដើម្បី ធ្វើឲ្យប្រសើរឡើង នូវការប្រកួតប្រជែងក្នុងទីផ្សារតំបន់ និងអន្តរជាតិ កំណើនសេដ្ឋកិច្ចនឹងកើនឡើងវិញ ឆ្ពោះទៅនិន្នាការកំណើនជាប្រវត្តិសាស្រ្តក្នុងរយៈពេលមធ្យម ។

ទោះបីរាជរដ្ឋាភិបាលមានវិធានការជាច្រើន ដើម្បីដោះស្រាយផលប៉ះពាល់ពីវិបត្តិក៏ដោយ ក៏កម្ពុជានៅតែមានផលប៉ះពាល់ដោយសារឥទ្ធិពលពីខាងក្រៅ ។ សម្រាប់មូលហេតុនេះ ការងើបឡើងព្រមៗគ្នាក្នុង សេដ្ឋកិច្ចជាក់ស្តែង (និងពិសេសកំណើនអ្នកមានការងារធ្វើ) និងនៅតែមិនប្រាកដ និងមិនអាចទស្សទាយ បាន។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីធានាបានល្អឲ្យកម្ពុជាមានសេដ្ឋកិច្ចងើបឡើងវិញ និងពង្រឹងមូលដ្ឋាន សេដ្ឋកិច្ចដើម្បីការពារបានល្អ ទៅនឹងវិបត្តិដូចគ្នានេះនៅពេលអនាគត រាជរដ្ឋាភិបាលបានដាក់ចេញនូវការ ខិតខំជាអាទិភាពមួយចំនួនដើម្បីដោះស្រាយនៅឆ្នាំខាងមុខ៖

- ធ្វើឲ្យមានទីផ្សារច្រើនសម្រាប់វិស័យកាត់ដេរ និងទំនិញកម្មន្តសាលដទៃទៀត សម្រាប់នាំចេញ ទៅអាស៊ីបូព៌ា មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- កែលម្អហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងអភិវឌ្ឍន៍តំបន់ទេសចរណ៍បន្ថែមទៀត និងកញ្ចប់ទេស ចរណ៍ប្រកបដោយភាពទាក់ទាញ
- ផ្តល់អាទិភាពការប្រើប្រាស់ធនធាន និងជំនាញរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីពង្រីក និងធ្វើឲ្យច្រើនឡើងនៃវិស័យកសិកម្ម សំដៅទាក់ទាញវិនិយោគប្រកបដោយគុណភាពបន្ថែមទៀត ក្នុងធុរៈកិច្ចកសិកម្ម និងកែលម្អទំនាក់ទំនងពាណិជ្ជកម្មកសិកម្ម ការកែទម្រង់ដីធ្លី ធ្វើឲ្យមានច្រើនឡើងក្នុងវិស័យកសិកម្ម និងដំណើរការកសិកម្ម
- ធ្វើវិនិយោគបន្ថែមទៀត លើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសលើវិស័យថាមពល ដើម្បី កាត់បន្ថយថ្លៃដើមថាមពលដល់ផ្នែកឯកជន និងដល់សហគមន៍
- បន្តលើកកម្ពស់ និងគាំទ្រការបង្កើតទ្រព្យធន និងកែលម្អកម្រិតជីវភាពរបស់ប្រជាជនតាមគោល ការណ៍ និងនីតិវិធីដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ។

## ៩.៣ សេចក្តីសន្និដ្ឋាន

ចាប់ពីចុងឆ្នាំ ២០០៧ ប្រទេសកម្ពុជា ក៏ដូចជាប្រទេសដទៃទៀតមួយចំនួន បានទទួលនូវឥទ្ធិពល ដោយវិបត្តិសេដ្ឋកិច្ចសកលលោក ។ វិបត្តិជះឥទ្ធិពលជាសំខាន់ទៅលើវិស័យកាត់ដេរ ទេសចរណ៍ និង សំណង់ដែលជាលទ្ធផល គឺបាត់បង់ការងារក្នុងវិស័យទាំងនេះ និងការថយចុះនៃចំនួនអ្នកទេសចរណ៍ ។ ក្នុងវិស័យកាត់ដេរតែមួយ តាមការប៉ាន់ស្មាន ប្រមាណ ៧០.០០០ ការងារត្រូវបានបាត់បង់នៅចុងឆ្នាំ ២០០៨ ។ ការណ៍នេះបានបង្ហាញថា អាចមានភាពងាយរងគ្រោះដល់កំណើននៃការនាំចេញ ។ វាក៏ទាក់ទង ដល់ការប្រកួតប្រជែងនៃការនាំចេញរបស់កម្ពុជាផងដែរ ក្នុងការប្រៀបធៀបទៅនឹងប្រទេសផ្សេងទៀតក្នុង ទ្វីបអាស៊ី ។

រាជរដ្ឋាភិបាលបានកំណត់នូវគោលនយោបាយ និងយុទ្ធសាស្ត្រទាន់ពេលវេលាមួយចំនួនដើម្បីដោះ ស្រាយជាមួយនឹងវិបត្តិ ។ គោលនយោបាយ និងយុទ្ធសាស្ត្រទាំងនេះអាចជួយក្នុងការធ្វើឲ្យដូចដើមវិញនូវ កំណើនសេដ្ឋកិច្ច ផ្តល់ភាពប្រសើរឡើងដល់បរិយាកាសសេដ្ឋកិច្ចក្រៅប្រទេស ដែលធ្វើឲ្យផលប៉ះពាល់លើ ទីផ្សារការងារដែលនៅបន្តមិនសូវទទួលរងឥទ្ធិពល ។ តម្រូវការបង្កើនការគាំពារសង្គម ក៏បានយកចិត្តទុក ដាក់ផងដែរ ដើម្បីបន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃវិបត្តិលើកម្លាំងពលកម្ម ។

# ជំពូក ៥

## បញ្ហាទីផ្សារការងារក្នុងទសវត្សរ៍ការងារសមរម្យនៅអាស៊ី ឆ្នាំ ២០០៦-២០១៥

ជំពូកនេះ បង្ហាញអំពីការពិភាក្សានៃបញ្ហាទីផ្សារការងារក្នុងទសវត្សរ៍ការងារសមរម្យនៅអាស៊ី ឆ្នាំ ២០០៦-២០១៥ ដើម្បីកំណត់នូវបញ្ហាប្រឈមរយៈពេលវែង ដែលបានជួបប្រទះនៅកម្ពុជា ។ បន្ទាប់ពី វិវាទក្នុងសង្គម កម្ពុជាពិតជាបានធ្វើដំណើរទៅមុខប្រកបដោយជោគជ័យជាមួយនឹងកំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍ក្នុងទសវត្សរ៍កន្លងមក

ដោយការខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាប្រឈមខាងសេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជន តាមរយៈគោលនយោបាយ និងកម្មវិធីប្រកបដោយប្រសិទ្ធភាព ។

## ៥.១ យុទ្ធសាស្ត្រចតុកោណ

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីរ ដែលបង្ហាញក្នុងរូប ៥.១ បានកំណត់មូលដ្ឋានគ្រឹះបួន នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចគឺ ៖ ១) លើកស្ទួយវិស័យកសិកម្ម ២) ការបន្តស្តារ និងកសាង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៣) ការអភិវឌ្ឍន៍ផ្នែកឯកជន និងការងារ និង ៤) ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ អភិបាលកិច្ចល្អជាចំណុចកណ្តាលនៃយុទ្ធសាស្ត្រចតុកោណ និងជាតម្រូវការ សម្រាប់សម្រេចបាននូវគោលដៅដទៃទៀត ។

រូប ៥.១ យុទ្ធសាស្ត្រចតុកោណ



ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ បានប្រើប្រាស់គ្រប់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលដើម្បីឲ្យអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងធ្វើតាមគោលដៅរបស់យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងគោលដៅសហសវត្សរ៍កម្ពុជា (MDG) ។ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលផ្តល់នូវអាទិភាព ខ្ពស់ដល់ការកាត់បន្ថយភាពក្រីក្រ ។

ការបង្កើតឱកាសសម្រាប់ការងារប្រកបដោយគុណភាពល្អ ឬការងារសមរម្យជាគោលដៅសំខាន់ ដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ ។ ទូទាំងទ្វីបអាស៊ី រដ្ឋាភិបាលទាំងឡាយបានព្រមទទួលយក គោលដៅរបស់ MDG ទីមួយសម្រាប់ការងារពេញលេញ និងការងារប្រកបដោយផលិតភាព និងការងារសមរម្យសម្រាប់ទាំងអស់គ្នា រួមទាំងយុវជនទាំងពីរភេទ ។ ការសម្រេចបាននូវចំណុចដៅនេះ គឺជាការងារដ៏ស្មុគ្រស្មាញដែលសំខាន់ផ្តោតលើឱកាសបង្កើតផលិតភាពការងារ ព្រោះវាជាមធ្យោបាយដែលអាច សម្រេចទៅបានច្រើនជាងគេក្នុងការកាត់បន្ថយភាពក្រីក្រ ។ របៀបវារៈនៃការងារសមរម្យផ្តល់ផ្លូវមួយ ឆ្ពោះទៅការយល់ឃើញនេះ ដែលផ្តោតមិនត្រឹមតែលើការងារប្រកបដោយគុណភាព និងការគាំពារសង្គម ប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តោតទៅលើដំណើរការទំនាក់ទំនងផងដែរ ដើម្បីសម្រេចបាននូវទំនាក់ទំនងរវាងគោល នយោបាយសេដ្ឋកិច្ច និងសង្គមកិច្ច ។

## ៥.២ គោលនយោបាយ និងកម្មវិធីសម្រាប់ពង្រីកឱកាសការងារសមរម្យ

កម្មវិធីការងារសមរម្យសម្រាប់ប្រទេស (DWCP) ផ្តល់យុទ្ធសាស្ត្រសម្រាប់បង្កើតការងារសមរម្យក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ។ កម្មវិធីការងារសមរម្យសម្រាប់ប្រទេសត្រូវបានរៀបចំសម្រាប់រយៈពេលបីឆ្នាំ (២០០៨-២០១០) ដែលស្របទៅនឹង NSDP និងក្របខ័ណ្ឌជំនួយការអភិវឌ្ឍន៍សហប្រជាជាតិ ។ DWCP ឆ្លុះបញ្ចាំងនូវអាទិភាពរបស់ស្ថាប័នត្រីភាគីក្នុងប្រទេស ។ ទំនាក់ទំនងខាងសង្គមកិច្ចជាឧបករណ៍គ្រឹះដើម្បីសម្រេច បាននៅការរៀបចំ DWCP សម្រាប់កម្ពុជា និងជាគន្លឹះក្នុងគ្រប់ផ្នែកនៃ DWCP ។

សម្រាប់ DWCP ឆ្នាំ ២០០៨-២០១០ នៅកម្ពុជាបានកំណត់ផ្នែកអាទិភាពបី៖

- ឱកាសផលិតភាពការងារ-បង្កើនឱកាសផលិតភាពការងារសម្រាប់ស្ត្រី និងបុរស យុវជន និង ជនពិការ ជាពិសេសក្នុងតំបន់ជនបទ។
- អភិបាលកិច្ចល្អ-ធ្វើឲ្យប្រសើរឡើងសម្រាប់វិធាននៃច្បាប់ ច្បាប់ការងារប្រកបដោយប្រសិទ្ធភាព និងស្ថាប័នទីផ្សារការងារ និងការអនុវត្តន៍តាមស្តង់ដារការងារអន្តរជាតិ ។ រាជរដ្ឋាភិបាលនិងដៃគូខាងសង្គមកិច្ចយល់ព្រម និងអនុវត្តគោលនយោបាយដើម្បីកែលម្អ និងការពារសិទ្ធិកុមារ ស្ត្រី កម្មករធ្វើការ ពីកន្លែងមួយទៅកន្លែងមួយ និងប្រជាជនកើតក្នុងស្រុក ។
- ការគាំពារសិទ្ធិ និងសង្គម-បង្កើនវិសាលភាពគាំពារសង្គមដល់កម្មករ និងកម្មការិនីទាំងក្នុង សេដ្ឋកិច្ចរៀបរយ និងមិនរៀបរយ។

## ៥.៣ បញ្ហាប្រឈម

ថ្វីត្បិតកម្រិតនៃភាពក្រីក្រជាទូទៅបានថយចុះ តែវិសមភាពចំណូលបានកើនឡើង ។ វិបត្តិ សេដ្ឋកិច្ចសកលលោក បានបង្ហាញច្បាស់នូវបញ្ហាប្រឈមមួយចំនួននៃការងារ និងសង្គមកិច្ចដូចបានបញ្ជាក់ ក្នុងរបាយការណ៍នេះ ។ ដូចបានពណ៌នាក្នុងជំពូក ៤ ដែលបង្ហាញថា ការកើនឡើងនៃជ័យជំនះដ៏លំបាកនៅកម្ពុជាត្រូវបានគំរាមកំហែងដោយវិបត្តិសេដ្ឋកិច្ច ជាពិសេសក្នុងទីផ្សារការងារ ។ ផ្នែកនេះពណ៌នាអំពីវិបត្តិ និងកំណត់អំពីបញ្ហាដែលកើតមានឡើង និរន្តរភាព និងកំណើនការងារនៅប្រទេសកម្ពុជា ។

### ៥.៣.១ បញ្ហាប្រឈមនៃការសម្រេចបាននូវផលិតភាពពេញលេញ និងការងារសមរម្យសម្រាប់ទាំងអស់គ្នា

ការកើនឡើងនៃផលិតភាពការងារ និងសមត្ថភាពការងាររបស់ប្រជាជនកម្ពុជា គឺជាតម្រូវការដ៏សំខាន់ ជាពិសេសនៅតំបន់ជនបទដែលភាពក្រីក្រមានច្រើនជាងគេ និងមានសកម្មភាពសេដ្ឋកិច្ចតិចតួច ។ វាងាយស្រួលជះឥទ្ធិពលទៅនឹងផែនការយុទ្ធសាស្ត្រជាតិរបស់ប្រទេស ដែលសង្កត់ធ្ងន់ទៅលើភាពសំខាន់ នៃការបង្កើតការងាររយៈពេលវែងប្រកបដោយចិរភាពដល់សេដ្ឋកិច្ចរបស់ប្រទេស និងការអភិវឌ្ឍន៍សង្គម។ និន្នាការប្រជាសាស្ត្រ និងសេដ្ឋកិច្ចធ្វើឲ្យមានបញ្ហាប្រឈមនេះ ជាពិសេសទាក់ទងទៅនឹងបរិបទប្រជាជន កម្ពុជា ។ កត្តាដែលគួរឲ្យកត់សម្គាល់ និងកើតឡើងមិនស៊ីគ្នារវាងជំនាញដែលផ្តល់ឲ្យកម្លាំងពលកម្ម និង តម្រូវការជំនាញក្នុងទីផ្សារការងារ បានបញ្ជាក់យ៉ាងច្បាស់ថា ការប្រកួតប្រជែងការងារនៅកម្ពុជាគួរតែ យកចិត្តទុកដាក់នៅឆ្នាំខាងមុខ ។

*និន្នាការចំណោលប្រជាជន បង្ហាញអំពីកំណើនប្រជាជនដល់អាយុធ្វើការ*

ផ្នែកមួយនៃបញ្ហាប្រឈមខាងសេដ្ឋកិច្ច និងសង្គមកិច្ចចម្បងនៅកម្ពុជា គឺការបង្កើតឱកាសការងារ សម្រាប់កម្លាំងពលកម្មថ្មី ខណៈដូចគ្នាក៏ត្រូវបង្កើនចំណូល និងលើកកំពស់ផលិតភាព ដែលជាពិសេស សម្រាប់កម្មករធ្វើការក្នុងតំបន់ជនបទ និងសេដ្ឋកិច្ចមិនរៀបរយ ។ ទិន្នន័យបានបង្ហាញថា នៅចន្លោះឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៨ ទីផ្សារការងារត្រូវបានពង្រីកតាមអត្រាប្រចាំឆ្នាំជាមធ្យមប្រមាណ ១៩២.០០០ នាក់ ចូលថ្មី ។ ចំណោលប្រជាជនបង្ហាញក្នុងផ្នែក ២.៤ ប៉ាន់ស្មានអត្រាកំណើនប្រចាំឆ្នាំជាមធ្យមនៃប្រជាជន សរុបនៅចន្លោះឆ្នាំ ២០០៩ និង ២០១៥ មានប្រមាណ ១,៣ ភាគរយ ។ ប្រជាជនធ្វើការងារ (អាយុ ២៥-៥៨ឆ្នាំ) នឹងកើនឡើង អត្រាប្រចាំឆ្នាំជាមធ្យម ៣,៤ ភាគរយ (ឧបសម្ព័ន្ធ តារាង ២៨) ។ អត្រាកំណើន ខ្ពស់នៃប្រជាជនដល់អាយុធ្វើការ នឹងបង្កើនកម្លាំងពលកម្មក្នុងទសវត្សរ៍ខាងមុខ ។ រាជរដ្ឋាភិបាលត្រូវ បង្កើតផលិតភាពការងារថែមទៀត បង្កើតការគាំពារសង្គមដល់អ្នកងាយរងគ្រោះ រួមទាំងសុវត្ថិភាព វិជ្ជា ជីវៈ និងលក្ខខណ្ឌសុខភាពឲ្យបានល្អ និងការងារជំនាញថែមទៀត ដែលអាចនាំមកនូវកំណើន និងការ ប្រកួតប្រជែង ។

*សេចក្តីត្រូវការសម្រាប់បង្កើនផលិតភាព ដើម្បីបញ្ឈប់ការងារងាយរងគ្រោះ និងភាពក្រីក្រ*

ដូចបានកត់សម្គាល់ក្នុងផ្នែក ៣.២.៥ ប្រទេសកម្ពុជា បានស្ថិតនៅក្រោយប្រទេសដទៃទៀតក្នុង តំបន់អាស៊ានចំពោះកម្រិតផលិតភាព ។ ការបង្កើនផលិតភាពការងារ និងបង្កើនការប្រកួតប្រជែងផលិតផលរបស់កម្ពុជានឹងនៅបន្តជាអាទិភាពក្នុងឆ្នាំខាងមុខ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ បានកំណត់នូវតម្រូវការសម្រាប់ធ្វើឲ្យប្រសើរឡើង និងអប់រំដល់កម្លាំងពលកម្មដែលត្រូវការជាមុនសម្រាប់បង្កើនផលិតភាព ។

ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាមានភាពនឹងនរ ក្នុងមួយទសវត្សរ៍កន្លងមក បានថយចុះជា មធ្យម ១ ភាគរយក្នុងមួយឆ្នាំ ហើយនិងអត្រាបច្ចុប្បន្នមានប្រមាណ ៣០ ភាគរយ ។ ម្យ៉ាងទៀតអ្នកគ្មាន ការងារធ្វើ ដូចបានកំណត់ជាផ្លូវការ នៅមានកម្រិតទាបតិចជាង ២ ភាគរយ ។

ទោះបីមាននិន្នាការជាវិជ្ជមានក៏ដោយ ជាសំខាន់មិនត្រូវរំលងចំនួនកម្មករក្នុង "ការងារងាយរង គ្រោះ" ឡើយ ។ កម្មករទាំងនេះ ជាសំខាន់នៅក្នុងចំណោមភាគច្រើនដែលខ្វះការអប់រំ និងជំនាញ ដែលនាំ ឲ្យខ្វះឱកាស និងមានចំណូលទាប ក៏ដូចជាកម្មករងាយរងគ្រោះ ដែលភាគច្រើនមានការតក់ស្លុតដោយមិន រំពឹងទុកជាមុន ដូចជាគ្មានការងារធ្វើ

ឬសង្រោះបន្ទាន់ខាងវេជ្ជសាស្ត្រ (ដោយសារពួកគេមានប្រាក់បន្តិច បន្តួច សន្សំទុកសម្រាប់ហេតុការណ៍ដោយចៃដន្យ) ។ វាសំខាន់ខ្លាំងណាស់ ដែលផលិតភាពរបស់កម្មករ ទាំងនេះត្រូវបានលើកកម្ពស់ ដូច្នេះពួកគាត់អាចបង្កើនប្រាក់ចំណូល និងផុតពីភាពក្រីក្រ ។

ក្រុមមួយចំនួនក្នុងសង្គម ត្រូវការជាពិសេសនូវជំនួយដល់ផលិតភាពការងារ ដោយសារពួកគេមាន ជំនាញទាប និងឱកាសការងារមានកម្រិត ។ ទាំងនេះរួមបញ្ចូលទាំងអ្នករស់នៅក្រោម ឬជិតបន្ទាត់ភាព ក្រីក្រ យុវជន(អ្នកមានវិសមមាត្រភាគរយខ្ពស់នៃអ្នកគ្មានការងារធ្វើ) ស្ត្រី (អ្នកដែលនៅតែប្រឈមទៅនឹង ការបង្ខិតបង្ខំ ទាក់ទងនឹងឥរិយាបទប្រពៃណី និងមានការអប់រំតិចតួច) អ្នកដែលរស់នៅក្នុងតំបន់ដាច់ ស្រយាល និងជនបទក្រីក្រ ។ គោលនយោបាយ និងកម្មវិធី ដើម្បីបង្កើនឱកាសការងារសម្រាប់ក្រុមទាំង នេះ និងបង្កើនសមត្ថភាព ការងាររបស់ពួកគេ គឺជាការចង់បានរបស់កម្ពុជាដើម្បីទ្រទ្រង់នូវកំណើន និងការ អភិវឌ្ឍន៍សង្គម និងពង្រឹងមូលដ្ឋានធនធានមនុស្សទាំងអស់របស់ប្រទេស និងការប្រកួតប្រជែងសេដ្ឋកិច្ច ។

## *ការអភិវឌ្ឍន៍ជំនាញ និងសមត្ថភាពការងារ*

ទោះបីបានធ្វើឲ្យប្រសើរឡើង គួរឲ្យកត់សម្គាល់ក្នុងឆ្នាំកន្លងមកនេះក៏ដោយ ប្រទេសកម្ពុជាបាន ប្រឈមនឹងការប្រកួតប្រជែងដ៏សំខាន់ក្នុងការកសាងមូលដ្ឋានធនធានមនុស្សឲ្យបានខ្លាំង និងកម្លាំងពល កម្មប្រកបដោយជំនាញទៅតាមតម្រូវការទីផ្សារការងារ ។ ប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលត្រូវបានបំផ្លាញ ក្នុងឆ្នាំមានសង្គ្រាម បានបន្សល់ទុកនូវកម្លាំងពលកម្មដែលខ្វះជំនាញ និងសមត្ថភាពចាំបាច់សម្រាប់ពួកគេ ដែលនាំឲ្យមានជំនាញទាប ចំណូលទាប និងមានឱកាសតិចតួច ។ ទោះបីការសម្រេចបានជាទូទៅក្នុងការ ទទួលបាននូវការអប់រំ និងមានគុណភាពជាង ១៥ ឆ្នាំកន្លងមកនេះ (ជាពិសេសនៅកម្រិតបឋមសិក្សា) សាកលវិទ្យាល័យ និងសាលាបណ្តុះបណ្តាលបច្ចេកទេសនៅមានកម្រិត និងមិនស្របទៅនឹងតម្រូវការទីផ្សារការងារ។ មួយផ្នែកដែលជាលទ្ធផលនៃបញ្ហានេះ បច្ចុប្បន្នកម្ពុជាប្រយុទ្ធប្រឆាំងជាមួយនឹងភាពមិនត្រូវ គ្នារវាងជំនាញរបស់កម្លាំងពលកម្ម និងការចង់បានរបស់និយោជក ហើយមានលក្ខខណ្ឌកាន់តែធ្ងន់ឡើង ដោយសារកំណើនលឿននៃកម្លាំងពលកម្ម និងដំណើរការយឺតនៃការបង្កើតសេដ្ឋកិច្ចថ្មីៗ ច្រើនទៀត ។

តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសកម្ពុជាមានចំនួនសាកលវិទ្យាល័យ និងសាលា បណ្តុះបណ្តាលបច្ចេកទេសកើនឡើងគួរឲ្យកត់សម្គាល់ ។ ទោះជាយ៉ាងណាក៏ដោយ គុណភាពនៃការ បង្រៀន និងកម្មវិធីសិក្សានៅតាមវិទ្យាស្ថានទាំងនេះ នៅមានការព្រួយបារម្ភដោយនិយោជកមានការលំបាក ស្វែងរកជំនាញសមស្របសម្រាប់កន្លែងធ្វើការ ។ ក្រៅពីមុខជំនាញ "ពិបាក" ក៏ត្រូវពង្រឹងផងដែរនូវមុខ ជំនាញផ្សេងៗទៀត ដូចជាការចេះគិតពិចារណា ការទំនាក់ទំនង និងភាពជាអ្នកដឹកនាំដែលមិនអាចខ្វះបាន សម្រាប់និយោជកក្នុងប្រទេស ។ ទោះបីមន្ត្រីជាជនជាតិកម្ពុជា និងផ្នែកសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជាត្រូវបាន គ្រប់គ្រងដោយជនបរទេសក៏ដោយ អ្នកគ្រប់គ្រងដែលនៅមានការខ្វះខាតខាងភាពប៉ិនប្រសប់ក្នុងស្រុក ប្រកបដោយគុណភាពយូរអង្វែង គឺតម្រូវឲ្យមានការប្តូរនិន្នាការនេះ ។

ការគ្មានប្រសិទ្ធភាពនៃទីផ្សារការងារ ក៏កើតមានឡើងផងដែរនូវភាពមិនស្មើគ្នានៃរចនាសម្ព័ន្ធរវាង ចំនួនបានបញ្ចប់កម្រិតសិក្សាសាកលវិទ្យាល័យ និងចំនួនទទួលបានចំណេះដឹងខាងបច្ចេកទេសនិងវិជ្ជាជីវៈ។ ប្រទេសកម្ពុជា តាមកម្រិតនៃការអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន ត្រូវការខ្លាំងនូវពលកម្មជំនាញតាមប្រភេទថ្មី ក្នុងវិជ្ជាជីវៈ ដូចជាជាងម៉ាស៊ីន អ្នកបច្ចេកទេសខាងអគ្គីសនី និងជំនាញខាងវិជ្ជាពេទ្យ និងសំណង់ព្រោះជា ការងារថ្មីដែលត្រូវបានបង្កើតឡើង ។ បច្ចុប្បន្នទោះបីប្រទេសមានអ្នកបញ្ចប់កម្រិតសាកលវិទ្យាល័យច្រើន ក៏ដោយ តែនៅមានចំនួនតិចតួចនៃមុខវិជ្ជា(ដូចជាវិទ្យាសាស្ត្រសង្គម និងការសិក្សាទាក់ទងនឹងពាណិជ្ជកម្ម) ដែលមិនត្រូវទៅនឹងមុខរបរវិជ្ជាជីវៈ ។ ជាទូទៅវាអាចទាមទារការយល់ដឹងរបស់យុវជនដែលមានការ សិក្សាអប់រំនៅសាកលវិទ្យាល័យ អាចប្រកបមុខជំនួញបានច្រើនជាងចំណេះដឹងខាងបច្ចេកទេស និងវិជ្ជា ជីវៈ ។ តាមការពិតត្រូវចំណាយពេលវេលាច្រើន និងធ្វើការពិចារណាក្នុងការពង្រីកព័ត៌មានទីផ្សារការងារ និងលើកស្ទួយតម្លៃការងារនៃការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីបង្វែរការយល់ដឹងទាំងនេះ ហើយនាំមកនូវសេចក្តីប្រាថ្នានៃកម្លាំងពលកម្មឲ្យខិតទៅជិតភាពត្រូវគ្នា ជាមួយនឹងការសង្ឃឹមទុកនៃទីផ្សារ ការងារ ។

សម្រាប់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចបច្ចុប្បន្ន ការពង្រឹងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជារឿងសំខាន់សម្រាប់កម្ពុជា។

ទោះបីមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ដូចជាការអភិវឌ្ឍន៍ក្របខ័ណ្ឌវិស័យ អប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាតិមួយ និងការយល់ព្រមនៃស្តង់ដារសមត្ថភាពជំនាញ មូលដ្ឋាន ក៏ដោយ ក៏ការបណ្តុះបណ្តាលរបស់រដ្ឋ និងឯកជននៅមានក្រិតទាំងសមត្ថភាព និងការឆ្លើយតប ទៅនឹងតម្រូវការទីផ្សារការងារ ។ ក្នុងករណីជាច្រើន មុខវិជ្ជាមួយចំនួនត្រូវបានរៀបចំតាមទម្លាប់និងត្រូវ បានធ្វើដដែលៗពីមួយឆ្នាំទៅមួយឆ្នាំ ជាមួយនឹងការពិចារណាបន្តិចបន្តួចប៉ុណ្ណោះ។ មុខវិជ្ជាបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈខាងជាងកាត់ដេរ ត្រូវបានរៀបចំតាមការពិគ្រោះយោបល់ជាមួយនឹងនិយោជក មានពេលតិចតួច ដែលធ្វើឲ្យមុខវិជ្ជាបច្ចុប្បន្ន មិនបានផ្តល់ឲ្យស្របតាមលក្ខខណ្ឌដែលទីផ្សារការងារមាន។ កត្តាទាំងនេះ កាន់តែធ្វើឲ្យលំបាក ដែលតាមការពិត និស្សិតភាគច្រើនមានចំណេះដឹងមិនគ្រប់គ្រាន់ខាងទី ផ្សារការងារ ដើម្បីអាចយកការសិក្សារបស់ពួកគេឈានចូលក្នុងការងារសង្ឃឹមទុកនាពេលអនាគតឡើយ។

ទាក់ទងទៅនឹងបញ្ហានេះ ប្រទេសកម្ពុជា ក៏ប្រឈមខ្លាំងទៅនឹងការប្រកួតប្រជែងការងាររបស់យុវ ជនផងដែរ ។ តាមនិន្នាការសកលលោក យុវជននៅកម្ពុជាទំនងជាគិតខ្លួនឯងថា គ្មានការងារធ្វើជាង មនុស្សពេញវ័យ ទោះបីអ្នកគ្មានការងារធ្វើជាផ្លូវការក្នុងប្រទេសមានចំនួនទាបក៏ដោយ ។ តាមមូលដ្ឋាន សេដ្ឋកិច្ចចង្អៀត បានផ្តល់នូវគម្លាតធំបន្តិចម្តងៗ រវាងសេចក្តីត្រូវការកម្លាំងពលកម្ម និងការផ្តល់ទីផ្សារ ការងារជាមួយនឹងបន្ទុកខុសគ្នានៃផលប៉ះពាល់មកលើយុវជន ។ ទោះបីឧបសគ្គ មិនអាចផ្លាស់ប្តូរបានក្នុង ដំណើរការខ្លីក៏ដោយ គេអាចដោះស្រាយក្នុងរយៈពេលវែង តាមគោលនយោបាយទ្វេ ដែលរួមបញ្ចូល យុទ្ធសាស្ត្រជាតិ ស្តីពីការងារជាមួយនឹងការវាយតម្លៃឡើងវិញនៃតម្លៃការងារបច្ចុប្បន្ន និងកំណើនសេដ្ឋកិច្ច នាពេលអនាគតរបស់ប្រទេស ។

### ៥.៣.២ ការគាំពារសង្គម ដើម្បីប្រយុទ្ធនឹងភាពងាយរងគ្រោះ

មុនពេលសេដ្ឋកិច្ចធ្លាក់ចុះ ប្រទេសកម្ពុជាមានកំណើនស្ទើរជាងមួយទសវត្សរ៍ នាំមកនូវកំណើនដ៏ រឹងមាំមួយនៃការចំណាយពិតសម្រាប់មនុស្សម្នាក់ និងការធ្លាក់ចុះនៃភាពក្រីក្រ ។ បច្ចុប្បន្នក៏ដូចជាអតីត កាល ភាគច្រើននៃប្រជាជនដែលក្រីក្រ និងងាយរងគ្រោះរស់នៅក្នុងតំបន់ជនបទ ។ ដូច្នេះ ទោះបីសម្រេច បានពិតប្រាកដក៏ដោយ ក៏បង្ហាញថាប្រជាជនមួយចំនួននៅមានមូលហេតុផ្សេងៗ មិនអាចកាត់បន្ថយហានិ

ភ័យបាន បាន បង្កើននូវភាពងាយរងគ្រោះរបស់ពួកគេក្នុងពេលសេដ្ឋកិច្ចធ្លាក់ចុះដែលមិនបានគិតមុនដែលនាំ ឲ្យពួកគេអាចធ្លាក់មកភាពក្រីក្រ ។

ការគាំពារសង្គម (សន្តិសុខសង្គម) គឺជាទំនាក់ទំនងនៃវិធានការសាធារណៈផ្តល់ដោយសង្គមដល់ សមាជិក ក៏ដូចជាដោយឯកជន ឬគម្រោងផ្សេងៗ ដែលមានគោលបំណងប្រហាក់ប្រហែលគ្នា ។ ប្រព័ន្ធ គាំពារសង្គមនៅកម្ពុជា គឺជាដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍ ដែលគ្រាន់តែកំណត់ប្រយោជន៍ដល់ក្រុម ត្រូវបានគាំពារ ដូចជាមន្ត្រីស៊ីវិល និងនិយោជិតផ្នែកឯកជន និងកម្មវិធីផ្សេងៗ (សំខាន់អ្នកផ្តល់ជំនួយ) សម្រាប់សេដ្ឋកិច្ចមិនរៀបរយ និងអ្នកក្រីក្រ ។

ការវិនិយោគខាងការគាំពារសង្គមនឹងជួយកាត់បន្ថយភាពក្រីក្រ និងវិសមភាព ។ ផ្នែកមួយនៃបញ្ហា ប្រឈមរបស់កម្ពុជានៅពេលអនាគត គឺការអនុវត្តន៍យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់អ្នកក្រីក្រ និងជន ងាយរងគ្រោះ ដែលតម្រូវឲ្យកសាងមូលដ្ឋាននៃការគាំពារសង្គមដែលប្រាក់បំណាច់ មានកម្រិតខ្ពស់ឡើងជា លំដាប់។ មូលដ្ឋាននៃការគាំពារសង្គម គឺជាការធានារ៉ាប់រងដល់ការគាំពារសង្គមសម្រាប់ប្រជាជនទាំងអស់ តាមរយៈកញ្ចប់ប្រាក់បំណាច់ និងសេវាកម្មសង្គមបំពេញបង្គ្រប់ ដើម្បីដោះស្រាយនូវភាពងាយរងគ្រោះ ព្រមជាមួយនឹងវិធីសាស្ត្រខួបនៃជីវិតសម្រាប់កុមារ ស្ត្រីនិងម្តាយមានគភ៌ ប្រជាជនដល់អាយុធ្វើការ ជន ពិការ និងចាស់ជរា ។

## ៥.៣.៣ សមភាពខាងយេនឌ័រ

ដូចបានរៀបរាប់រួចមកហើយ ការកើនឡើងអត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្ត្រី ក៏ដូចជា កំណើនអត្រាអ្នកមានការងារធ្វើធៀបនឹងប្រជាជន សម្រាប់ស្ត្រីផងដែរ ។ ទោះបីកំណើនលឿនខាងវិស័យ កាត់ដេរបានធ្វើឲ្យកើនឡើងនៃអ្នកមានការងារធ្វើទទួលប្រាក់ឈ្នួលជាស្ត្រីក៏ដោយ ក៏ភាពខុសគ្នាខាងយេន ឌ័រនៃអ្នកមានការងារធ្វើ និងការងារសមរម្យនៅតែមានដដែល ។ ភាពខុសគ្នានេះ មានទំហំធំដោយសារឥរិ យាបទប្រពៃណីអំពី "ភាពសមរម្យ" ខាងមុខរបររបស់ស្ត្រី និងបុរសដែលទាក់ទងជាសំខាន់ដល់ការទទួល បានការសិក្សា ការបណ្តុះបណ្តាល និងសេវាកម្មគាំទ្ររបស់ក្មេងស្រី និងស្ត្រី ។

ប្រមាណ ៧៨ ភាគរយនៃស្ត្រីទាំងអស់ បានចូលរួមក្នុងវិស័យបឋម ដែលភាគច្រើននៃពួកគេនៅ ក្នុងកសិកម្ម ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីក្នុងកសិកម្ម គឺជាអ្នកធ្វើការឲ្យគ្រួសារដោយមិនយកប្រាក់ ឈ្នួល ។

ស្ត្រីនៅតំបន់ជនបទក៏មិនសូវចេះអាន និងសរសេរអក្សរ មានច្រើនជាងបុរសនៅជនបទ និងជា ពិសេសធ្វើឲ្យការទទួលបាននូវឥណទានដីធ្លី និងធនធានដទៃទៀតរបស់ពួកគេនៅមានកម្រិត ។ ទន្ទឹមនឹង ច្បាប់ដីធ្លី រួមទាំងវិធានការធានាសិទ្ធិស្ត្រី កម្រិតទាបនៃការចេះអាន និងសរសេរអាចរារាំងដល់ការផ្តល់ សិទ្ធិ ។ ព័ត៌មានអំពីទីផ្សារ និងបច្ចេកវិទ្យាបានធ្វើឲ្យមានការភ័យខ្លាចដល់គុណភាពទាប ដែលជាទូទៅ បុរសអាចទទួលយកបានជាងស្ត្រី ។ ទាំងអស់នេះបានកំណត់ឱកាសសម្រាប់ស្ត្រី ដើម្បីបង្កើនផលិតកម្ម របស់ពួកគេ និងធ្វើឲ្យប្រសើរឡើងដល់ជីវភាពរស់នៅរបស់ពួកគេផងដែរ ។ សមាមាត្ររបស់ស្ត្រីធំជាង បុរសក្នុងវិស័យកសិកម្ម ក៏អាចបញ្ជាក់បានថា ឱកាសតិចតួចណាស់សម្រាប់ស្ត្រីដែលមានជំនាញតិចជាង បុរសក្នុងវិស័យមិនមែនកសិកម្ម ។ ការបណ្តុះបណ្តាលជាញឹកញាប់ពុំមានភាពសមស្របសម្រាប់ស្ត្រី ដោយសារការទទួលខុសត្រូវបន្ថែមរបស់ពួកគាត់សម្រាប់ការងារគ្រួសារ និងការថែទាំក្មេង ។ ក្នុងករណីខ្លះ កម្មវិធីបណ្តុះបណ្តាលធ្វើឲ្យយេនឌ័រពុំមានការប្រែប្រួលក្នុងការជ្រើសរើសអាជីពឡើយ ។ កត្តាទាំងនេះ ដោយរួមទាំងការមិនចូលរួមក្នុងសង្គមផ្អែកតាមភេទផង មានន័យថាកម្មការិនីមិនត្រូវបានយកចិត្តទុកដាក់ ឲ្យបានស្មើទៅនឹងបុរសនៅពេលដែលពួកគេត្រូវបានឲ្យទទួលធ្វើការងារ និងសេវាកម្ម ។

## ៥.៣.៤ ទំនាក់ទំនងវិជ្ជាជីវៈ

ទំនាក់ទំនងវិជ្ជាជីវៈ ជាពិសេសក្នុងឧស្សាហកម្មកាត់ដេរត្រូវចាត់ទុកថា មានកម្រិតខ្ពស់ខាងវិវាទ ដែលគួរពិចារណាក្នុងប្រព័ន្ធដ៏ក្មេងខ្ចីនេះ ។ សហជីព និងនិយោជកមិនមានចំណេះដឹង ឬឧបករណ៍ចូលរួម ក្នុងការដោះស្រាយ និងមានវិធានការការពារវិវាទរួមទាំងកិច្ចព្រមព្រៀងអនុសញ្ញារួម ។ និយោជកបានកត់សម្គាល់ថា ពហុសហជីព និងការប្រកួតប្រជែងសហជីពនៅទីកន្លែងធ្វើការ និងកូដកម្មដែលមិនតាមនីតិវិធី បានបង្កើននូវការប្រកួតប្រជែងសម្រាប់ទំនាក់ទំនងវិជ្ជាជីវៈល្អ ក្នុងវិស័យកាត់ដេរ ។ សហជីពតវ៉ាអំពី ប្រាក់ឈ្នួលទាបឬមិនទូទាត់ឲ្យ ការរើសអើងប្រឆាំងសហជីព និងការរំលោភលើកិច្ចព្រមព្រៀងរយៈពេល ខ្លី ។ ទាំងនេះត្រូវបានផ្លាស់ប្តូរបន្តិចម្តងៗ ដែលនាំឲ្យកម្មករ និងនិយោជកធ្វើការជាមួយគ្នា ដើម្បីធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ ។ ដូចបានរៀបរាប់ក្នុងផ្នែក ៣.២.៩ ការចាប់ផ្តើមគំនិតមួយចំនួន បានផ្តល់មូលដ្ឋានរឹងមាំមួយ

សម្រាប់ធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ ។ ទោះជាយ៉ាងណាក៏ដោយ វានៅតែជាបញ្ហាប្រឈមដ៏ចម្បងមួយ ។

### ៥.៣.៥ ស្ថិតិទីផ្សារការងារទាន់ពេលវេលា

បញ្ហាប្រឈមចម្បងផ្សេងទៀត សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងត្រូវពិចារណា គឺ កង្វះខាតស្ថិតិពលកម្ម ដែលជាចំណុចសំខាន់ សម្រាប់ធ្វើផែនការគោលនយោបាយក្នុងការបង្កើតនូវភាព សមរម្យ និងផលិតភាពការងារ និងកាត់បន្ថយភាពក្រីក្រ ។ បញ្ហាប្រឈមនេះធ្វើឲ្យមានការលំបាកនាពេលបច្ចុប្បន្នក្នុងការតាមដានដល់វិសាលភាព និងដំណើរការនៃវិបត្តិសេដ្ឋកិច្ចសកលលោក ដែលមានផលប៉ះពាល់ខ្លាំងដល់ប្រទេសកម្ពុជា។

សេដ្ឋកិច្ចបានកើនឡើងគួរឲ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំកន្លងមក ប៉ុន្តែព័ត៌មាននៅមានកម្រិតនៅឡើយ អំពីទីផ្សារការងារចំពោះកំណើនដ៏អស្ចារ្យនេះ ។ កំណើននៅកម្ពុជាបាន និងបន្តកើនឡើងដោយផ្អែកលើ ភាគច្រើននៃការនាំចេញ និងការវិនិយោគផ្ទាល់ពីបរទេស ហើយទាំងនេះបានផ្តល់លទ្ធផលក្នុងកម្រិតនៃការផ្លាស់ប្តូរពីកសិកម្មសុទ្ធសាធទៅរចនាសម្ព័ន្ធសេដ្ឋកិច្ចឧស្សាហកម្មមុនគេ ។ ការផ្លាស់ប្តូរទាំងនេះ អាចទៅជាមួយគ្នា តាមការប្រែប្រួលក្នុងទីផ្សារការងារ ដែលជាការប្រែប្រួលឱកាស និងសេចក្តីប្រាថ្នា ។ ទោះជាយ៉ាងណាក៏ដោយ អវត្តមានដ៏សំខាន់នៃទិន្នន័យទាន់សម័យ និងគួរទុកចិត្តបាន និងការវិភាគទាំង បរិមាណ និងគុណភាពនៃការងារ ក្នុងប្រទេសនៅតែជាឧបសគ្គចម្បងដល់ការរៀបចំគោលនយោបាយ ការងារ និងការអភិវឌ្ឍន៍ឲ្យបានត្រឹមត្រូវ ។

បច្ចុប្បន្ន គម្លាតចម្បងដែលមានក្នុងការប៉ាន់ស្មាន និងការវិភាគសេដ្ឋកិច្ចមិនរៀបរយ ប្រភេទទំនាក់ ទំនងការងារ ភាពមិនត្រូវគ្នាខាងមុខជំនាញ ភាពគ្មានការងារធ្វើគ្រប់គ្រាន់ ផលិតភាព និងប្រាក់ចំណូលការងារទទួលប្រាក់ចំណូលតិច គម្លាតយេនឌ័រក្នុងមុខរបរ និងប្រាក់ចំណូលពលកម្មកុមារ កម្មករធ្វើការ ផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ សុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ ម៉ោងធ្វើការ និងយន្តការដោះ ស្រាយក្នុងគ្រួសារ ។ ទាំងនេះបង្ហាញពីភាពរាំងស្ទះក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលទាក់ទងនឹងសមិទ្ធិផលនៃគោលដៅអភិវឌ្ឍន៍រយៈពេលវែង ។

ទន្ទឹមនឹងភាគច្រើននៃអ្នកវិភាគយល់ព្រមថា វិបត្តិសេដ្ឋកិច្ចបច្ចុប្បន្នមានផលប៉ះពាល់ចម្បងទៅលើ ទីផ្សារការងារ អវត្តមានទិន្នន័យថ្នាក់ជាតិដែលគួរទុកចិត្តបាន និងមានគុណភាពខ្ពស់ក៏ត្រូវបានចាប់

អារម្មណ៍ផងដែរដោយសារការវាយតំលៃសឹងតែទាំងអស់ត្រូវពឹងផ្អែកទៅលើតួលេខជាក ស្តុតាង និងការ អង្កេតជាក់លាក់តាមវិស័យ និងតំបន់ ។

ការអង្កេតកម្លាំងពលកម្មគួរតែមានប្រសិទ្ធភាពខ្ពស់ ដើម្បីជួយឲ្យអ្នកស្រាវជ្រាវ និងអ្នកធ្វើគោល នយោបាយអាចធ្វើការវិភាគអំពីបញ្ហាប្រឈម និងរៀបចំគោលនយោបាយ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ ជាតិ និងកាត់បន្ថយភាពក្រីក្រ ។ ការអង្កេតកម្លាំងពលកម្មកន្លងមកត្រូវបានដំណើរការនៅឆ្នាំ ២០០១ ហើយតាំងពីនោះមក ការផ្លាស់ប្តូរមួយចំនួនកើនឡើងក្នុងកម្លាំងពលកម្ម និងទីផ្សារការងារ ។ ជំរឿន ប្រជាជនឆ្នាំ ២០០៨ បានផ្តល់ព័ត៌មាននៅមានកម្រិតអំពីសូចនាករទីផ្សារការងារខ្លះមុនវិបត្តិបច្ចុប្បន្ន ។ អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០០៤ និងឆ្នាំ ២០០៧ ក៏ផ្តល់ព័ត៌មានមួយចំនួននៅមានកម្រិតផងដែរអំពីការងារ ភាពគ្មានការងារធ្វើ និងស្ថានភាពការងារ ប៉ុន្តែមិនទូលំទូលាយ និងមិនសូវមានទិន្នន័យច្រើន ទាក់ទងនឹងការងារសមរម្យ ។ ការប្រែប្រួលគួរឲ្យកត់សម្គាល់ក្នុងសេដ្ឋកិច្ច និងទំនាក់ទំនងទីផ្សារការងារ ការធ្វើអង្កេតកម្លាំងពលកម្មពេញលេញមួយ នឹងមិនអាចចៀសបានឡើយក្នុងពេលបច្ចុប្បន្ននេះ ដើម្បីយល់ដឹងនូវភាពស្មុគ្រស្មាញនៃទីផ្សារការងារ សម្រាប់ប្រើប្រាស់ក្នុងការរៀបចំគោលនយោបាយ ហើយវាក៏ត្រូវ បានកត់ត្រាក្នុងផែនការមេស្ថិតិរបស់វិទ្យាស្ថានជាតិស្ថិតិផងដែរ ។ កង្វះខាតទិន្នន័យបច្ចុប្បន្នកម្ម និងទូលំ ទូលាយទីផ្សារការងារ គឺជាការរារាំងដ៏សំខាន់មួយក្នុងការអភិវឌ្ឍន៍គោលនយោបាយការងារ គោលនយោបាយទីផ្សារការងារសកម្ម និងកម្មវិធីគាំពារសង្គមសម្រាប់ទូទាំងប្រទេស ។

## ៥.៤ គោលនយោបាយ

### ៥.៤.១ យុទ្ធសាស្ត្រ និងគោលនយោបាយជាតិដែលផ្តោតលើការងារខាងយេនឌ័រ

អត្រាកំណើនខ្ពស់នៃ GDP បាននាំឲ្យកាត់បន្ថយជាក់ស្តែងនូវកម្រិតភាពក្រីក្រក្នុងឆ្នាំកន្លងមកនេះ។ ទោះបីមានសមិទ្ធផលរួមគ្នា ប្រទេសកម្ពុជានឹងបន្តត្រូវការឲ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងពហុសណ្ឋាននៅឆ្នាំខាងមុខនេះ ក៏ដូចជាពន្លឿនផលិតភាព និងបង្កើតការងារមានកម្រៃខ្ពស់ដើម្បីបង្ការ នូវភាពយឺតយ៉ាវដល់គោលដៅអភិវឌ្ឍន៍នាពេលអនាគត ។ ទោះបីការធ្លាក់ចុះនូវអត្រាគ្មានការងារធ្វើដល់ ប្រមាណ ១,៦ ភាគរយក៏ដោយ ឧប្បត្តិហេតុនៃភាពក្រីក្រនៅតែមានប្រមាណ ៣០ ភាគរយ ហើយស្ថាន ភាពនេះ បាន បង្ហាញចរិតលក្ខណៈនៃការប្រកួតប្រជែងការងារបច្ចុប្បន្ន ដែលច្រើនទាក់ទងទៅនឹងបញ្ហា "ការងារងាយរងគ្រោះ" ។

ភាពងាយរងគ្រោះនៃការងារ និងចំណូលអាចកើតមានក្នុងចំណោមប្រជាជនធ្វើការ ។ ផលប៉ះពាល់ នៃវិបត្តិសេដ្ឋកិច្ចសកលលោក បានធ្វើឲ្យមានបញ្ហាប្រឈមនៃការបង្កើតឱកាសការងារសមរម្យ ។ ទោះបី ការឆ្លើយតបរបស់រាជរដ្ឋាភិបាលទៅនឹងវិបត្តិបានឆាប់រហ័សក៏ដោយ ផលប៉ះពាល់ក៏នៅតែមាន ។ ដោយ សារទិន្នន័យគួរទុកចិត្តបានថ្នាក់ជាតិនៅមិនទាន់មានដើម្បីបង្ហាញថា ភាពគ្មានការងារធ្វើបានកើនឡើងនោះ ក៏មិនអាចនិយាយបំផ្លើសបានថា វិបត្តិអាចនឹងឡើងខ្លាំងចំពោះភាពគ្មានការងារធ្វើ និងការងារងាយរង គ្រោះក្នុងសេដ្ឋកិច្ចមិនរៀបរយបានឡើយ ។ ជាការពិតប្រជាជនមួយចំនួនជួបការលំបាកដែលនាំឲ្យគ្មាន ការងារធ្វើនៅពេលដែលពុំទាន់មានយន្តការដោះស្រាយ ។ ម្យ៉ាងទៀតវិបត្តិសេដ្ឋកិច្ចក៏បង្ហាញពីភាពងាយ រងគ្រោះរបស់កម្មការិនីក្នុងផ្នែកឧស្សាហកម្ម (កាត់ដេរ) ក្នុងប្រទេស និងរារាំងដល់សមិទ្ធិផលមួយចំនួន ដែលបានមកដោយលំបាក ក្នុងការផ្លាស់ស្ត្រីចេញពីកសិកម្មដែលមានផលិតភាពទាប ទៅទទួលបានផលិត ភាពខ្ពស់ និងការងារទទួលប្រាក់ឈ្នួលត្រឹមត្រូវ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ បានដាក់ការកាត់បន្ថយភាពក្រីក្រជាអាទិភាព ជាតិខ្ពស់ជាងគេ ។ រាជរដ្ឋាភិបាលបានបង្ហាញតម្រូវការសម្រាប់ "ការផ្តោតលើការយកចិត្តដាក់ និងសកម្ម ភាពគោលដៅ ដើម្បីសម្រេចបានគោលដៅសហស្សវត្សរ៍កម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ" (NSDP ២០០៦-២០១០) ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ (NSDP Update ២០០៦-២០១០) បានកំណត់ថា "ការបង្កើតការងារ និងការធានាកែលម្អលក្ខខណ្ឌការងារ គឺជាគោលដៅបន្តរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅ របស់ប្រជាជន ការកាត់បន្ថយភាពក្រីក្រ និងការពន្លឿនកំណើនសេដ្ឋកិច្ច" ។ ទាំងនេះបានផ្តល់នូវបរិបទ និងភាពត្រឹមត្រូវ សម្រាប់រៀបចំយុទ្ធសាស្ត្រជាតិស្តីពីការងារ និងសម្រាប់ដាក់នៅក្នុងក្របខ័ណ្ឌការងារ អភិវឌ្ឍន៍ជាតិ ។

គោលដៅមូលដ្ឋាននៃយុទ្ធសាស្ត្រការងារ គឺជួយដល់អ្នករៀបចំផែនការគោលនយោបាយដៃគូខាង សង្គមកិច្ច និងភាគីទាក់ទងដទៃទៀត ដើម្បីរៀបចំគោលនយោបាយ និងកម្មវិធីផ្តោះទៅការបង្កើតនូវផលិត ភាពការងារ និងទទួលបានកម្រៃខ្ពស់ជាមួយនឹងការងារដែលពេញចិត្ត ។ យុទ្ធសាស្ត្រការងារ ក៏នឹងជួយ

រាជរដ្ឋាភិបាលក្នុងការបង្កើតការងារ (បរិមាណ និងគុណភាព) និងធ្វើគោលនយោបាយស្តីពីសេដ្ឋកិច្ច និង សង្គមកិច្ច ដើម្បីលើកស្ទួយគោលដៅនៃការងារពេញលេញ និងការងារសមរម្យ ។ ទន្ទឹមនឹងការកំណត់ គោលនយោបាយ ការងារត្រូវបានរៀបចំនោះ គួរត្រូវដាក់បញ្ចូលផងដែរនូវការងារមួយចំនួន ជាពិសេស សម្រាប់ស្ត្រីកម្មករនៅជនបទ និងកម្មករងាយរងគ្រោះ ទៅក្នុងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយតាមវិស័យ គោលនយោបាយអភិវឌ្ឍន៍ជំនាញ គោលនយោបាយទេសន្តប្រវេសន៍ និងគោល នយោបាយអភិវឌ្ឍន៍សហគ្រាស ។ ក្នុងគោលនយោបាយនីមួយៗ ការប្រុងប្រយ័ត្នគួរត្រូវបានពិចារណា ដើម្បីធានាដល់ភាពត្រឹមត្រូវ និងតម្រូវការកាត់ដេររបស់ស្ត្រី ជាពិសេសក្មេងស្រី និងជាងនេះទៀតចំពោះ ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ជំនាញ ។

## ៥.៤.២ យុទ្ធសាស្ត្រគាំពារសង្គម

ដើម្បីអភិវឌ្ឍន៍ចក្ខុវិស័យរួម និងតាមផ្នែក អំពីការពង្រីកនៃការគាំពារសង្គម និងដើម្បីបង្កើនការ សម្របសម្រួល និងទំនាក់ទំនងរវាងសមាសភាពក្នុងការខិតខំនេះ យុទ្ធសាស្ត្រស្តីពីការគាំពារសង្គមពីរត្រូវ បានបង្កើតៈ

- ផែនការមេស្តីពីការគាំពារសុខភាពសង្គមបង្កើតដោយក្រសួងសុខាភិបាល និងរង់ចាំអនុមតិដោយ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។ ផែនការនឹងរៀបចំអភិវឌ្ឍន៍ប្រព័ន្ធគាំពារសុខភាពសង្គមរួម មួយដែលគ្របដណ្តប់ប្រជាជនទាំងអស់ (រដ្ឋបាលនៃគម្រោងដែលមានស្រាប់) ។

- យុទ្ធសាស្ត្រជាតិស្តីពី ការគាំពារសង្គមសម្រាប់អ្នកក្រីក្រ និងជនងាយរងគ្រោះបង្កើតដោយក្រុម ប្រឹក្សាសម្រាប់ការអភិវឌ្ឍន៍កសិកម្ម បានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ ។ យុទ្ធសាស្ត្រ ផ្តល់នូវចក្ខុវិស័យសម្រាប់ការអភិវឌ្ឍន៍ គាំពារសង្គមថ្នាក់ក្រោមសម្រាប់អ្នកក្រីក្រ និងជនរងគ្រោះ ដោយចាប់ផ្តើមជាមួយនឹងការអនុវត្តន៍នៃការទទួលបានជាទូទៅនូវសេវាកម្ម សង្គមថ្នាក់មូលដ្ឋាន (សុខភាព ម្ហូបអាហារ និងការសិក្សា) និងជួយអ្នកមានចំណូលទាបបំផុតសម្រាប់ប្រជាជនដល់ អាយុធ្វើការ (កម្មវិធីការងារសាធារណៈ) និងគ្រួសារមានកូនច្រើន ក៏ដូចជាក្រុមងាយរងគ្រោះ ជាយថាហេតុ។

ក្របខ័ណ្ឌការងារយុទ្ធសាស្ត្រទាំងនេះ មាននៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែល

កំណត់ទិសដៅគោលនយោបាយទូលំទូលាយ សម្រាប់ធ្វើឲ្យប្រសើរឡើងនូវការគាំពារសង្គម និងកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍន៍សំណាញ់សុវត្ថិភាពសង្គម ។ វាបានលើកទឹកចិត្តដល់ការអភិវឌ្ឍន៍ប្រកប ដោយចិរភាព និងសមធម៌ ហើយនិងផ្តល់អាទិភាពដល់ការកែលម្អបទបញ្ញត្តិគាំពារសង្គម ។

បច្ចុប្បន្នមានកិច្ចការជាច្រើនដែលត្រូវពង្រីកការគាំពារសង្គម ដូចជាការរៀបចំ និងការចំណាយលើ គម្រោង ការបង្កើតច្បាប់ និងអនុក្រឹត្យដើម្បីធានារ៉ាប់រងដល់ការផ្តល់ផលប្រយោជន៍ខាងសន្តិសុខសង្គមដូច បានកំណត់ក្រោមគម្រោងខុសៗគ្នា ការអនុវត្តន៍រចនាសម្ព័ន្ធរដ្ឋបាលដែលនឹងគ្រប់គ្រងគម្រោង ការបង្កើតយន្តការសម្របសម្រួល ការធ្វើឲ្យមានប្រតិបត្តិច្បាប់ ការបង្កើតយន្តការដែលអាចទុកចិត្តបានជាដើម ។

ប្រព័ន្ធជាតិស្តីពីសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ ស្ថិតនៅក្រោមការអភិវឌ្ឍន៍ខាងច្បាប់ ការ ត្រួតពិនិត្យ ការគាំទ្រ និងការបណ្តុះបណ្តាល ។ សមត្ថភាពនៃសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការថ្នាក់ ជាតិ ត្រូវការពង្រឹងតាមរយៈផែនការ និងការអភិវឌ្ឍន៍កម្មវិធីជាតិស្តីពីសុវត្ថិភាព និងសុខភាពនៅកន្លែង ធ្វើការ ។

### ៥.៤.៣ បរិយាកាសសម្រាប់ទំនាក់ទំនងវិជ្ជាជីវៈ

ការធ្វើឲ្យប្រសើរឡើងនូវវិធាននៃច្បាប់ទីផ្សារការងារប្រកបដោយប្រសិទ្ធភាព និងធ្វើឲ្យស្របទៅ នឹងស្ថាប័នការងារ និងការអនុវត្តតាមស្តង់ដារការងារអន្តរជាតិ តម្រូវការអភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធ សាស្ត្រ អភិវឌ្ឍន៍កម្ពុជា ។

រាជរដ្ឋាភិបាលនាឆ្នាំកន្លងមកនេះ បានគាំទ្រដល់គោលការណ៍ និងគោលនយោបាយដែលធ្វើឲ្យ ប្រសើរឡើងនូវអភិបាលកិច្ចនៃទីផ្សារការងារ ។ នៅឆ្នាំ ២០០៧ រាជរដ្ឋាភិបាលបានបង្ហាញពីការគាំទ្រដល់ ការកែលម្អ អនុសញ្ញារួមរវាងនិយោជក និងសហជីពដែលមានភាពជាតំណាងបំផុតដោយអាស្រ័យហេតុ ផលថា មានចំនួនសហគ្រាសតិចដែលមានបទពិសោធន៍ល្អខាងកិច្ចព្រមព្រៀងអនុសញ្ញារួម បើមិនដូច្នេះ នឹងមានកូដកម្ម ឬវិវាទការងារដ៏ធ្ងន់ធ្ងរ ។ ជាពិសេសនោះក្នុងឧស្សាហកម្មកាត់ដេរដែលមានសហជីពច្រើន ក៏ដូចជាការមិនយល់ព្រមឲ្យមានសហជីពដោយនិយោជក និងគ្មានការអនុញ្ញាតខាងវិវាទ ។ សហជីពមាន យ៉ាងហោចណាស់ ៥១ ភាគរយនៃកម្លាំងការងាររបស់សហគ្រាសដែលជាសមាជិកអាចបញ្ជាក់ភាពជាតំណាងបំផុត ហើយត្រូវបានផ្តល់សិទ្ធិដើម្បីចរចារក្នុងនាមកម្មករទាំងអស់ក្នុងសហគ្រាស

។ ជាលទ្ធផល នៃគោលនយោបាយនេះ និងការអនុវត្តន៍ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួនសហជីព ដែលបានបញ្ជាក់ភាពជាតំណាងបំផុត កើនឡើងច្រើនជាង ៤០០ ភាគរយ ។

ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការពីនិយោជក រាជរដ្ឋាភិបាល ក៏បានយល់ព្រមបង្កើតច្បាប់ សហជីពថ្មីមួយដែលបច្ចុប្បន្នកំពុងរៀបចំ ហើយនិងបញ្ចប់នៅក្នុងខែមិថុនា ឆ្នាំ២០១១ ខាងមុខ ។

កម្មករ និងនិយោជក ក៏បានប្តេជ្ញាតាមការសម្រេចដោយអាជ្ញាកណ្តាលទាំងការជំទាស់សិទ្ធិ និង ក្នុងកិច្ចព្រមព្រៀងអនុសញ្ញារួម ។ ពួកគាត់ក៏បានប្តេជ្ញាបញ្ឈប់ធ្វើកូដកម្ម ឬមិនចូលធ្វើការងារមុនការ សម្រេចរបស់អាជ្ញាកណ្តាល ។ ការប្តេជ្ញាទាំងនេះ ជាសកម្មភាពដ៏រឹងមាំដែលមានឥទ្ធិពលជាវិជ្ជមានដល់ ទំនាក់ទំនងវិជ្ជាជីវៈនៅប្រទេសកម្ពុជា ។

## ៥.៥ សេចក្តីសន្និដ្ឋាន

ទោះបីសម្រេចបាននូវស្នាដៃសំខាន់ៗក៏ដោយ ក៏បញ្ហាប្រឈមខាងគោលនយោបាយ នៅមានជួប ប្រទះ ដែលមានឥទ្ធិពលទៅលើការសម្រេចគោលដៅការងារសមរម្យ ។ កំណើនសេដ្ឋកិច្ចដ៏រឹងមាំមុនវិបត្តិ បាននាំឲ្យអត្រាភាពក្រីក្រថយចុះ ប៉ុន្តែកម្រិតភាពក្រីក្រនៅតែមានកំរិតគួរឲ្យកត់សំគាល់ ។ ម្យ៉ាងទៀត ទោះបីអត្រានៃអ្នកគ្មានការងារធ្វើតូច ហើយបានថយចុះក្នុងទសវត្សរ៍កន្លងមកក៏ដោយ ក៏កម្រិតនៃការងារ ងាយរងគ្រោះនៅខ្ពស់ដដែល ។ ចំនួនប្រជាជនដល់អាយុធ្វើការនឹងកើនឡើងក្នុងឆ្នាំខាងមុខ បង្ខំឲ្យទីផ្សារ ការងារផ្តល់នូវការងារប្រកបដោយគុណភាពក៏មានការកើនឡើងផងដែរ ។ ឱនភាពនៃបរិមាណ និងគុណ ភាពការងារ បានធ្វើឲ្យមានបញ្ហាប្រឈមចម្បងខាងគោលនយោបាយ ។

ព័ត៌មានទីផ្សារការងារតាមភេទ និងអាយុជាបញ្ហាសំខាន់សម្រាប់ធ្វើសេចក្តីសម្រេចចិត្ត និងបង្កើត ប្រព័ន្ធព័ត៌មានទីផ្សារការងារប្រកបដោយប្រសិទ្ធភាព ដូចដែលបានរៀបរាប់ក្នុងផែនការយុទ្ធសាស្ត្រអភិ វឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ ។ ប្រទេសកម្ពុជា បានកសាងប្រព័ន្ធស្ថិតិជាតិដ៏រឹងមាំមួយ ជំរឿន និងអង្កេតសេដ្ឋកិច្ច សង្គមកិច្ចបានផ្តល់ទិន្នន័យសម្រាប់សូចនាករទីផ្សារការងារ ។ ជាងនេះទៀត ទិន្នន័យពីក្រសួងនានា និងអង្គការសហប្រជាជាតិ បានផ្តល់ព័ត៌មានអំពីពលកម្មពិតប្រាកដ និងនិន្នាការខាង សង្គមកិច្ច ។

របាយការណ៍នេះឆ្លុះបញ្ចាំងនូវទិន្នន័យ ដែលមានសម្រាប់វិភាគទីផ្សារការងារ និងនិន្នាការ ។ ទោះ ជាយ៉ាងណាក៏ដោយ ទិន្នន័យអំពីផ្នែកសំខាន់ៗមួយចំនួន ដូចជាចំណូល ការងារក្នុងផ្នែកមិនរៀបរយ ភាព គ្មានការងារធ្វើគ្រប់គ្រាន់ ការងារជនក្រីក្រ ម៉ោងធ្វើការ យន្តការផ្លាស់ប្តូរយោបល់ខាងសង្គមដែលបច្ចុប្បន្ន មិនអាចរកបានឡើយ ។ ការខិតខំបន្ថែមតម្រូវឲ្យពឹងផ្អែកទៅលើមូលដ្ឋានព័ត៌មានសម្រាប់ការវិភាគ និង តាមដាន ដែលនឹងផ្តល់មូលដ្ឋានលើការជឿទុកចិត្ត សម្រាប់រៀបចំគោលនយោបាយទីផ្សារការងារ ។ ក្រៅ ពីនេះត្រូវមានប្រព័ន្ធប្រមូល និងផ្សព្វផ្សាយទិន្នន័យដែលត្រឹមត្រូវមួយ ហើយប្រើទិន្នន័យទាំងនេះសម្រាប់ វិភាគ និងជាព័ត៌មានទីផ្សារការងារដែលមានសារៈប្រយោជន៍យ៉ាងខ្លាំង ។

ប្រទេសកម្ពុជាបន្តរីកចំរើន និងធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចសកលលោក ដើម្បីទទួលបាន នូវភាពសមរម្យ និងផលិតភាពការងារដែលជាមធ្យាបាយមួយសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ ទោះ បីសម្រេចបានស្នាដៃច្រើនក៏ដោយ ក៏នៅមានបញ្ហាប្រឈមផងដែរ ។ គោលនយោបាយសម្រាប់ពង្រឹង ស្ថាប័នទីផ្សារការងារ និងកាត់បន្ថយភាពក្រីក្រត្រូវការពឹងផ្អែកទៅលើមូលដ្ឋានព័ត៌មានដ៏រឹងមាំមួយនៃ ទិន្នន័យ និងស្ថិតិដែលស៊ីគ្នា ។ បច្ចុប្បន្នមានគម្លាតជាឧបសគ្គមួយចំនួន ទោះបីមានការខិតខំប្រឹងប្រែងច្រើន ដើម្បីធ្វើការឆ្លើយតបចំពោះស្ថានការណ៍ក៏ដោយ ។

# តារាង ឧបសម្ព័ន្ធស្ថិតិ


| | | |
|---|---|---|
| តារាង ១ | ប្រជារាស្ត្រ តាមក្រុមអាយុ ៥ ឆ្នាំ និងភេទ ឆ្នាំ ១៩៩៨ និង ២០០៨ | ៧៤ |
| តារាង ២ | កំរិតសិក្សាដែលបានបញ្ចប់ដោយប្រជារាស្ត្រចេះអក្សរ ឆ្នាំ ១៩៩៨ និង ២០០៨ | ៧៥ |
| តារាង ៣ | GDP តាមផលិតកម្មតាមថ្លៃថេរឆ្នាំ ២០០០ (គិតជាពាន់លានរៀល) | ៧៦ |
| តារាង ៤ | អត្រាកំណើន GDP តាមថ្លៃថេរឆ្នាំ ២០០០ (គិតជាភាគរយ) | ៧៧ |
| តារាង ៥ | ពាណិជ្ជកម្មតាមថ្លៃថេរឆ្នាំ ២០០០ (គិតជាពាន់លានរៀល) | ៧៨ |
| តារាង ៦ | លំហូរចូលការវិនិយោគផ្ទាល់ពីបរទេស តាមប្រទេស FDI (គិតជាលានដុល្លារអាមេរិក) | ៧៩ |
| តារាង ៧ | តារាង ៧ សន្និធិ ការវិនិយោគផ្ទាល់ពីបរទេស FDI តាមប្រទេស (គិតជាលានដុល្លារអាមេរិក) | ៨០ |
| តារាង ៨ | តារាង ៨ លំហូរចូល ការវិនិយោគផ្ទាល់ពីបរទេស FDI តាមវិស័យ (គិតជាលានដុល្លារអាមេរិក) | ៨១ |
| តារាង ៩ | តារាង ៩ សន្និធិ ការវិនិយោគផ្ទាល់ពីបរទេស FDI តាមវិស័យ (គិតជាលានដុល្លារអាមេរិក) | ៨១ |
| តារាង ១០ | ការប៉ាន់ស្មានភាពក្រីក្រ តាមតំបន់ | ៨២ |
| តារាង ១១ | ចំណាយប្រើប្រាស់ក្នុងថ្លៃថេរឆ្នាំ ២០០០ (គិតជាពាន់លានរៀល) | ៨២ |
| តារាង ១២ | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ GDP ភ្នំពេញ (ខែ កក្កដា-ធ្នូ ឆ្នាំ ២០០០=១០០) | ៨៣ |
| តារាង ១៣ | កម្លាំងពលកម្ម និងអត្រាចូលរួមកម្លាំងពលកម្ម (%) | ៨៤ |
| តារាង ១៤ | ផលធៀបប្រជារាស្ត្រមានការងារធ្វើ និងគ្មានការងារធ្វើធៀបនឹងកម្លាំងពលកម្ម (%) | ៨៥ |
| តារាង ១៥ | ប្រជារាស្ត្រមានការងារធ្វើ និងផលធៀបប្រជារាស្ត្រមានការងារធ្វើធៀបនឹងប្រជារាស្ត្រ (%) | ៨៦ |
| តារាង ១៦ | អ្នកមានការងារធ្វើ តាមសកម្មភាពសេដ្ឋកិច្ច អាយុ និង ភេទឆ្នាំ ២០០៨ | ៨៧ |
| តារាង ១៧ | ប្រជារាស្ត្រមានការងារធ្វើ តាមសកម្មភាពសេដ្ឋកិច្ច អាយុ និង ភេទឆ្នាំ ១៩៩៨ | ៨៨ |
| តារាង ១៨ | អ្នកមានការងារធ្វើ តាមស្ថានភាពការងារ អាយុ និង ភេទឆ្នាំ ១៩៩៨-២០០៨ | ៨៩ |
| តារាង ១៩ | អ្នកមានការងារធ្វើ តាមកំរិតសិក្សាដែលបានបញ្ចប់ និង ភេទ | ៩០ |
| តារាង ២០ | អត្រាអ្នកគ្មានការងារធ្វើ តាមកំរិតសិក្សាអប់រំ និង ភេទ | ៩១ |
| តារាង ២១ | ចំនួនអ្នកគ្មានការងារធ្វើ តាមកំរិតសិក្សាដែលបានបញ្ចប់ (អាយុ ៧ ឆ្នាំឡើង) | ៩២ |
| តារាង ២២ | កម្មករផ្លាស់ប្តូរលំនៅដ្ឋាន ដើម្បីការងារក្នុងប្រទេស ឆ្នាំ ១៩៩៨-២០០៨ | ៩៣ |
| តារាង ២៣ | និស្សិតបានបណ្តុះបណ្តាលអប់រំបច្ចេកទេស និងជំនាញវិជ្ជាជីវៈ | ៩៤ |
